# ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៩

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 30-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ៕

## LPN សូមគោរពអញ្ជើញបងប្អូនពលករខ្មែរ ដែលធ្វើការក្នុងប្រទេសថៃ ចូលរួមកម្មវិធី ស្តាប់បញ្ហាពលករកម្ពុជា ក្នុងប្រទេសថៃ

https://www.facebook.com/LabourOfficial/ 01-10-2019

សូមគោរពអញ្ជើញបងប្អូនពលករខ្មែរ ដែលធ្វើការក្នុងប្រទេសថៃ ចូលរួមកម្មវិធី( ស្តាប់បញ្ហាពលករកម្ពុជា ក្នុងប្រទេសថៃ )ដែលរៀបចំឡើងលើកទី២ ដោយអង្គការបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ (LPN) កម្មវិធីនេះចាប់ផ្តើមនៅវេលាម៉ោង០៨ព្រឹក ដល់០៣រសៀល ថ្ងៃអាទិត្យ ទី០៦ ខែតុលា ឆ្នាំ២០១៩នេះ នៅសណ្ឋាគារ The Color Living ស្ថិតនៅផ្លូវថេបផារ៉ាក់ ខេត្តសាមុតសាប្រាកាន ដោយមានការចូលរួមពីសំណាក់ភ្នាក់ងាររដ្ឋដូចជា៖

.មន្ទីរការងារ ខេត្តសាមុតសាប្រាកាន

.មន្ទីរសុខមាលភាពនិងគាំពារសិទ្ធិពលករ ខេត្តសាមុតសាប្រាកាន

.មន្ទីរសង្គមកិច្ចនិងអភិវឌ្ឍសង្គម ខេត្តសាមុតសាប្រាកាន

.សមាគមពាណិជ្ជកម្មនិយោជក ព្រមទាំងអាជ្ញាធរពាក់ព័ន្ធជាច្រើនទៀត។

អាស្រ័យហេតុនេះសូមគោរពអញ្ជើញបងប្អូនពលករខ្មែរ ដែលធ្វើការរស់នៅក្នុងខេត្តសាមុតប្រាកាន និងខេត្តផ្សេងៗក្នុងប្រទេសថៃ ចូលរួមអោយបានច្រើនកោះកុង ។

# ថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៩

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 02-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៥នាក់ នាថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មានស្រុកកណើតនៅខេត្តសៀមរាប ០២នាក់ ស្រី ០១នាក់, ខេត្តកំពង់ធំ ០១នាក់ ស្រី ០១នាក់ និងខេត្តតាកែវ ០២នាក់៕

## ចំណាកស្រុកធ្វើការឲ្យគេ តែអកុសល ពលករខ្មែរម្នាក់ជួបគ្រោះថ្នាក់ចរាចរណ៍ដាច់ជើងទាំងពីរ

http://nokorwatnews.com/ 02-10-2019

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរម្នាក់ធ្វើការប្រមូលសំរាមនៅក្នុងក្រុង Pattaya ត្រូវរថយន្តបុកដាច់ជើងទាំងសងខាងកាលពីវេលាម៉ោង០២រំលងអធ្រាត្រ ឈានចូលថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ នៅត្រង់ចំណុចស្របផ្លូវរថភ្លើងជិតភូមិខៅតាឡូ សង្កាត់ណង់ព្រឺ ស្រុកបាងឡាលុង ខេត្តឈុនបុរី ប្រទេសថៃ ។ សមត្ថកិច្ចមូលដ្ឋានថា ជនរងគ្រោះ

មានឈ្មោះ ឈួន ប៊ុនរឿន ភេទប្រុស ២៨ ឆ្នាំ សញ្ជាតិខ្មែរ ស្រុកកំណើតរស់នៅស្រុកមង្គលបូរី ខេត្ត បន្ទាយមានជ័យ បានរងរបួសដាច់ជើងទាំងសងខាង ។ ចំណែកឯរថយន្តបង្គម៉ាក Nissan Sylphy ពាក់ស្លាកលេខ 4 កណ 4462 បាងកក បើកបរដោយបុរសជនជាតិថៃម្នាក់បានបើកទៅបុកគូទរថយន្តប្រមូលសំរាម ពាក់ស្លាកលេខ 73-3948 របស់ក្រុមហ៊ុន Eastern Green World គ្រាដែលជនរងគ្រោះកំពុងធ្វើសកម្មភាពប្រមូលសំរាមតាមទីសាធរណៈបណ្ដាលឲ្យខាងក្រោយរថយន្តរងរបួសធ្ងន់។ ក្រោយពេលកើតហេតុជនរងគ្រោះត្រូវសមត្ថកិច្ចសង្គ្រោះដឹកបញ្ជូនយកទៅព្យាបាលបន្ទាន់នៅមន្ទីរពេទ្យក្នុងស្រុកបាងឡាលុង ។ ប្រភពថា ជនរងគ្រោះរហូតមកទល់នឹងវេលាម៉ោងនេះបានស្លាប់ហើយ ៕ នីមវណ្ណា

# ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៩

## កម្ពុជា អរគុណ រដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត ដែលឲ្យពលករខ្មែរ ជាស្ត្រីធ្វើការងារតាមផ្ទះ

https://www.dap-news.com/ ByID:117 Posted on 03 October 2019 | 17:45

**ភ្នំពេញ ៖** សម្តេច សាយ ឈុំ ប្រធានព្រឹទ្ធសភា បានថ្លែងអំណរគុណចំពោះ រដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត ដែលឲ្យពលករកម្ពុជាជាស្ត្រី បានទៅធ្វើការងារតាមផ្ទះ នៅអារ៉ាប៊ីសាអូឌីត ស្របតាមកិច្ចព្រមព្រៀងស្តីពី ការជ្រើសរើសពលកររវាង កម្ពុជា និងអារ៉ាប៊ីសាអូឌីត។

ក្នុងជំនួបពិភាក្សាការងារជាមួយ លោក Saud F.M. Alsuwelim ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតប្រចាំកម្ពុជា នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៩ សម្តេច សាយ ឈុំ បានឲ្យដឹងថា អារ៉ាប៊ីសាអូឌី នឹងជំរុញវិនិយោគរបស់ខ្លួន មកធ្វើវិនិយោគនៅ កម្ពុជាលើកវិស័យកសិកម្ម និងវិស័យផ្សេងៗទៀត។

ចំណែកលោក Saud F.M. Alsuwelim បានលើកឡើងថា ការផ្តល់ហិរញ្ញប្បទាន ដល់ព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តនូវគម្រោង ចាំបាច់ណាមួយ សម្រាប់អភិវឌ្ឍ ប្រទេសកម្ពុជា ឲ្យកាន់តែរីកចម្រើន ថែមទៀត ពីព្រោះបច្ចុប្បន្ន កម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងមានការអភិវឌ្ឍ យ៉ាងឆាប់រហ័ស លើគ្រប់វិស័យ ជាពិសេស ការគ្រប់គ្រង ថវិកាជាតិ និងការប្រមូលពន្ធបានល្អ៕

## ក្រសួងសង្គមកិច្ច បានចុះកិច្ចព្រមព្រៀង ជាមួយអង្គការចំនួនពីរ បន្ថែមទៀត លើកិច្ចការងារកុមារ និងការជួញដូរមនុស្ស

http://bayontv.com.kh/ 04/10/2019

ភ្នំពេញ ៖ ក្រសួងសង្គមកិច្ច បានសម្រេចចុះកិច្ចព្រមព្រៀងការងារ ជាមួយអង្គការចំនួន ២ លើកិច្ចការងារជួយដល់កុមារ និងកិច្ចការងារជួយដល់ជនរងគ្រោះដោយការជួញដូរនៅកម្ពុជា ។ ការចុះកិច្ចព្រមព្រៀងនេះផ្ទាល់ធ្វើឡើង នៅព្រឹកថ្ងៃទី ៤ ខែតុលាឆ្នាំ ២០១៩ ដោយមានការចូលរួមជាអធិបតីពី ឯកឧត្តម តូច ចាន់នី អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ ក្រសួងសង្គមកិច្ចបានចុះកិច្ចព្រមព្រៀងការងារជាមួយ អង្គការដៃកម្ពុជា (ARM) និងមូលនិធិ អេ២១ ដើម្បីរួមចំណែកការងារសង្គមជួយលើផ្នែក កុមារ និងជនរងគ្រោះក្នុងអំពើជួញដូរមនុស្ស។

សម្រាប់អង្គការដៃកម្ពុជា ដែលបានចុះកិច្ចព្រមព្រៀងនាពេលនេះ មានទំហំទឹកប្រាក់ចំនួនជាង ៣លានដុល្លារ ក្នុងរយៈពេល៣ឆ្នាំ ដោយអង្គការផ្តោតលើការស្តានីតិសម្បទា និងសមាហរណកម្មដល់កុមាររងគ្រោះដោយសារ ការរំលោភបំពានផ្លូវភេទ ការជួញដូរផ្លូវភេទ និងការជួញដូរពលកម្ម ហើយទីតាំងអនុវត្តគម្រោងគឺស្ថិតនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ។ រីឯមូលនិធី អេ ២១វិញ គឺនឹងជួយដល់ការការពារជនរងគ្រោះក្នុងអំពើជួញដូរមនុស្ស និងការធ្វើសម

ហរណេកម្មជនរងគ្រោះទៅសហគមន៍វិញផងដែរ ដោយទីតាំងអនុវត្តគម្រោងធ្វើឡើងនៅក្រុង ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងមាន ថវិកា ជាង៦សែនដុល្លារសម្រាប់អនុវត្តកម្មវិធី។

ក្នុងឱកាសចុះកិច្ចព្រមព្រៀងនេះ ឯកឧត្តម តូច ចាន់នីអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស បញ្ជាក់ថា ក្រសួងតែងស្វាគមន៍បណ្ដាអង្គការទាំងអស់ ដែលចូលមករួមចំណែកជួយដល់កម្ពុជា តែយ៉ាងណាមិញក៏ទាមទារឱ្យអង្គការទាំងអស់ត្រូវគោរពតាមគោលការណ៍ និងមិនត្រូវឆ្លៀតឱកាសធ្វើការងារនយោបាយនោះទេ។ អង្គការទាំងនោះត្រូវមាន លក្ខខណ្ឌកម្មវិធីជាក់លាក់ និងគម្រោងទាំងនោះ **ត្រូវផ្ដល់ប្រយោជន៍**ដល់ក្រុមគោលដៅពិតប្រាកដ។ ឯកឧត្តមបន្តថា បន្ទាប់ពីការចុះកិច្ចព្រមព្រៀងរួច មន្ទីរសង្គមកិច្ចនៅតាមរាជធានី ខេត្ត ត្រូវតាមដានសកម្មភាពរបស់អង្គការថា តើគោរពតាមកិច្ចព្រមព្រៀងរឺទេ។ ឯកឧត្តម បញ្ជាក់ដែរថា មកដល់ពេលនេះ ក្រសួងសង្គមកិច្ច បានចុះកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ១២៥ហើយ ដោយមានទំហំទឹកប្រាក់ជាង ១០០លានដុល្លារ។

គួរបញ្ជាក់ថា អង្គការទាំង២ ដែលបានចុះហត្ថលេខា លើកិច្ចព្រមព្រៀង ជាមួយក្រសួងសង្គមកិច្ចនាពេលនេះ សុទ្ធសឹងតែជាអង្គការ ដែលបានចូលរួមចំណែកជួយការពារជនរងគ្រោះពីការជួញដូរមនុស្ស ករណីកេងប្រវ័ញ្ចលើកុមារ ការរំលោភបំពាន ផ្លូវភេទ ការជួញដូរផ្លូវ ភេទ និងការជួញដូរកម្លាំងពលកម្ម៕

## យោធាកម្ពុជា-ថៃ បន្តសហការគ្នាដើម្បីសន្តិភាព

https://www.postkhmer.com/ ខន សារី | Publication date 04 October 2019 | 10:28 ICT

**ភ្នំពេញៈ** មន្ត្រីយោធាកម្ពុជា-ថៃ សន្យាពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្នាបន្ថែមទៀត ខណៈមន្ត្រីជាន់ខ្ពស់យោធាកម្ពុជាបានអះអាងថា ប្រទេសទាំង ២ មានសន្តិភាពល្អជាមួយគ្នាចាប់តាំងពីលោក ប្រាយុធ ចាន់អូចា បានក្លាយជានាយករដ្ឋមន្ត្រីរបស់ប្រទេស ថៃ មក។ ការអះអាងអំពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងយោធាកម្ពុជា-ថៃនេះ បានធ្វើឡើងនៅថ្ងៃម្សិលមិញនៅឯទីស្ដីការគណៈរដ្ឋមន្ត្រីគឺនៅក្នុងជំនួបរវាងលោក សាយុទ្ធ ប៊ុនជី អនុព័ន្ធយោធាកងទ័ពជើងគោក និងលោក ចាត់ទុរុង ឌីភីងទុន អនុព័ន្ធយោធាកងទ័ពជើងទឹកនៃកងទ័ពភូមិន្ទថៃដែលបានដឹកនាំមន្ត្រីជួបពិភាក្សាដើម្បីជម្រាបលាលោក នាង ផាត រដ្ឋលេខាធិការក្រសួងការពារជាតិពេលបញ្ចប់អាណត្តិការទូតយោធានៅកម្ពុជា។

លោក នាង ផាត ថ្លែងថាថ្វីដ្បិតមានបញ្ហាស្មុគស្មាញជាច្រើនដែលមន្ត្រីយោធាប្រទេសទាំង ២ ត្រូវបន្តសហការគ្នាដើម្បីដោះស្រាយបន្ថែមក្តី ប៉ុន្តែសន្តិភាពរវាងភាគីទាំង ២ គឺមានភាពល្អប្រសើរចាប់ពីប្រទេសថៃបានស្ថិតក្រោមការដឹកនាំដោយលោក ប្រាយុធ ចាន់អូចា មក។ លោកថា ខាងភាគីកម្ពុជានឹងបន្តសហការធ្វើការងារជាមួយភាគីយោធាថៃ ដើម្បីពង្រឹងទំនាក់ទំនងកងទ័ពប្រទេសទាំង ២ ឱ្យកាន់តែល្អប្រសើរថែមទៀត។ លោកថ្លែងថា៖ «ក្នុងការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ប្រាយុធ ចាន់អូចា ធ្វើឱ្យប្រទេសយើងទាំង ២ មានសន្តិភាពជាមួយគ្នាល្អ ហើយក៏សូមអរគុណខាង (ទាហានថៃ) តម្រួតថៃដែរ ព្រោះខ្ញុំដឹងថា កម្មករខ្មែរចេញចូលមានភាពត្រឹមត្រូវ និងខុសច្បាប់ខ្លះ និងជួបការងារស្មុគស្មាញណាស់ ហើយបានដោះស្រាយរហូតមក ហើយរវល់ជាងជើងគោក ជើងអាកាស និងជើងទឹកទៀត»។

លោក សាយុទ្ធ ប៊ុនជី បញ្ជាក់ដែរថាប្រទេសទាំង ២ កំពុងសហការគ្នាល្អដើម្បីអភិវឌ្ឍនៅតាមតំបន់ព្រំដែនឱ្យបានល្អប្រសើរថែមទៀត។ ប៉ុន្តែការផ្សព្វផ្សាយរបស់សារព័ត៌មានកន្លងមកដែលថាមានពលរដ្ឋខ្មែរដែលលួចឆ្លងដែនចូលកាប់ឈើខុសច្បាប់ក្នុងទឹកដីថៃ និងត្រូវទាហានថៃបាញ់សម្លាប់ អាចធ្វើឱ្យប៉ះពាល់ទំនាក់ទំនងរវាងប្រជាជនទាំង ២ គឺអាចជាព័ត៌មានមិនពិត និងមិនទាន់គ្រប់ជ្រុងជ្រោយនោះទេ។ លោកថ្លែងតាមរយៈអ្នកបកប្រែថា៖ «រឿងដែលសំខាន់មួយនោះគឺព័ត៌មានដែលចេញផ្សាយទៅសុំឱ្យមានការត្រួតពិនិត្យឱ្យបានច្បាស់លាស់ តើពិតឬមិនពិត មុនការ

ចេញផ្សាយ»។ ប្រទេស ថៃ នឹងបញ្ជូនលោកវរសេនីយ៍ឯក ដេសានុ សារ៉ាជី អនុព័ន្ធយោធាតំណាងឱ្យកងទ័ពជើងគោក និងលោក ស៊ុប៉ាកាន វិថារ៉ាត់ អនុព័ន្ធយោធាតំណាងឱ្យកងទ័ពជើងទឹក ដើម្បីបន្តអាណត្តិការទូតយោធានៅកម្ពុជារយៈពេល ៣ ឆ្នាំបន្ថែមទៀត៕

## កុមារកម្ពុជា និងកុមារភូមា រីករាយ ពេលបានចូលរៀន បណ្តោះអាសន្ន នៅមជ្ឈមណ្ឌល កុមារមេត្តេយ្យ របស់ក្រុមហ៊ុនបុរី សាងសង់ផ្ទះមួយក្នុងខេត្តប៉ាធុមថានី

https://www.facebook.com/LabourOfficial/ ប្រាក់ ភក្ត្រា-Prak Pheaktra 04/10/19

កុមាកម្ពុជា និងកុមាភូមា រីករាយ ពេលបានចូលរៀន បណ្តោះអាសន្ន នៅមជ្ឈមណ្ឌល កុមារមេត្តេយ្យ របស់ក្រុមហ៊ុនបុរី សាងសង់ផ្ទះមួយក្នុងខេត្តប៉ាធុមថានី បន្ទាប់ពីឪពុកម្តាយរបស់ពួកគេ បានចំណាកស្រុក ពីប្រទេសកម្ពុជាមកធ្វើការនៅប្រទេសថៃ ព្រមទាំងយកកូនតូចៗមកជាមួយផង។

នេះជាលើកទី១ ហើយដែលក្រុមហ៊ុនសាងសង់បុរី ក្នុងប្រទេសថៃ យកចិត្តទុកដាក់ចំពោះកុមារបរទេស ដែលតាមឪពុកម្តាយចំណាក់ស្រុកចូលប្រទេសថៃ ដោយមិនបានរៀនសូត្រ ដោយសារហេតុនេះខាងក្រុមហ៊ុនបានសម្រេចសាងសង់ អគារមួយខ្នង ព្រមទាំងរៀបចំឧបករណ៍រៀនសូត្របណ្តោះអាសន្នជូនកុមារបរទេសទាំងនោះ ដើម្បីឲ្យពួកគេបានរៀនសូត្រ អំឡុងពេលដែលឪពុកម្តាយនៅធ្វើការក្នុងក្រុមហ៊ុននេះ។

តែអ្វីដែលសំខាន់នោះគឺកុមារកម្ពុជាទាំងអស់នោះ មិនបានរៀនភាសាខ្មែរ ដូចនៅប្រទេសកម្ពុជានោះទេ ដោយសារតែគ្មានគ្រូបង្រៀនភាសាខ្មែរ ក្នុងករណីខ្វះខាតគ្រូបង្រៀនភាសាខ្មែរ ក្នុងករណីនេះដែរ អង្គការបណ្តាញលើកកម្ពស់គុណភាពជីវិត ឬហៅកាត់ថា (LPN) ប្រទេសថៃ កំពុងប្រកាសជ្រើសរើសគ្រូបង្រៀនភាសាខ្មែរ ស្មាកចិត្តដើម្បីយកបង្រៀនដល់កុមារកម្ពុជាទាំងអស់នោះ អោយបានយល់ដឹងអំពីភាសាជាតិរបស់ខ្លួន។

# ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៩

## ក្រសួងការងារអនុញ្ញាតឱ្យជនបរទេសប្រកបមុខរបរដូចធម្មតាវិញ ក្រោយចេញបម្រាមជាង១ខែ

https://www.rfa.org/khmer/news/ ដោយ ជី វិតា 2019-10-06

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុញ្ញាតឱ្យជនបរទេស អាចប្រកបមុខរបររកស៊ីនៅកម្ពុជាឡើងវិញជាធម្មតា បន្ទាប់ពីចេញបម្រាមហាមឃាត់មិនទាន់បានពីរខែផង។ សង្គមស៊ីវិល និងសហជីព សម្តែងការសោកស្តាយចំពោះការសម្រេចចិត្តរបស់ក្រសួងការងារនេះ ព្រោះពួកគេយល់ថា នេះជាការបើកឱកាសឱ្យជនជាតិបរទេសដណ្តើមការងារពលរដ្ឋខ្មែរ និងធ្វើឱ្យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសកាន់តែច្រើន។

បន្ទាប់ពីហាមឃាត់បរទេសមិនឱ្យប្រកបមុខរបរមួយចំនួនបានជាង១ខែ ស្រាប់តែក្រសួងការងារ បានប្រកាសអនុញ្ញាតឱ្យជនបរទេសប្រកបមុខរបរគ្រប់ប្រភេទឡើងវិញ។ សេចក្តីជូនដំណឹងរបស់ក្រសួងការងារ ដែលអាស៊ីសេរីទទួលបាននៅថ្ងៃទី៦ ខែតុលា បង្ហាញថា ការអនុញ្ញាតឱ្យជនបរទេសប្រកបមុខរបរគ្រប់ប្រភេទឡើងវិញនេះ ដោយសារតែមានតម្រូវការកម្លាំងពលកម្មជំនាញ និងដើម្បីលើកទឹកចិត្តការវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណា សេចក្តីជូនដំណឹងថ្មីនេះ គឺផ្ទុយពីសេចក្តីប្រកាស កាលពីថ្ងៃទី២៨ ខែសីហា កន្លងទៅដែលក្រសួងការងារ បានដាក់កំហិតមិនឱ្យជនបរទេសធ្វើការ និងប្រកបមុខរបរចំនួន១០ប្រភេទនៅកម្ពុជា ដើម្បីការពារទីផ្សារការងារដល់ប្រជាពលរដ្ឋកម្ពុជា។ មុខរបរដែលស្ថិតក្នុងបម្រាមទាំងអស់នោះរួមមាន អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ជាលក្ខណៈអាជីវកម្ម ការលក់ដូរដោយមធ្យោបាយថ្មើរជើង ឬយានជំនិះគ្រប់ប្រភេទ ម៉ាស្សា និងចាប់សសៃតាមសាធារណៈ កាត់សក់

អ៊ុតសក់ ថែរក្សាសម្ផស្ស សេវាកម្មដេរ និងសម្អាតស្បែកជើង ប៉ះកង់ ជួសជុលយានយន្ត កាត់ដេរ ផលិតវត្ថុអនុស្សាវរីយ៍ខ្មែរ ផលិតឧបករណ៍ភ្លេងខ្មែរ ផលិតបាត្រលោក ព្រះពុទ្ធរូប និងជាងទង និងជាងច្នៃត្បូងពេជ្រ។

អាស៊ីសេរី មិនអាចសុំការពន្យល់បន្ថែមអំពីរឿងនេះ ពីរដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បានទេនៅថ្ងៃទី០៦ តុលា ដោយទូរស័ព្ទចូលពុំមានអ្នកទទួល។

ប្រធានសហព័ន្ធសហជីពកម្មករនិយោជិកវិស័យទេសចរណ៍សេវាកម្មកម្ពុជា លោក ម៉ម រិទ្ធី ថ្លែងថា នេះជារឿងគួរឱ្យសោកស្ដាយដែលក្រសួងការងារចេញសេចក្ដីសម្រេច គ្មានភាពជាក់លាក់ដូច្នេះ។ លោកបន្ថែមថា ក្ដីរំពឹងរបស់ពលរដ្ឋដែលថា នឹងមានមុខរបរសមរម្យ ហើយមិនមានជនបរទេសដណ្ដើមការងារពីពួកគាត់នោះ ត្រូវបានរលាយទៅវិញហើយ តាមរយៈសេចក្ដីជូនដំណឹងរបស់ក្រសួងការងារនេះ៖ «កន្លងមក យើងមានការបារម្ភថា ករណីនេះធ្វើឱ្យបាត់បង់ ចំណូលនិងបាត់បងមុខរបររកស៊ីរបស់ប្រជាពលរដ្ឋខ្មែរ ហើយនៅពេលដែលក្រសួងហាមឃាត់រួចហើយបែរជាលុបចោលវិញ។ យើងខកចិត្តខ្លាំងហ្មង ហើយផលប៉ះពាល់មិនមែនតែមួយផ្នែកទេ គឺយើងរាប់ទាំងការងារខាងក្រោមតូចៗ គឺជនបរទេសយកធ្វើឡើងវិញទាំងអស់។ ការងារអ៊ុតសក់ កាត់សក់ ធ្វើក្រចក រុញរទេះលក់តាមផ្លូវ សុទ្ធតែជាការងារដែលខ្មែរយើងអាចធ្វើបាន ដូច្នេះហេតុអី បានជាលើកទឹកចិត្តឱ្យប្រជាពលរដ្ឋគេមករកស៊ីមុខរបរទាំងនេះទៅវិញ»។

លោក ម៉ម រិទ្ធី បារម្ភថា ការអនុញ្ញាតឱ្យជនបរទេសប្រកបរបររកស៊ីដោយខ្លួនឯងនេះ គឺជាបើកឱកាសឱ្យជនបរទេសដណ្ដើមការងារពីពលរដ្ឋខ្មែរ ហើយគឺជាផ្នែកមួយធ្វើឱ្យពលរដ្ឋខ្មែរជាច្រើននាក់អត់ការងារធ្វើ និងនាំគ្នាធ្វើចំណាកស្រុកទៅក្រៅប្រទេសទាំងប្រថុយប្រថាន៖ « បាត់មុខរបរទាំងនេះហើយធ្វើឱ្យប្រជាជនចំណាកស្រុកកាន់តែច្រើនទៅៗ។ យើងមើលឃើញនៅប្រទេសថៃវិញ គ្រាន់តែខ្មែរយើងរុញរទេះលក់គេចាប់ភ្លាម គេមិនបើកឱ្យយើងរុញរទេះលក់ទេ គេត្រឹមតែឱ្យយើងទៅធ្វើកម្មករស៊ីឈ្នួលគេទេ ហើយធ្វើការងារ ដែលបានប្រាក់ខែតិចនិងការងារដែលប្រជាជនគេមិនធ្វើថែមទៀត។ហេតុអីទើបគេធ្វើអ៊ីចឹង ព្រោះគេ ចង់ថែរក្សាមុខរបរឱ្យប្រជាជនរបស់គេ ។ចុះយើងហេតុអីមិនធ្វើដូចគេ»។ ប្រធានសហជីពខាងវិស័យទេសចរណ៍រូបនេះ សង្ស័យថា ការអនុញ្ញាតឱ្យជនជាតិបរទេសប្រកបមុខរបរគ្រប់ប្រភេទឡើងវិញនេះ ប្រហែលជារដ្ឋាភិបាលកម្ពុជា ទទួលសំណើពីរដ្ឋាភិបាលចិន ឬ រដ្ឋាភិបាលវៀតណាម ដោយសារតែពលរដ្ឋរបស់ប្រទេសទាំងពីរនេះ កំពុងមានវត្តមានរកស៊ីមុខរបរ ស្ទើរគ្រប់ប្រភេទនៅកម្ពុជា។ លោកកត់សម្គាល់ថា តំបន់ដែលពួកគេដណ្ដើមការងារខ្មែរច្រើនជាងគេ មាននៅរាជធានីភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ ដោយសារតំបន់ទាំងនេះសំបូរជនបរទេសរស់នៅ និងមានកំណើនសេដ្ឋកិច្ចគ្រាន់បើជាងគេនៅកម្ពុជា។

រីឯអ្នកសម្របសម្រួលមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក យុន ថារ៉ូ លើកឡើងថា ចំណាត់ការរបស់ក្រសួងការងារកន្លងមក គឺគ្រាន់តែដើម្បីឆ្លើយតបចំពោះប្រតិកម្មរបស់សាធារណជនមួយភ្លែតប៉ុណ្ណោះ គ្មានភាពប្រាកដប្រជានោះទេ។ លោកសង្កេតឃើញថា ជនជាតិបរទេស មិនត្រឹមតែមានសិទ្ធិប្រកបមុខរបរគ្រប់ប្រភេទដូចពលរដ្ឋខ្មែរម្ចាស់ប្រទេសនោះទេ ប៉ុន្តែសូម្បីតែការងារជំនាញផ្សេង ៗក៏ពួកគេមានលក្ខខណ្ឌការងារល្អ និងប្រាក់ខែខ្ពស់ជាងពលរដ្ឋខ្មែរដែរ ទោះបីជាការងារនិងតួនាទី ដូចគ្នាក្ដី។ លោកស្នើសុំឱ្យក្រសួងការងារសិក្សាស្រាវជ្រាវឱ្យបានច្បាស់លាស់ ដើម្បីធានារក្សាទី ផ្សារការងារសម្រាប់ពលរដ្ឋម្ចាស់ប្រទេសជាអាទិភាព៖ «យើងត្រូវគិតថា ធម្មតាទីផ្សារសេរីហើយក្នុងបរិបទអាស៊ាន គឺយើងមិនអាចរើសអើងការប្រកបវិជ្ជាជីវៈមុខរបរទេ ប៉ុន្តែយើងត្រូវមានកំណត់លក្ខខណ្ឌបែបណា ប្រភេទមុខរបរណា កុំឱ្យវាប៉ះពាល់នឹងទីផ្សារការងារពលរដ្ឋខ្មែរដែលគាត់មានជំនាញវិជ្ជាជីវៈ ប្រហាក់ប្រហែលនឹងកម្មករបរទេសដែរ។ មិនថាប្រទេសណានោះទេ គឺគេមានកម្រិតលក្ខខណ្ឌមួយដើម្បីធានាថា ការងារក្នុងស្រុកត្រូវប្រគល់ជូនអាទិភាពសម្រាប់ម្ចាស់ស្រុកមិនមែនជនបរទេសនោះទេ។

របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចេញកាលពីខែមីនា ឆ្នាំ២០១៩ បញ្ជាក់ថា ក្នុងឆ្នាំ២០១៨ ក្រសួងបានផ្តល់បណ្ណ័ និងសៀវភៅការងារដល់ជនបរទេសជាង១៣ម៉ឺន ៥៣ាន់( ១៣៥,២០១)នាក់។

ប្រជាពលរដ្ឋមួយចំនួន ក៏បានប្រតិកម្មចំពោះការប្រកាសរបស់ក្រសួងការងារនេះនៅលើបណ្តាញសង្គមហ្វេសប៊ុកដែរ។ ពួកគេ លើកឡើងថា គ្មានប្រទេសណាមួយបើកដៃឱ្យជនបរទេសរកស៊ីគ្រប់ ប្រភេទនោះទេ។ ពួកគេ លើកឡើងថា ប្រជាពលរដ្ឋវៀតណាម និងជនជាតិចិន កំពុងតែហូរចូលយ៉ាងគំហុកនៅក្នុងប្រទេសកម្ពុជា ដែលរកស៊ីនិងធ្វើការងារស្ទើរគ្រប់វិស័យ រាប់ចាប់ពីកាស៊ីណូ សណ្ឋាគារ ភោជនីយដ្ឋាន រហូតដល់មុខរបរតូចតាចជាដើម ដែលទាំងអស់នេះ បានបង្កជាក្តីកង្វល់ដល់ប្រជាពលរដ្ឋខ្មែរនៅមូលដ្ឋានដែលប្រកបមុខរបរដូចគ្នា។ ស្របពេលជនបរទេសសម្រុកចូលមកដណ្តើមការងារនិងមុខរបរនៅកម្ពុជា ពលរដ្ឋខ្មែររាប់សែននាក់ កំពុងស្វែងរកការងារធ្វើនៅបរទេស។ ប្រជាពលករខ្មែរខ្លះ ត្រូវបានថៅកែបរទេស រំលោភបំពានសិទ្ធិការងារ កេងប្រវ័ញ្ចកម្លាំងពលកម្ម និងរំលោភបំពានផ្លូវភេទ ហើយអ្នកខ្លះត្រូវជាប់គុកនិងបាត់បង់ជីវិតនៅស្រុកគេទៀតផង៕

## នាយឧត្តមសេនីយ៍ នេត សាវឿន៖ កិច្ចសហការរវាង FBI អាមេរិកជាមួយនឹងប៉ូលិសកម្ពុជា ធ្វើឲ្យបទល្មើសធ្លាក់ចុះ

http://bayontv.com.kh/ 06/10/2019

ភ្នំពេញ៖ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិបានបញ្ជាក់ថា ជោគជ័យកិច្ចសហប្រតិបត្តិការរវាង FBI សហរដ្ឋអាមេរិកជាមួយនឹងនគរបាលជាតិកម្ពុជា បានធ្វើឲ្យបទល្មើសធ្លាក់ចុះគួរឲ្យកត់សម្គាល់។ កិច្ចសហប្រតិបត្តិការកន្លងមកនេះ បានធ្វើឲ្យជនជាតិអាមេរិកប្រព្រឹត្តបទល្មើសនៅកម្ពុជា មានការថយចុះគួរឲ្យកត់សម្គាល់ នេះជាមោទនភាពរបស់អាមេរិក និងកម្ពុជា។

ការបញ្ជាក់នេះ បានធ្វើឡើងក្នុងពិធីបំពាក់មេដាយសហមេត្រីថ្នាក់សេនា ជូនដល់មន្ត្រី FBI សហរដ្ឋអាមេរិក ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ លើវិស័យការពារសន្តិសុខសុវត្ថិភាពនៅអគ្គស្នងការដ្ឋាននគរបាលជាតិ។ អគ្គស្នងការនគរបាលជាតិបានបន្តថា ចំណុចទាំង៣ នៃជោគជ័យកិច្ចសហប្រតិបត្តិការរវាង FBI ជាមួយនឹងនគរបាលជាតិកម្ពុជា ដែលធ្វើឲ្យបទល្មើសបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ គឺទី១.កិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវ បង្ក្រាបបទល្មើស ជាពិសេសការទប់ស្កាត់អំពើអានាចារ្យរំលោភផ្លូវភេទលើកុមារ និងករណីមួយចំនួនទៀត ដែលមានយ៉ាងហោចប្រមាណ ១០ករណី។ ទី២.FBI បានជួយក្នុងការបណ្តុះបណ្តាលធនធានសមត្ថភាពដល់នគរបាលជាតិកម្ពុជា និងទី៣.FBI បានជួយបណ្តុះបណ្តាលជំនាញបច្ចេកទេសវិទ្យាសាស្ត្រ និងឧបករណ៍បច្ចេកទេសក្នុងការបញ្ចូលមុខសញ្ញាទៅក្នុងទិន្នន័យកុំព្យូទ័រ បានជាង១ម៉ឺននាក់ផងដែរ។ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន បានថ្លែងអំណរគុណចំពោះតំណាង FBI លោក John D. Wilson ដែលបានបញ្ចេញស្នាដៃរយៈពេល ២ឆ្នាំ ក្នុងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន FBI និងនគរបាលជាតិកម្ពុជា។

ចំណែកលោក John D. Wilson សេនានុព័ន្ធផ្នែកច្បាប់ FBI សហរដ្ឋអាម៉េរិក បានថ្លែងអំណរគុណដល់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រគល់នូវមេដាយដែលបានបំពាក់នេះ។ លោកមានសេចក្តីរីករាយនឹងការបំពេញកិច្ចសហប្រតិបត្តិការជាមួយនឹងកម្លាំងនគរបាលជាតិកម្ពុជា ដែលលោកបានចាត់ទុកថា ជាកម្លាំងដែលមានជំនាញ និងវិជ្ជាជីវៈត្រឹមត្រូវ។ សេនានុព័ន្ធផ្នែកច្បាប់ FBI សហរដ្ឋអាម៉េរិករំពឹងថា FBI នឹងបន្តកិច្ចសហប្រតិបត្តិការល្អជាមួយនឹងកម្លាំងនគរបាលជាតិកម្ពុជានាពេលអនាគត។ សូមជម្រាបថា មន្ត្រី FBI សហរដ្ឋអាម៉េរិកដែលទទួលបានការបំពាក់មេដាយ គឺលោក John D. Wilson ដែលជាសេនានុព័ន្ធផ្នែកច្បាប់ FBI និងលោក Sean L. Yan សេនានុព័ន្ធរងផ្នែកច្បាប់ FBI ៕

## កម្លាំងជួរមុខកម្ពុជា-ថៃ បានជួបប្រជុំពិភាក្សាគ្នា នៅភូមិសាស្រ្តប៉ុស្តិ៍ព្រំដែនថ្មដូន

http://kampucheathmey.com/ ចាន់ ធី  7/10/2019 9:13 Am

ឧត្តរមានជ័យ ៖ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១០និង៣០នាទី កម្លាំងជួរមុខកម្ពុជា-ថៃ បានប្រជុំពិភាក្សាគ្នា នៅទល់មុខភូមិសាស្រ្តប៉ុស្តិ៍ព្រំដែនថ្មដូន ត្រង់ចំណុចដើមចំបក់ UA(១៩៤២៨-៨៧៣៤១)។ ភាគីកម្ពុជា ចំនួន០៩នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ប៉ោង គាំ នាយប៉ុស្តិ៍ស្ដីទី(ថ្មដូន) វរ:៧០២ និង លោកអនុសេនីយ៍ត្រី ឡេង ឡូន មេបញ្ជាការកងអនុសេនាធំលេខ២ សឹករងក្រុងសំរោង ។ ភាគីថៃ ចំនួន០៩នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ផាន់ថាក់ណាន់ ធៃង៉ាម មេបញ្ជាការកងអនុសេនាធំ ២៦០៥ វរសេនាធំ ២៦ ឈុតខ្មៅ និង លោក អនុសេនីយ៍ឯក ណាត់តាប៉ុង ស៊ិលិតានុន មេបញ្ជាការកងអនុសេនាធំលេខ១ នៃវរសេនាតូចលេខ២២ ប៉ាវ៉ា។ ជាមួយគ្នានោះដែរ ភាគីកម្ពុជា សំណូមពរ បើមានប្រជាពលរដ្ឋដើរច្រូតស្បូវ ឬ ដកផ្សិតវង្វេងចូលក្នុងទឹកដីថៃ សុំកុំមានការធ្វើបាប និងធ្វើទារុណកម្មផ្សេងៗ សុំចាប់បញ្ជូនមកតាមច្រកដែលវង្វេងនោះវិញ ភាគីថៃ ឯកភាព៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/ General Department of Immigration – GDI  October 4 at 5:10 PM •

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០២នាក់ នាវេលាម៉ោង ១៦និង៥៥នាទី ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកខេត្តសាមុត្រប្រាកាន ដើម្បីចូលរួមក្នុងកម្មវិធី "សមត្ថភាពរបស់ពលករចំណាកស្រុក

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 06-10-2019

ថ្ងៃអាទិត្យ ៨កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៩ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកខេត្តសាមុត្រប្រាកាន ដើម្បីចូលរួមក្នុងកម្មវិធី "សមត្ថភាពរបស់ពលករចំណាកស្រុក៖ ការកសាងនិងពង្រឹងសមត្ថភាពក្រុមពលករខ្មែរជួយខ្លួនឯង នៅខេត្តសាមុតប្រាកាន និងខេត្តត្រាត។ កម្មវិធីនេះរៀបចំឡើង ក្នុងគោលបំណងបង្កើនចំណេះដឹងពាក់ព័ន្ធផ្នែកច្បាប់ការងារ សិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ ដល់បងប្អូនពលករខ្មែរមកពីខេត្តសាមុតប្រាកាន និងត្រាត ដើម្បីអាចឱ្យបងប្អូនអាចមានលទ្ធភាពជួយខ្លួនឯងបាន នាពេលពួកគាត់បញ្ហាផ្សេងៗនៅកន្លែងធ្វើការ និងការរស់នៅប្រចាំថ្ងៃនៅក្នុងប្រទេសថៃ។

# ថ្ងៃទី ០៨ ខែ តុលា  ឆ្នាំ២០១៩

## ក្រសួងសង្គមកិច្ច និងអង្គការ ២ ចុះកិច្ចព្រមព្រៀងជួយជនរងគ្រោះពីអំពើជួញដូរមនុស្ស

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 07 October 2019 | 09:48 ICT

**ភ្នំពេញ:** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកាលពីថ្ងៃសុក្រសប្ដាហ៍មុនបានចុះកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការដៃកម្ពុជា (ARM Cambodia) និងមូលនិធិអេ ២១ (A២១) ដើម្បីជួយក្នុងវិស័យ

សង្គមកិច្ចដោយផ្តោតសំខាន់លើការការពារជនរងគ្រោះពីការជួញដូរមនុស្ស ករណីកេងប្រវ័ញ្ចលើកុមារ ការរំលោភបំពានផ្លូវភេទ ការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្មកុមារជាដើម។

លោក តូច ចាន់នី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស និងជាអ្នកនាំពាក្យ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានប្រាប់ភ្នំពេញ-ប៉ុស្ដិ៍ពីម្សិលមិញថា ការចុះកិច្ចព្រមព្រៀងរវាងក្រសួងសង្គមកិច្ច និងអង្គការទាំង ២ ខាងលើ ព្រោះអង្គការនេះជាអង្គការដែលបានចូលរួមចំណែកជួយការពារជនរងគ្រោះពីការជួញដូរមនុស្ស ករណីកេងប្រវ័ញ្ចលើកុមារ ការរំលោភបំពានផ្លូវភេទ ការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្ម។ លោកថ្លែងថា៖ «អង្គការដៃកម្ពុជាមានមណ្ឌលជួយថែទាំជនរងគ្រោះនៅក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង។ ដូច្នេះកុមារដែលរងគ្រោះដោយការជួញដូរ ឬការរំលោភបំពានផ្សេងៗត្រូវបានអង្គការនេះយកមកផ្ដល់សេវាថែទាំ និងស្តារនីតិសម្បទាដល់ជនរងគ្រោះឡើងវិញ។ ក្រោយជនរងគ្រោះសះស្បើយពីភាពទ្រុឌទ្រោមដោយការរំលោភបំពាន យើងនឹងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ពួកគាត់ទើបបញ្ជូនពួកគាត់ទៅកាន់គ្រួសារវិញ»។

លោក តូច ចាន់នី បន្ថែមថាក្រសួងសង្គមកិច្ចនៅតែស្វាគមន៍ជានិច្ចជាមួយដៃគូពាក់ព័ន្ធ និងអង្គការនានាដើម្បីជួយដល់ជនរងគ្រោះនៅកម្ពុជាឲ្យមានជីវភាព និងជីវិតរស់នៅបានល្អប្រសើរថែមមួយកម្រិតទៀត។ លោកបន្តថា ការចូលរួមសហការរបស់អង្គការដៃគូ ពិតជាសំខាន់ណាស់ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចនៅកម្ពុជា។ លោកឱ្យដឹងថា កិច្ចព្រមព្រៀងជាមួយអង្គការដៃកម្ពុជា អង្គការនឹងប្រើប្រាស់ថវិកា ៣៧៦០៨១៦ ដុល្លារសហរដ្ឋអាមេរិកសម្រាប់គម្រោងរយៈពេល៣ឆ្នាំ គិតពីឆ្នាំ ២០១៩ នេះតទៅលើសុខុមាលភាព និងការថែទាំកុមាររីងគ្រោះ។ អគ្គនាយករូបនេះបញ្ជាក់ថា រាល់អង្គការដៃគូទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង សូមធ្វើប្រតិបត្តិការទៅតាមលក្ខខណ្ឌធ្វើតែកិច្ចការការងារសង្គមតែប៉ុណ្ណោះ មិនត្រូវធ្វើការងារនយោបាយឡើយ។ ប្រសិនបើក្រសួងរកឃើញថា អង្គការណាមួយមិនបានគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងបែរជាយកការងារសង្គមមកធ្វើជាការងារនយោបាយ ក្រសួងនឹងបញ្ចប់កិច្ចព្រមព្រៀងភ្លាមហើយឈានដល់បញ្ឈប់សកម្មភាព។

លោកស្រី សាត ធារ៉ា ប្រធានប្រចាំប្រទេសរបស់អង្គការដៃកម្ពុជា (ARM Cambodia) ថ្លែងពីម្សិលមិញថា អង្គការដៃកម្ពុជាមានមណ្ឌលដែលជាផ្ទះសុវត្ថិភាពសម្រាប់ថែទាំកុមារីមានការបណ្តុះបណ្តាលជំនាញ និងការបណ្តុះបណ្តាលជំនាញភាសាអង់គ្លេសដល់កុមារីផងដែរ។ លោកស្រីបានថ្លែងថា៖ «ពួកខ្ញុំជួយតែកុមារីដែលរងគ្រោះដោយការជួញដូរ។ បច្ចុប្បន្នយើងមានមណ្ឌលថែទាំនៅខេត្តសៀមរាប និងបាត់ដំបង។ ប៉ុន្តែកិច្ចសហប្រតិបត្តិការជាមួយក្រសួងរយៈពេល ៣ ឆ្នាំនេះ យើងនឹងជួយកុមារីរងគ្រោះទូទាំងប្រទេសកម្ពុជា»។ លោកស្រីបញ្ជាក់ថា អង្គការដៃកម្ពុជានឹងជួយកុមារីរងគ្រោះមានអាយុចាប់ពី ៤ ឆ្នាំដល់អាយុ ១៨ ឆ្នាំដោយទទួលយកពួកគេពីក្រសួងទៅថែទាំនៅមណ្ឌលក្នុងទីតាំងខេត្តទាំង ២ ខាងលើ។ លោកស្រី ធារ៉ា មើលឃើញថាស្ថានភាពនៃការរំលោភបំពានផ្លូវភេទ និងពលកម្មលើកុមារីនាពេលបច្ចុប្បន្នមានការថយចុះ ព្រោះពលរដ្ឋមានការយល់ដឹងច្រើនជាងមុន។ ប៉ុន្តែលោកស្រីមិនទាន់អាចបញ្ជាក់ពីទិន្នន័យនៃចំនួនកុមារីដែលរងការរំលោភបំពានបានទេពីម្សិលមិញ ព្រោះមិនមានទិន្នន័យនៅក្នុងដៃ។

កញ្ញា ហម ណែត មន្ត្រីសង្គមកិច្ចនៃអង្គការមូលនិធិ អេ ២១ (Case Worker A21) បានថ្លែងពីម្សិលមិញដែរថា អង្គការមូលនិធិ អេ ២១ បានធ្វើការផ្តោតសំខាន់លើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ ពិសេសការជួញដូរកុមារ និងរំលោភពលកម្មកុមារទៅក្រៅប្រទេសជាដើម។ កញ្ញាបន្តថា៖ «អង្គការរបស់យើងនឹងធ្វើការងារស្នូលដោយសហការជាមួយមណ្ឌលសំចត និងមន្ទីរសង្គមកិច្ចនៅក្នុងខេត្តប៉ៃលិនក្នុងការផ្តល់ជំនួយឧបត្ថម្ភដល់កុមារដែលរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចពលកម្មតាមរយៈការឧបត្ថម្ភថវិកា សម្លៀកបំពាក់ និងការព្យាបាលផ្នែកផ្លូវចិត្តដល់ជនរងគ្រោះជាដើមរហូតដល់ជាសះស្បើយ ទើបយើងបន្ថែមការបណ្តុះបណ្តាលវិជ្ជា

ជីវៈដល់ជនរងគ្រោះថែមទៀត»។ កញ្ញា ហម ណែត បញ្ជាក់ថា តាមរយៈកិច្ចសហការជាមួយក្រសួងសង្គមកិច្ចនាពេលកន្លងមក អង្គការមូលនិធិ អេ ២១ បានជួយកុមារា និងកុមារី ជាង ២០ នាក់ពីប្រទេសថៃដែលត្រូវបានគេរំលោភពលកម្មដោយយកទៅឱ្យធ្វើជាអ្នកសុំទាន ត្រឡប់មកកម្ពុជាវិញ និងថែទាំពួកគេ។ កញ្ញាបន្តថា តាមរយៈកិច្ចព្រមព្រៀងរយៈពេល ៣ ឆ្នាំ ជាមួយក្រសួងសង្គមកិច្ច អង្គការមូលនិធិ អេ ២១ នឹងប្រើប្រាស់ថវិកាចំនួន ៦៦៦ ០១៦ ដុល្លារអាមេរិក៕

## សង្គមស៊ីវិល៖ ពលរដ្ឋខ្មែរក្រីក្រ នឹងចំណាកស្រុកច្រើន ដោយសារជនបរទេសដណ្តើមមុខរបរតូចតាច

https://thmeythmey.com/ 07, Oct 2019 , 5:30 pm

ភ្នំពេញ៖ ពលរដ្ឋខ្មែរក្រីក្រ នឹងចំណាកស្រុកច្រើន ដោយសារជនបរទេសដណ្តើមមុខរបរតូចតាច។ នេះជាការលើកឡើងរបស់មន្ត្រីសង្គមស៊ីវិល ដែលមើលឃើញបញ្ហានេះ ស្របពេលដែលរដ្ឋាភិបាល ផ្តល់សិទ្ធិអនុញ្ញាតឱ្យជនបរទេសប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធឬស្វ័យនិយោជន៍ គ្រប់ប្រភេទឡើងវិញនៅកម្ពុជា។

លោក វ៉ន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ យល់ឃើញថា ការសម្រេចរបស់រដ្ឋាភិបាល ក្នុងការអនុញ្ញាតឱ្យជនបរទេសអាចប្រកបរបររកស៊ីតូចតាចដូចពលរដ្ឋខ្មែរដែរនោះ វាជារឿងមិនត្រឹមត្រូវនោះទេ។ សម្រាប់លោក វ៉ន់ ពៅ ការផ្តល់សិទ្ធិរកស៊ីដល់ជនបរទេសបែបនេះ វាហាក់ដូចជាអនុញ្ញាតឱ្យពួកគេដណ្តើមការងារពីពលរដ្ឋខ្មែរ ដែលធ្វើឱ្យពលរដ្ឋខ្លួនឯង បាត់បង់មុខរបរ ប្រាក់ចំណូល និងបាត់បង់អតិថិជន ហើយនាំឱ្យធ្លាក់ចូលក្នុងភាពក្រីក្រ ដែលឈានទៅបង្ខំចិត្តចំណាកស្រុកខុសច្បាប់កាន់តែច្រើនផងដែរ។ ថ្លែងប្រាប់សារព័ត៌មានថ្មីៗ លោក វ៉ន់ ពៅ បាននិយាយដូច្នេះថា ៖«មុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំងនេះដែលរដ្ឋាភិបាលយើងបើកឱ្យជនបរទេសធ្វើនេះ គឺមិនចាំបាច់ទាមទារជំនាញមួយច្បាស់លាស់ឡើយ មានន័យថាពលរដ្ឋខ្មែរយើងអាចធ្វើបាន ហើយពួកគាត់ធ្លាប់ធ្វើតាំងពីដើមមកម្លេះ»។

ត្រង់ចំណុចនេះ លោក យុន ផារ៉ូ អ្នកសម្របសម្រួលមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ (CENTRAL) បាននិយាយថា ក្រសួងការងារគួរតែពិនិត្យ និងពិចារណាឱ្យច្បាស់ឡើងវិញ ចំពោះការផ្តល់សិទ្ធិឱ្យបរទេសប្រកបរបរតូចតាចដូចពលរដ្ឋខ្មែរនេះ។ «យើងត្រូវកំណត់ក្នុងក្រមខណ្ឌណាមួយ ដែលប្រជាប្រពលរដ្ឋខ្មែរអនុវត្តមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលអាចធ្វើបាន ហើយមិនចាំបាច់ដោះដូរកម្លាំងពលកម្មជាមួយបរទេសនោះទេ។ រឿងដែលសំខាន់នោះ រដ្ឋាភិបាល គួរតែគិតអំពីជនបរទេសដែលធ្វើអនុវត្តការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យស្ថិតនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធវិញ ព្រោះវាកម្លាំងដែលសំខាន់ ឱ្យពួកគាត់មានការគាំពារផ្នែកច្បាប់ មានការគាំពារផ្នែករបរការពារសង្គម ផ្នែកបេឡាជាតិជាដើម។ ទាំងនេះបានរឿងអទិភាពដែលយើងត្រូវធ្វើ។ នេះបើតាមលោក យុន ផារ៉ូ។

ទាំងលោក វ៉ន់ ពៅ និងលោក យុន ផារ៉ូ សុទ្ធតែអះអាងថា កន្លងមកជនបរទេសបានដណ្តើមការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធពីពលរដ្ឋខ្មែរច្រើនណាស់មកហើយ ជាពិសេសផ្នែកសេវាកម្ម រួមទាំងអាជីវកម្មរកស៊ីទ្រង់ទ្រាយតូច រហូតដល់ទ្រង់ទ្រាយធំ ភាគច្រើនជាជនជាតិវៀតណាម និងចិនជាដើម នៅក្នុងខេត្តព្រះសីហនុ សៀមរាប និងភ្នំពេញ។

សារព័ត៌មានថ្មីៗ មិនអាចទាក់ទងលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសុំការអត្ថាធិប្បាយបន្ថែម ជុំវិញការអនុញ្ញាតឱ្យជនបរទេសអាចប្រកបរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬស្វ័យនិយោជន៍គ្រប់ប្រភេទឡើងវិញនៅកម្ពុជាឡើយ។

កាលពីថ្ងៃទី៦ តុលា ក្រសួងការងារបានសេចក្តីជូនដំណឹងជាសាធារណៈនៃការអនុញ្ញាតឱ្យជនបរទេសធ្វើការនិងប្រកបមុខរបរចំនួន១០ប្រភេទនៅកម្ពុជា ក្រោមមូលហេតុកម្ពុជាត្រូវការកម្លាំងពលកម្មជំនាញនៃជនបរទេសក្នុងវិស័យ

សេវាកម្ម និងដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងប្រទេសកម្ពុជា។ មុខរបរទាំង១០ប្រភេទនោះមាន ការងារជាអ្នកបើកបរយានជំនិះគ្រប់ប្រភេទ ជាលក្ខណៈអាជីវកម្ម ការលក់ដូរដោយមធ្យោបាយថ្មើរជើង ឬយានជំនិះគ្រប់ប្រភេទ ម៉ាស្សា និងចាប់សសៃតាមសាធារណៈ កាត់សក់ អ៊ុតសក់ ថែរក្សាសម្ផស្ស សេវាកម្មដេរ និងសម្អាតស្បែកជើង ប៉ះកង់ ជួសជុលយានយន្ត កាត់ដេរ ផលិតវត្ថុអនុស្សាវរីយ៍ខ្មែរ ផលិតឧបករណ៍ភ្លេងខ្មែរ ផលិតបាត្រលោក ព្រះពុទ្ធរូប និងជាងទង និងជាងច្នៃត្បូងពេជ្រ។ ប៉ុន្តែការសម្រេចឱ្យជនបរទេសប្រកបរបរតូចតាច ក្រោមហេតុផលត្រូវការកម្លាំងជំនាញនេះ ត្រូវបានសង្គមស៊ីវិល ចាត់ទុកថា ជាហេតុផលមិនសមរម្យ។ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធរូបនេះ បានសង្កត់ធ្ងន់ថា មុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំង១០ប្រភេទខាងលើនេះ វាមិនចាំបាច់ត្រូវការអ្នកជំនាញជាជនបរទេសឡើយ។

បើតាមលោក វន់ ពៅ អ្នកជំនាញជនបរទេសដែលកម្ពុជាត្រូវការនោះ គឺជំនាញក្នុងវិស័យរោងចក្រ សហគ្រាសកាត់ដេរ រោងចក្រដំឡើងរថយន្ត-ម៉ូតូ...និងរោងចក្រធំៗ ជាដើម...។ «ត្រឹមមុខរបរត់ម៉ូតូឌុប តាក់ស៊ី ជាងកាត់សក់ អ្នកតុបតែងមុខ ម៉ាស្សា និងអ្នកលក់ចំណីចល័តតាមផ្លូវជាដើម គឺវាមិនចាំបាច់មានជនបរទេសជំនាញមកធ្វើការងារទាំងអស់ហ្នឹងទេ»។ នេះជាការបញ្ជាក់របស់លោក វន់ ពៅ៕

## ក្រុមអង្គការ៥១ ខកចិត្តចំពោះរាជរដ្ឋាភិបាល អនុញ្ញាតឲ្យជនបរទេស ប្រកបមុខរបរនៅកម្ពុជាឡើងវិញ

https://www.dap-news.com/ ByID:114VT Posted on 07 October 2019 | 14:59

ភ្នំពេញ ៖ ក្រុមសហជីព សមាគម និងអង្គការសង្គមស៊ីវិលចំនួន៥១ នៅកម្ពុជាបានសម្តែងការខកចិត្ត ចំពោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល អនុញ្ញាតឲ្យជនបរទេស ប្រកបការងារនៅកម្ពុជាឡើងវិញ។ ក្រសួងការងារ បានឲ្យជនបរទេសប្រកបការងារ នៅកម្ពុជាវិញ កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩ បន្ទាប់ពីបានហាម កាលពីថ្ងៃទី២៨ សីហា ។ សេចក្តីថ្លែងការណ៍ របស់ក្រុមអង្គការនៅថ្ងៃទី៧ តុលា បានឲ្យដឹងថា "យើងខ្ញុំជាសហជីព សមាគម និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការជាមួយកម្មករក្នុងប្រព័ន្ធ ប្រជាពលរដ្ឋកម្ពុជា ពិសេសកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬកម្មករស្វ័យនិយោជន៍ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស មុខរបរ និងជីវភាពរស់នៅ របស់បងប្អូនកម្មករ កម្មការិនី និងប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា មានការខកចិត្តយ៉ាងខ្លាំង ដែលបានឃើញក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអនុញ្ញាតឡើងវិញនៃសកម្មភាពស្វ័យនិយោជន៍ដោយជនបរទេស" ។

ពួកគេយល់ឃើញថា ការអនុញ្ញាតឲ្យជនបរទេស ធ្វើការវិញនៅកម្ពុជា គឺដណ្តើមមុខរបររបស់កម្មករ និងប្រជាពលរដ្ឋខ្មែរ ព្រោះនឹងប្រឈមការបាត់បង់ប្រាក់ចំណូល បាត់បង់អតិថិជន បាត់បង់មុខរបរ និងធ្វើឲ្យជីវភាព កាន់តែលំបាកដុនដាប ហើយត្រូវបង្ខំចិត្តចំណាកស្រុក ទៅរកការងារធ្វើនៅក្រៅប្រទេស។ កន្លងមកសហជីព សមាគម និងអង្គការសង្គមស៊ីវិលសារទរ ចំពោះការកំណត់ប្រភេទមុខរបរ និងការងារដែរ ត្រូវហាមឃាត់ចំពោះជនបរទេស ដោយក្រសួងជានាបាន នូវការលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋកម្ពុជា ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ទៅតាមជំនាញរបស់ខ្លួន ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬ កម្មករស្វ័យនិយោជន៍ ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 08-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៥នាក់ នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥

នាក់នេះ មានស្រុកកំណើតនៅខេត្តបាត់ដំបង ០១នាក់, ខេត្តឧត្តរមានជ័យ ០២នាក់ ស្រី ០១នាក់ និងខេត្តពោធិ៍សាត់ ០២នាក់ ស្រី ០១នាក់៕

## ឈឺចិត្តណាស់! នារីជាអ្នកបម្រើចំណាកស្រុកម្នាក់ រៀបរាប់ទាំងទឹកភ្នែក ក្រោយរងការធ្វើបាបពីថៅហ្វាយនាយ ឱ្យហូបបាយមួយថ្ងៃតែមួយដងគត់

https://www.khmerload.com/news/ ពៅ, Khmerload 13:31 October 08, 2019

សិង្ហបុរី៖ នារីជាអ្នកបម្រើចំណាកស្រុកជនជាតិឥណ្ឌូនេស៊ីម្នាក់ បានរៀបរាប់ទាំងទឹកភ្នែក ពោរពេញដោយការឈឺចាប់ ក្រោយរងការធ្វើបាបពីសំណាក់ថៅហ្វាយនាយ ឲ្យហូបបាយក្នុងមួយថ្ងៃតែមួយដងគត់ រួមទាំងការប្រើប្រាស់ហិង្សា និងពាក្យសម្តីមិនសមរម្យជាច្រើនផ្សេងទៀតមកលើនាង។ បើតាមប្រភពបានឲ្យដឹងថា នារីជាអ្នកបម្រើខាងលើនេះ ត្រូវបានគេស្គាល់ឈ្មោះថា Castina បានចាកចេញពីស្រុកកំណើតខ្លួន ក្នុងតំបន់ Indramayu ខេត្ត West Java ប្រទេសឥណ្ឌូនេស៊ី ដើម្បីមកធ្វើការងារជាអ្នកបម្រើតាមផ្ទះ (ឬស្ថាប័នក្រុមហ៊ុន) នៅក្នុងប្រទេសសិង្ហបុរី។ ប៉ុន្តែអ្វីដែលមិននឹកស្មានដល់នោះ នាងបានជួបនូវរឿងរ៉ាវអាក្រក់ ក៏ដូចជាទុក្ខសោកក្រៀមក្រំជាច្រើន ដោយសារតែ នាងត្រូវបានរងការធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្ត ពីសំណាក់ថៅហ្វាយនាយ។

ជាក់ស្តែង បើផ្អែកតាមរយៈវីដេអូឃ្លីបមួយ ដែលត្រូវបានថត និងបង្ហោះចែកចាយនៅលើបណ្តាញសង្គម ដោយនារីមិនបញ្ចេញអត្តសញ្ញាណម្នាក់ កាលពីថ្ងៃសុក្រសប្តាហ៍មុននេះ ជុំវិញនឹងការសាកសួរខ្លះៗទៅកាន់នារីរងគ្រោះ គឺនាង Castina បានរៀបរាប់ទាំងទឹកភ្នែករលីងរលោងថា ក្នុងមួយថ្ងៃនាងត្រូវបានថៅហ្វាយនាយ ដែលស្នាក់នៅផ្ទះដែលនាងមើលថៃ អនុញ្ញាតផ្តល់អាហារឲ្យទទួលទានតែ១ដងប៉ុណ្ណោះ ហើយនាងក៏តែងតែទទួលរងនូវការជេរប្រមាថ ស្តីបន្ទោសឥតស្រាកស្រាន្ត ប្រសិនបើនាងហ៊ានតែស្នើសុំបន្ថែមទៀត (អាហារ)។ លើសពីនេះ នាងថែមទាំងត្រូវបានថៅហ្វាយនាយ ប្រោះទឹក ឬជះទឹកដាក់ជារឿយៗ ប្រសិនណាបើនាង ហ៊ានតែងើបមិនទាន់នៅត្រឹមម៉ោង ៥ព្រឹក ដើម្បីធ្វើការងារ។ ប៉ុន្តែបើទោះបីជាយ៉ាងណាក្តី ចំណុចនេះ Castina ថា វាមិនសូវជាធ្ងន់ធ្ងរខ្លាំងសម្រាប់នាងនោះឡើយ។ នារីរងគ្រោះ នាង Castina បានឲ្យដឹងទៀតថា គេថែមទាំងមិនអនុញ្ញាតឲ្យនាងទាក់ទងទៅកាន់ក្រុមគ្រួសាររបស់នាង ដែលរស់នៅឯប្រទេសឥណ្ឌូនេស៊ីនោះឡើយ។ នាងតែងតែនៅក្នុងផ្ទះ ដូចអ្នកជាប់ឃុំយ៉ាងអីចឹង ចាប់តាំងពីនាងបានមកធ្វើការនៅទីនេះ។ ដោយសារតែ ភាពភ័យខ្លាច និងអស់សង្ឃឹម Castina ក៏បាននិយាយដែរថា នាងចង់ឲ្យមានការផ្លាស់ប្តូរនិយោជក (ឬថៅហ្វាយនាយ) ដែលស្នាក់នៅ និងគ្រប់គ្រងលើនាង ព្រោះបើមិនដូច្នេះទេ គេអាចនឹងកាន់តែគំរាមកំហែង ធ្វើបាបលើនាងកាន់តែខ្លាំងទៀតជាក់ជាមិនខាន។

គួរឲ្យដឹងផងដែរថា ជុំវិញនឹងករណីខាងលើនេះ នារីដែលជាអ្នកថតវីដេអូសាកសួរជាមួយនឹងនាង Castina ក៏បានប្រាប់នាងឲ្យមានការអត់ធ្មត់ចំពោះរឿងមួយនេះ ហើយនាងក៏បានសន្យាថា នាងនឹងរាយការណ៍ពីស្ថានភាពនេះ ទៅកាន់ក្រសួងការងារក្នុងតំបន់ (Ministry of Manpower ឬហៅកាត់ថា "MOM") ដើម្បីជួយរកយុត្តិធម៌ឲ្យនាង និងសិទ្ធិត្រឹមត្រូវក្នុងនាមជាអ្នកបម្រើនេះផងដែរ។ យ៉ាងណាមិញ បន្ទាប់ពីវីដេអូឃ្លីបមួយនេះ ត្រូវបានសាយភាយខ្លាំងនៅលើបណ្តាញសង្គម បងប្អូនប្រុសរបស់នារីរងគ្រោះ នាង Castina ក៏បានឃើញ និងបានប្រកាសសុំឲ្យអ្នកលេងបណ្តាញសង្គមហ្វេសប៊ុកទាំងអស់ មេត្តាអាណិត និងជួយសង្គ្រោះដល់នាងផងដែរ។

អ្នកលេងបណ្តាញសង្គមជាច្រើន ក៏បានសម្តែងការខឹងសម្បាយ៉ាងខ្លាំង ទៅលើថៅហ្វាយនាយដែលបានប្រព្រឹត្តទង្វើមិនគប្បីមកលើអ្នកបម្រើខ្លួនទាំងបែបនេះ ហើយពួកគេក៏បានជំរុញសុំឲ្យខាង "MOM" ជួយចាត់ការលើរឿងមួយនេះឲ្យបានឆាប់ៗផងដែរ។ យោងតាមប្រភពច្បាស់ការណ៍មួយបានឲ្យដឹងថា ក្រោយរងការរិះគន់ កាលពីម្សិលម៉្ងៃនេះ (ថ្ងៃទី៦ តុលា) ខាង "MOM" ក៏បានធ្វើសេចក្តីប្រកាសមួយ នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួន

ដោយបាននិយាយថា បច្ចុប្បន្នពួកគេកំពុងតែធ្វើការស៊ើបអង្កេតលើករណីនេះ ខណៈឯនារីរងគ្រោះនាង Castina វិញ ក៏ត្រូវបានបញ្ជូនទៅស្ថានទូតឥណ្ឌូនេស៊ី ដើម្បីធានាសុវត្ថិភាពដល់រូបនាងផងដែរ។

## ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៩

## ឯកឧត្តមបណ្ឌិត អ៊ិត សំហេង អនុញ្ញាត ឱ្យប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ចូលជួបសម្តែងការគួរសម

http://www.mlvt.gov.kh/ Wednesday, 09 October 2019 17:04 Written by MLVT

(ភ្នំពេញ)៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុញ្ញាតឱ្យលោកស្រីវេជ្ជបណ្ឌិត ណិនណេត ម៉ូទូស (Nentte MOTUS) ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដើម្បីសម្តែងការគួរសម ក្នុងឱកាសបំពេញទស្សនកិច្ចនៅកម្ពុជា របស់លោកស្រីវេជ្ជបណ្ឌិត ដើម្បីពិភាក្សាការងារដែល IOM កំពុងអនុវត្តនៅកម្ពុជា និងក្នុងតំបន់ និងផែនការសម្រាប់កិច្ចសហការ នាពេលអនាគតរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការ IOM នារសៀលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង។ ឯកឧត្តមរដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ចំពោះ អង្គការ IOM ដែលបានជួយខាងផ្នែក ពលករទេសន្តរប្រវេសន៍ នៅក្នុងប្រទេសនានា ក៏ដូចជានៅក្នុងតំបន់។ កម្ពុជាទទួលបានផ្លែផ្កានៃកិច្ចសហប្រតិបត្តិការនេះយ៉ាងធំធេងផងដែរ មកដល់ពេលនេះ គោលនយោបាយ ទេសន្តរប្រវេសន៍ ពិតជាទទួលបានជោគជ័យ។ ភាពជោគជ័យនេះ គឺមិនអាចខ្វះបានពីការរួមចំណែកផ្នែកគាំទ្របច្ចេកទេស ពីសំណាក់អង្គការIOM។ យើងបានចាប់ផ្តើមទាំងការលំបាក ឥលូវអាចនិយាយបានថាពលករដែលធ្វើការនៅក្រៅប្រទេស សុវត្ថិភាព ស្របច្បាប់ ស្ទើរ១០០ភាគរយ។ នោះក្នុងពលករកម្ពុជាចេញទៅធ្វើការនៅក្រៅ ១លាន២សែននាក់ យើងបានថែទាំ និងតាមគាំពារពួកគេជាប់ជានិច្ច។ និយាយដូច្នេះ មិនមែនយើងមិនមានបញ្ហាប្រឈមនោះទេ បញ្ហាប្រឈមនានា នៅតែមាន តែយើងនឹងបន្តសហការជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាអស់ទាំងនេះ។ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា៖«កម្ពុជាយើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីបញ្ហាទេសន្តរប្រវេសន៍នេះ តាំងពីដំបូង ដែលជួបការលំបាកខ្លាំង ។ មកដល់បច្ចុប្បន្ន ការងារនេះបានក្លាយជា កាលានុវត្តភាពទៅវិញ។ ឧទាហរណ៍៖ពលករនៅថៃជាង១លាននាក់កំពុងធ្វើការនៅទីនោះ(ទាំងស្របច្បាប់ ឬមិនស្របច្បាប់) ប៉ុន្តែយើងបានធ្វើការងារនេះជាប្រព័ន្ធ ដោយមានការចូលរួមពីភាគីថៃ រហូតដល់ធ្វើឲ្យពលករខ្មែរ ក្លាយជាពលករស្របច្បាប់ផងដែរ។ ឯកឧត្តមបានបន្ថែមថា កម្ពុជាបានកំពុងគិតពីបញ្ហាពលករនេះ យ៉ាងខ្លាំង និងបានស្នើឲ្យIOM បន្តធ្វើការងារទាក់ទងនិងពលករទេសន្តប្រទេសន៍នេះ ពិសេសនោះជួយលើបញ្ហាចល័តភាពនៃរបបសន្តិសុខសង្គម ឲ្យកាន់តែប្រសើរថែមទៀត។

នៅក្នុងជំនួបនេះដែរ លោកស្រី Nentte MOTUS ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក បានលើកឡើងពីការងារមួយចំនួនទាក់ទងនឹងបញ្ហាកិច្ចប្រតិបត្តិការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិសេសជាមួយអង្គការ IOM និងជាមួយបណ្តាប្រទេសផ្សេងៗទៀត។ លោកស្រីក៏បានលើកឡើង ពីគោលដៅអាទិភាពនៅក្នុងឆ្នាំ២០៣០ និងលើកពីទំនាក់ទំនងទេសន្តរប្រវេសន៍ ពាក់ព័ន្ធនឹងពលករ និងការគ្រប់គ្រងពលករ រហូតដល់ពីទំនាក់ទំនងគ្រួសាររបស់ពលករផងដែរ។ ភាគីIOM ក៏បានឯកភាព បន្តជួយការងារ ពាក់ព័ន្ធពលករទេសន្តរប្រវេសន៍នេះ ដូចជា ជួយបណ្តុះបណ្តាលជំនាញដល់ពលករ និងស្វែងរកការងារដល់ពួកគេថែមទៀត ៕

## អគ្គស្នងការដ្ឋាននគរបាលជាតិ ពិនិត្យលទ្ធផល និងជំរុញសកម្មភាពការអនុវត្តការងារកិច្ចការពារកុមារ នៅស្នងការដ្ឋានខេត្តកណ្ដាល

http://www.freshnewsasia.com/ 2019-10-09

**(កណ្ដាល)៖** លោកឧត្ដមសេនីយ៍ឯក អ៊ឹង សំអុល ប្រធាននាយកដ្ឋានកិច្ចការប៉ុស្ដិ៍នគរបាលរដ្ឋបាល នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងលោកឧត្ដមសេនីយ៍ទោ អ៊ាវ ចំរើន ស្នងការនគរបាលខេត្តកណ្ដាល បានអញ្ជើញចូលរួមបើកកិច្ចប្រជុំស្ដីពី ការត្រូវបានពិនិត្យលទ្ធផល និងជំរុញសកម្មភាពការអនុវត្តការងារកិច្ចការពារកុមារនៅស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

លោកឧត្ដមសេនីយ៍ទោ អ៊ាវ ចំរើន បានបញ្ជាក់ថា នគរបាលនឹងខិតខំបន្ថែមទៀត លើការងារកិច្ចការពារកុមារនេះព្រោះថា ក្នុងរយៈពេល ០៩ខែ ឆ្នាំ២០១៩ នេះបញ្ហារបស់កុមារនៅមូលដ្ឋាន ក្នុងខេត្តកណ្ដាល នៅតែជាបញ្ហាដែលជាក្ដីបារម្ភណ៍។ ក្នុងនាមយើងជានគរបាល យើងត្រូវតែបន្ត សហការជាមួយក្រុមគ្រួសារ, អាជ្ញាធរមូលដ្ឋាន និងអង្គការ សមាគមនានា ដើម្បីឲ្យបញ្ហានេះទទួលបានប្រសិទ្ធភាពល្អឡើងវិញផងដែរ។

លោកស្រីឧត្ដមសេនីយ៍ត្រី ឈឹម វណ្ណី ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល បានបញ្ជាក់ថា ក្នុងរយៈពេល០៩ខែ ឆ្នាំ២០១៩ ក្រុមជនបង្គោលបានធ្វើសកម្មភាពចុះផ្សព្វផ្សាយតាមសាលារៀនបានចំនួន៤៥លើក មានអ្នកចូលរួមចំនួន១៧៥៣នាក់ ប្រុស៧៥៣នាក់, ចុះផ្សព្វផ្សាយតាមខ្នងផ្ទះចំនួន១០៦លើក ប្រជាពលរដ្ឋចូលរួមចំនួន៩៤៤នាក់ ប្រុស៤២០នាក់។ ក្រៅពីនោះ ក្រុមជនបង្គោល បានធ្វើការផ្សព្វផ្សាយដល់មណ្ឌលកុមារកំព្រា បានចំនួន៣មណ្ឌលផងដែរ មានកុមារចំនួន៣៨៥នាក់ ប្រុស១៩៤នាក់។ លោកស្រី បានលើកពីបញ្ហាប្រឈមយ៉ាងដូច្នេះថា កុមារដែលនៅក្រោមស្ពានមិត្តភាពកម្ពុជា-ជប៉ុន សំបូរទៅដោយកុមារហិតការ អង្គការមិត្តសម្លាញ់យកទៅដើម្បីបណ្ដុះបណ្ដាលដែរតែពួកគេមិនព្រមហើយពេលចុះផ្សព្វផ្សាយដល់ខ្នងផ្ទះសាម៉ីខ្លួនមិននៅផ្ទះ ដោយសារគាត់ដើរលេងមិនចូលផ្ទះ រីឯឪពុកម្ដាយ ឬអាណាព្យាបាលខ្លះដែលគ្មានលទ្ធភាពមិនព្រមបញ្ជូនកូនទៅមណ្ឌលទេ មូលហេតុទុកឲ្យកូនដើរសុំទានដើម្បីធ្វើអាជីវកម្ម។ ចំពោះបញ្ហាប្រឈមទាំងនេះការគ្រប់គ្រងរបស់សមត្ថកិច្ច គឺបានត្រឹមតែប្រមូលពួកគេឲ្យទៅសង្គមកិច្ចតែប៉ុណ្ណោះ។

លោកឧត្ដមសេនីយ៍ឯកប្រធាននាយកដ្ឋានកិច្ចការប៉ុស្ដិ៍នគរបាលរដ្ឋបាល នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានណែនាំផ្ដាំផ្ញើដល់កងកម្លាំងនគរបាលទាំងអស់ថា ត្រូវបន្តខិតខំបំពេញភារកិច្ចក្នុង នាមយើងជាកងកម្លាំងនគរបាលជាតិ អ្វីៗដែលយើងមានមក ដល់ពេលនេះយើងត្រូវតែបន្តថែរក្សាឲ្យបានល្អ ជាពិសេសសុខសន្តិភាព និងការអភិវឌ្ឍន៍ប្រទេសជាតិ ដែលសមិទ្ធិផលទាំងអស់នេះ គឺបានមកដោយការលះបង់គ្រប់ បែបយ៉ាងរបស់ប្រមុខដឹកនាំរបស់យើង គឺសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំជាឥស្សរជននយោបាយសំខាន់ៗផ្សេងទៀត ដែលលោកខិតខំពុះពារការលំបាក ឧបសគ្គគ្រប់បែបយ៉ាងចាប់តាំងពីចំណុចសូន្យ រហូតមកដល់ពេលនេះ គឺមិនអាចឲ្យជនណាមួយឬក្រុមណាមួយមកបំផ្លិចបំផ្លាញបានឡើយ៕

## អង្គការអន្តរជាតិធំមួយ ប្តេជ្ញាបន្តជួយបណ្តុះបណ្តាលជំនាញ និងស្វែងរកការងារដល់ពលករកម្ពុជា

http://www.freshnewsasia.com/ 2019-10-09

**(ភ្នំពេញ)៖** នៅចំពោះមុខលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក លោកស្រី ណិនណេត ម៉ូទូស (Nentte MOTUS) បានឯកភាពបន្តជួយដល់កម្ពុជា ពាក់ព័ន្ធពលករទេសន្តរប្រវេសន៍នេះ ដូចជាជួយបណ្តុះបណ្តាលជំនាញដល់ពលករ និងស្វែងរកការងារ

ដល់ពួកគេថែមទៀត។ ការប្តេជ្ញានេះ ត្រូវបានធ្វើឡើងក្នុងឱកាសលោក អ៊ិត សំហេង បានអនុញ្ញាតឱ្យលោកស្រី ណិនណេត ម៉ូទូស ដើម្បីពិភាក្សាការងារដែល IOM កំពុងអនុវត្តនៅកម្ពុជា និងក្នុងតំបន់ ព្រមទាំងផែនការសម្រាប់កិច្ចសហការ នាពេលអនាគតរវាងក្រសួងការងារ និងអង្គការ IOM នារសៀលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ។

លោករដ្ឋមន្ត្រីបានអះអាងថា កម្ពុជាទទួលបានផ្លែផ្កានៃកិច្ចសហប្រតិបត្តិការនេះ យ៉ាងធំធេងផងដែរ មកដល់ពេលនេះ គោលនយោបាយទេសន្តរប្រវេសន៍ ពិតជាទទួលបានជោគជ័យ។ ភាពជោគជ័យនេះ គឺមិនអាចខ្វះបានពីការរួមចំណែកផ្នែកគាំទ្របច្ចេកទេស ពីសំណាក់អង្គការ IOM។ លោកថា «យើងបានចាប់ផ្តើមទាំងការលំបាក ឥលូវអាចនិយាយបានថាពលករ ដែលធ្វើការនៅក្រៅប្រទេស សុវត្ថិភាព ស្របច្បាប់ស្ទើរ ១០០ភាគរយ នោះក្នុងពលករកម្ពុជាចេញទៅធ្វើការនៅក្រៅ ១លាន២សែននាក់ យើងបានថែទាំ និងតាមគាំពារពួកគេជាប់ជានិច្ច»។ និយាយដូច្នេះ មិនមែនយើងមិនមានបញ្ហាប្រឈមនោះទេ បញ្ហាប្រឈមនានានៅតែមាន តែយើងនឹងបន្តសហការជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាអស់ទាំងនេះ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា កម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង ពីបញ្ហាទេសន្តរប្រវេសន៍នេះតាំងពីដំបូង ដែលជួបការលំបាកខ្លាំង។ មកដល់បច្ចុប្បន្ន ការងារនេះបានក្លាយជា កាលានុវត្តភាពទៅវិញ។ ឧទាហរណ៍៖ ពលករនៅថៃជាង ១លាននាក់ កំពុងធ្វើការនៅទីនោះ (ទាំងស្របច្បាប់ ឬមិនស្របច្បាប់) ប៉ុន្តែកម្ពុជាបានធ្វើការងារនេះជាប្រព័ន្ធ ដោយមានការចូលរួមពីភាគីថៃ រហូតដល់ធ្វើឱ្យពលករខ្មែរ ក្លាយជាពលករស្របច្បាប់ផងដែរ។ លោកបានបន្ថែមថា កម្ពុជាបានកំពុងគិតពីបញ្ហាពលករនេះយ៉ាងខ្លាំង និងបានស្នើឱ្យ IOM បន្តធ្វើការងារទាក់ទងនឹងពលករទេសន្តរប្រវេសន៍ នេះ ពិសេសនោះជួយលើបញ្ហាចល័តភាពនៃរបបសន្តិសុខសង្គមឱ្យកាន់តែប្រសើរថែមទៀត។

លោកស្រីប្រធានអង្គការ IOM បានលើកឡើងពីការងារមួយចំនួនទាក់ទងនឹងបញ្ហាកិច្ចប្រតិបត្តិការរវាងក្រសួងការងារជាមួយអង្គការ IOM និងជាមួយបណ្តាប្រទេសផ្សេងៗទៀត។ លោកស្រីក៏បានលើកឡើងពីគោលដៅអាទិភាពនៅក្នុងឆ្នាំ២០៣០ និងលើកពីទំនាក់ទំនងទេសន្តរប្រវេសន៍ពាក់ព័ន្ធនឹងពលករ និងការគ្រប់គ្រងពលករ រហូតដល់ពីទំនាក់ទំនងគ្រួសាររបស់ពលករផងដែរ។ លោកស្រី ណិនណេត ម៉ូទូស ក៏បានឯកភាពបន្តជួយការងារពាក់ព័ន្ធពលករទេសន្តរប្រវេសន៍នេះ ដូចជាជួយបណ្តុះបណ្តាលជំនាញដល់ពលករ និងស្វែងរកការងារដល់ពួកគេថែមទៀត៕

## ក្រសួងការងារ៖ ពលករធ្វើការក្រៅប្រទេសសុវត្ថិភាពស្របច្បាប់ស្ទើរ ១០០%

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 08:34 ចន្លោះមិនឃើញ

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា ពលករដែល ធ្វើការនៅក្រៅប្រទេស សុវត្ថិភាព ស្របច្បាប់ ស្ទើរ១០០ភាគរយ។ ការលើកឡើងនេះ នៅក្នុងជំនួបពិភាក្សាការងារជាមួយលោកស្រីវេជ្ជបណ្ឌិត ណិនណេត ម៉ូទូស (Nentte MOTUS) ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីពិភាក្សាការងារដែល IOM កំពុងអនុវត្តនៅកម្ពុជា កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង។ លោកបានបន្តថា ក្នុងនោះពលករកម្ពុជាចេញទៅធ្វើការនៅក្រៅ ១លាន២សែននាក់ យើងបានថែទាំ និងតាមគាំពារពួកគេជាប់ជានិច្ច។ លោកបន្តថា បញ្ហាប្រឈមនានា នៅតែមាន តែយើងនឹងបន្តសហការជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាអស់ទាំងនេះ។ លោករដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ចំពោះអង្គការ IOM ដែលបានជួយខាងផ្នែក ពលករទេសន្តរប្រវេសន៍ នៅក្នុងប្រទេសនានា ក៏ដូចជានៅក្នុងតំបន់។ ដែល

ធ្វើឲ្យកម្ពុជាទទួលបានផ្លែផ្កាយ៉ាងធំធេង មកដល់ពេលនេះ គោលនយោបាយ ទេសន្តរប្រវេសន៍ ពិតជាទទួលបានជោគជ័យ។

លោកបានបញ្ជាក់ថា "កម្ពុជាយើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីបញ្ហាទេសន្តរប្រវេសន៍នេះ តាំងពីដំបូងដែលជួបការលំបាកខ្លាំង ។ មកដល់បច្ចុប្បន្ន ការងារនេះបានក្លាយជា កាលានុវត្តភាពទៅវិញ។ ឧទាហរណ៍៖ពលករនៅថៃជាង១លាននាក់កំពុងធ្វើការនៅទីនោះ(ទាំងស្របច្បាប់ ឬមិនស្របច្បាប់) ប៉ុន្តែយើងបានធ្វើការងារនេះជាប្រព័ន្ធ ដោយមានការចូលរួមពីភាគីថៃ រហូតដល់ធ្វើឱ្យពលករខ្មែរ ក្លាយជាពលករស្របច្បាប់ផងដែរ"។ បានបន្ថែមថា កម្ពុជាបានកំពុងគិតពីបញ្ហាពលករនេះ យ៉ាងខ្លាំង និងបានស្នើឱ្យIOM បន្តធ្វើការងារទាក់ទងនិងពលករទេសន្តរប្រវេសន៍ នេះ ពិសេសនោះជួយលើបញ្ហាចល័តភាពនៃរបបសន្តិសុខសង្គម ឱ្យកាន់តែប្រសើរថែមទៀត។

ចំណែកលោកស្រី Nentte MOTUS ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក បានលើកឡើងពីការងារមួយចំនួនទាក់ទងនឹងបញ្ហាកិច្ចប្រតិបត្តិការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិសេសជាមួយអង្គការIOM និងជាមួយបណ្តាប្រទេសផ្សេងៗទៀត។ លោកស្រីក៏បានលើកឡើង ពីគោលដៅអាទិភាពនៅក្នុងឆ្នាំ ២០៣០ និងលើកពីទំនាក់ទំនងទេសន្តរប្រវេសន៍ ពាក់ព័ន្ធនឹងពលករ និងការគ្រប់គ្រងពលករ រហូតដល់ពីទំនាក់ទំនងគ្រួសាររបស់ពលករផងដែរ។ ភាគី IOM ក៏បានឯកភាព បន្តជួយការងារ ពាក់ព័ន្ធពលករទេសន្តរប្រវេសន៍នេះ ដូចជា ជួយបណ្តុះបណ្តាលជំនាញដល់ពលករ និងស្វែងរកការងារដល់ពួកគេថែមទៀត ៕ អត្ថបទ៖ កុសល

## ពលរដ្ឋខ្មែរ៥នាក់ ចាញ់បោកមេខ្យល់ នាំឆ្លងដែនខុសច្បាប់ ចូលប្រទេសថៃ ត្រូវបានឃាត់ខ្លួន និងបញ្ជូនមកខ្មែរវិញ

https://www.dap-news.com/ ByID:112PH Posted on 09 October 2019 | 17:09

ភ្នំពេញ៖ លោក ណុប រដ្ឋា កុងស៊ុល និងលោក យន់ យ៉េន ជំនួយការអគ្គកុងស៊ុល បានចុះជួបមន្ត្រី នគរបាលអន្តោប្រវេសន៍ថៃ ប្រចាំខេត្តសាកែវ ដើម្បីសម្របសម្រួល និង ធ្វើមាតុភូមិនិវត្តន៍ ពលរដ្ឋខ្មែរចំនួន ៥នាក់ វិលត្រលប់ទៅកម្ពុជាវិញ តាមច្រកអន្តរជាតិប៉ោយប៉ែត នៅរសៀលថ្ងៃទី ០៩ តុលា ២០១៩។

ពលរដ្ឋខ្មែរទាំង ៥ នាក់ខាងលើ ត្រូវបានមេខ្យល់នាំឆ្លងដែនខុសច្បាប់ ចូលប្រទេសថៃ កាលពីថ្ងៃទី ៤ ខែតុលា ឆ្នាំ២០១៩ ដើម្បីមកធ្វើការនៅក្នុង ខេត្តក្បែរទីក្រុងបាងកក ។ ប៉ុន្តែត្រូវសមត្ថកិច្ចថៃ ឃាត់ខ្លួនពេលពួកគាត់បានធ្វើដំណើរ មកដល់ភូមិសាស្ត្រ ស្រុកវ៉ាត់ថាណាណាក់ខន ខេត្តសាកែវ រួចអនុវត្តតាមនីតិវិធី ។

មន្ត្រីស្ថានអគ្គកុងស៊ុលបានអប់រំ និងណែនាំដល់បងប្អូនខ្មែរទាំង ៥ នាក់ខាងលើ ថា បើមានបំណងមកធ្វើការនៅប្រទេសថៃ មេត្តាកុំជឿមេខ្យល់ ឬជនណានាំឆ្លងដែនដោយខុសច្បាប់ និងគួរស្វែងរកក្រុមហ៊ុនស្របច្បាប់ ដើម្បីរៀបចំជូនបងប្អូនបានមកធ្វើការដោយស្របច្បាប់នៅប្រទេសថៃ។ ការធ្វើការគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ប្រឈមនឹងការចាប់ខ្លួន ពុំទទួលបានការថែទាំសុខភាព និងពុំទទួលបានសំណងក្នុងករណីជួបគ្រោះថ្នាក់ការងារ ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 09-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់ នាវេលាម៉ោង ១៨និង៤០នាទី ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ប៉ូលិសនីហ្សេរីយ៉ាបង្រ្កាបកន្លែងបង្កើតកូនលក់ខុសច្បាប់ ស្រីៗត្រូវគេចាប់រំលោភឲ្យមានផ្ទៃពោះ ដើម្បីបានកូនយកទៅលក់

https://khmernote.com/news/ 10-10-2019

នីហ្សេរីយ៉ា៖ ស្ត្រីមានផ្ទៃពោះចំនួន ១៩ នាក់ត្រូវបានប៉ូលិសជួយសង្គ្រោះចេញពីកន្លែងបង្កើតកូនលក់ខុសច្បាប់ ឬជាភាសារបស់ក្រុមជនខិលខូចហៅថា "រោងចក្រផលិតកូន" នៅក្នុងក្រុង Lagos ប្រទេសនីហ្សេរីយ៉ា។ សូមបញ្ជាក់ជូនថា នៅក្នុងប្រទេសនីហ្សេរីយ៉ាមានទីផ្សារងងឹតមួយសម្រាប់លក់កូនក្មេងតូចៗ ដែលក្នុងនោះក្មេងប្រុសមានតម្លៃជាមធ្យមគឺ ១ ២៣០ ដុល្លារ និងក្មេងស្រីមានតម្លៃ ៨៦០ ដុល្លារ។

ចំពោះស្ត្រីទាំង ១៩ នាក់ខាងលើត្រូវបានគេរាយការណ៍ថា មានអាយុចន្លោះពី ១៥ ដល់ ២៨ ឆ្នាំ ហើយពួកនាងបានចាញ់បោកជនខិលខូច បោកយកមកបង្ខាំងទុកនៅក្នុងរោងចក្រផលិតកូននេះ ហើយពួកនាងត្រូវបានបុរសជាច្រើននាក់ប្តូរវេនគ្នារំលោភម្នាក់ម្តងៗរហូតទាល់តែពួកនាងមានផ្ទៃពោះ។ ក្រៅតែពីបានជួយសង្គ្រោះស្ត្រីមានផ្ទៃពោះទាំង ១៩ នាក់ គេក៏បានជួយសង្គ្រោះក្មេង ៤ នាក់ផ្សេងទៀត ដែលគេបម្រុងនឹងលក់ចេញផងដែរក្នុងនោះមានក្មេងម្នាក់ទើបតែកើតបាន ១ ថ្ងៃប៉ុណ្ណោះ។

ក្នុងយុទ្ធនាការបង្ក្រាបការជួញដូរកុមារខាងលើនេះ ប៉ូលិសអាចចាប់ខ្លួនស្ត្រីជាធ្មប ដែលគ្មានជំនាញច្បាស់លាស់ត្រឹមតែ ២ នាក់ប៉ុណ្ណោះ ដោយឡែកមេខ្លោង និងក្រុមបុរសដែលប្តូរវេនគ្នាចាប់រំលោភស្ត្រីរងគ្រោះនោះបានរត់គេចខ្លួនបាត់អស់ហើយ។ សូមរម្លឹកជូនថា នីហ្សេរីយ៉ាជាទីកន្លែងដែលមានការជួញដូរកុមារ និងស្ត្រីដ៏ធំមួយ ហើយកាលពីឆ្នាំកន្លងទៅមានកុមារប្រមាណជា ១៦០ នាក់ត្រូវបានគេជួញដូរ និងរហូតមកទល់នឹងពេលនេះគេមិនដឹងថាកុមារទាំងនោះទៅដល់ទីណានោះទេ៕

# ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៩

## ថាបោកៗមែន! មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាកូរ៉េសាំស៊ុង រងការចោទប្រកាន់ថា បោកលុយពលរដ្ឋរាប់រយនាក់ ម្នាក់ៗអស់មិនក្រោមខ្ទង់ពាន់ដុល្លារ

http://kampucheathmey.com/ វិទូ10/10/2019 5:01 Pm

ភ្នំពេញ ៖ ប្រជាពលរដ្ឋប្រុស/ស្រីប្រមាណជាង១០នាក់ តំណាងឲ្យពលរដ្ឋរាប់រយនាក់ ដែលអះអាងថា ចាញ់បោកក្រុមហ៊ុនមួយឈ្មោះថា «មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាកូរ៉េសាំស៊ុង» ដែលបានប្រកាសជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេសដោយតម្រូវឲ្យ ម្នាក់ៗបង់លុយមុនចាប់ពី១០០០ដុល្លារ ទៅ៣០០០ដុល្លារ រង់ចាំថ្ងៃហៅសម្ភាសន៍ចេញទៅធ្វើការតែអស់រយៈពេលជាច្រើនខែមកហើយ គឺស្ងាត់ឈឹងរហូត មិនបានទៅធ្វើការឯណាឡើយ ពេលនាំគ្នាមកទារលុយវិញ ម្តងថាថ្ងៃនេះម្តង ថាថ្ងៃនោះ សង្ស័យថាបោកឥឡូវបោកមែន ទើបនាំគ្នារត់ទៅរកសុំឲ្យសមត្ថកិច្ចជួយអន្តរាគមន៍ កាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ នៅភូមិក្បាលដំរី២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ។

តាមសម្តីប្រជាពលរដ្ឋជាចាញ់បោកបានឲ្យដឹងថា ពួកគាត់បានមកចុះឈ្មោះ បង់លុយ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាកូរ៉េ សាំស៊ុង នេះ ដែលមានទីតាំងស្ថិតនៅក្នុងភូមិក្បាលដំរី២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យនេះមិនមែនមានតែជាង១០នាក់នោះទេ ពោលគឺមានប្រជាពលរដ្ឋមកចុះឈ្មោះ នៅទីនេះរាប់រយនាក់ឯនោះ ក្នុងម្នាក់ៗ បង់លុយចាប់ពី១០០០ដុល្លារ រហូតដល់៣០០០ដុល្លារ មានចេញឯកសារវិក្កយបត្រត្រឹមត្រូវ សន្យាថានឹងនាំទៅធ្វើការនៅបរទេស តែផ្ទុយទៅវិញ រាប់ខែទៅហើយ ពួកគាត់មិនត្រូវបានក្រុមហ៊ុន មជ្ឈមណ្ឌលមួយនេះ ចាត់បញ្ជូន

ទៅធ្វើការឯណាឡើយ អ្នកខ្លះទើបបង់លុយ អ្នកខ្លះបង់លុយគ្រប់យូរហើយអត់បានទៅណាទាំងអស់គ្នានឹង ហើយម្នាក់ៗចេះតែនឹកគិតថា សង្ស័យថាបោកប្រាស់ទេ រហូតមកដល់ពេលនេះទើបដឹងច្បាស់ថា បោកមែនហួសចិត្តតែម្តង។

ពលរដ្ឋបន្តទៀតថា ក្រោយពីអស់ទំនុកចិត្តលើអ្នកគ្រប់គ្រងនៅក្នុងមជ្ឈមណ្ឌលមួយនេះ អស់លុយហើយនោះ និងមិនបានចេញទៅធ្វើការអីសោះនោះទើបនាំគ្នាទៅតវ៉ាសុំដកលុយវិញ តែខាងតំណាងមជ្ឈមណ្ឌល ម្តងថាថ្ងៃនោះ ម្តងថាថ្ងៃនោះ យកលេសកុហករហូត ទើបនៅព្រឹកថ្ងៃទី១០ នេះ ពលរដ្ឋជាង១០នាក់ តំណាងឲ្យពលរដ្ឋរាប់រយនាក់ទៀតដែលមិនបានមកជាក់ស្តែងបាននាំគ្នារត់ទៅប្តឹងសមត្ថកិច្ចឲ្យជួយអន្តរាគមន៍ដោះស្រាយជូនពួកគាត់ផង ហើយសមត្ថកិច្ចកំពុងស្រាវជ្រាវករណីនេះដើម្បីហៅអ្នកគ្រប់គ្រងមកសាកសួរ។ រហូតមកដល់ព្រឹកនេះ គេមិនអាចទាក់តាមទូរស័ព្ទដែលមាននៅលើវិក្កយបត្រចូលទេ ហើយភ្នាក់ងារព័ត៌មានក៏រង់ចាំការបកស្រាយបំភ្លឺពីសំណាក់អ្នកគ្រប់គ្រងនោះដែរ៕

## កម្លាំងចម្រុះរបស់ស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន បង្ក្រាបទីតាំងជួញដូរផ្លូវភេទខុសច្បាប់ មួយកន្លែងឃាត់មនុស្ស៦នាក់

http://cambodiapolice.com/policekh/ 7:13 am 11 តុលា 2019

ភ្នំពេញ៖ កាលពីវេលាម៉ោង០១និង០៥នាទី រំលងអាធាត្រឈានចូលថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ដោយមានការដឹកនាំផ្ទាល់ពីលោក តូច សុភក្តិ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តប៉ៃលិន និងមានការបញ្ជាពីលោកឧត្តមសេនីយ៍ទោ សេង សុគន្ធ ស្នងការនគរបាលប៉ៃលិន ចាត់ឲ្យលោកឧត្តមសេនីយ៍ត្រី ស៊ិន សុភាលក្ស្មី ស្នងការរងផែនការងារគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងអគ្គីភ័យ ដឹកនាំកម្លាំងចម្រុះនៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ចុះបង្ក្រាបករណីជួញដូរផ្លូវភេទខុសច្បាប់ មួយកន្លែងស្ថិតនៅចំណុចផ្ទះរបស់ឈ្មោះ សុខ ស្រីលីន ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិវៀតណាម នៅក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ឃាត់ខ្លួនបានជនសង្ស័យប្រុសស្រីចំនួន០៦នាក់។ ក្នុងករណីនេះកម្លាំងជំនាញបានឆែកឆេរឃើញស្រោមអនាម័យមួយចំនួននៅក្នុងកាបូបដៃជនសង្ស័យ និងស្រោមអនាម័យដែលប្រើប្រាស់រួចនៅក្នុងធុញសំរាមសរុបចំនួន១០ស្រោម។ ករណីខាងលើទៅការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជន បានកសាងសំណុំរឿងដើម្បីអនុវត្តតាមនីតិវិធីបន្ត ៕

## មិនគួរយកស្រោមអនាម័យ ធ្វើជាឥស្សតាងក្នុងការបង្ក្រាបអំពើជួញដូរមនុស្សទេ

https://www.postkhmer.com/ តុង សុប្រាជ្ញ | Publication date 11 October 2019 | 08:50 ICT

កម្ពុជាត្រូវបានគេទទួលស្គាល់ថា ជាប្រទេសដែលអនុវត្តការប្រយុទ្ធប្រឆាំងទៅនឹងការរីករាលដាលនៃជំងឺអេដស៍បានល្អ និងបានឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០១៥។ ពោលគឺនិន្នាការទិន្នន័យនៃមេរោគអេដស៍ និងជំងឺអេដស៍មានការធ្លាក់ចុះជាលំដាប់ទាំងប្រេវ៉ាឡង់ ទាំងចំនួនអ្នកផ្ទុកមេរោគ ទាំងការចម្លងមេរោគថ្មី និងទាំងអ្នកស្លាប់ដោយសារជំងឺអេដស៍ ។ តាមរយៈការសិក្សាថ្មីៗ និងធ្វើបច្ចុប្បន្នភាពជាស៊េរីនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) ឆ្នាំ ២០១៩ បានរកឃើញ និងធ្វើការប៉ាន់ប្រមាណ និន្នាការអត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅដែលមានអាយុពី ១៥-៤៩ ឆ្នាំ ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០២០ គឺមានការធ្លាក់ចុះពី ១,៦ ភាគរយ មក ០,៥ ភាគរយ។ រីឯនិន្នាការចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅកម្ពុជាមានអាយុពី ១៥ ទៅ ៤៩ ពីឆ្នាំ ២០០៥ ដល់ ២០២០ គឺពី ១០ ម៉ឺននាក់មក ៦ ម៉ឺននាក់ ។ ម្យ៉ាងទៀតការចម្លងថ្មីក៏ធ្លាក់ចុះពី ៤ ០០០ នាក់មក ៥០០ នាក់ និងករណីស្លាប់បានធ្លាក់ចុះពី ៨ ០០០ នាក់មក ២ ០០០ នាក់។ នៅពេលដែលនិន្នាការមានការធ្លាក់ចុះបែបនេះនៅឆ្នាំ ២០១២ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) សហការជាមួយ UNAIDS បានចេញក្របខ័ណ្ឌគោលគំនិត «កម្ពុជា ៣.០» សម្រាប់ឈានដល់ការលុបបំបាត់

ការឆ្លងមេរោគអេដស៍ថ្មីនៅកម្ពុជានៅឆ្នាំ ២០២០ ខាងមុខនេះ។ កម្ពុជា ៣.០ មានន័យថាទី ១- គ្មានការចម្លងមេរោគអេដស៍ថ្មី ទី ២- គ្មានការស្លាប់ដោយសារជំងឺអេដស៍ថ្មី និងទី ៣- គ្មានការរើសអើងនឹងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍។

ទោះបីជាមានការអនុវត្តការកាត់បន្ថយការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍នេះបានប្រសើរឡើងក៏ដោយ ក៏នៅមានបញ្ហាប្រឈមដែលមាននៅក្នុងរបាយការណ៍វឌ្ឍនភាពជាតិស្តីពីការប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ ២០១៥ ដូចជាការផ្លាស់ប្តូរថ្មីៗពាក់ព័ន្ធទៅនឹងការឆ្លើយតបទៅនឹងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ច្បាប់ស្តីពីការបង្ក្រាបអំពើការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនជាដើម។ ឧទាហរណ៍គ្រាន់តែច្បាប់បង្ក្រាបការជួញដូរ និងអាជីវកម្មផ្លូវភេទចេញឲ្យអនុវត្តនៅឆ្នាំ ២០០៨ គឺធ្វើឲ្យបាត់បង់ក្រុមគោលដៅមួយចំនួនធំរបស់កម្មវិធីលើកកម្ពស់សុខភាពផ្លូវភេទ និងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍។ ជាមួយគ្នានេះដែរកន្លងមកជារឿយៗសមត្ថកិច្ចដែលចុះបង្ក្រាបទីតាំងផ្ទះបនក្តី កន្លែងខារ៉ាអូខេ និងកន្លែងម៉ាស្សាដែលផ្តល់សេវាផ្លូវភេទខុសច្បាប់គឺមន្ត្រីអនុវត្តច្បាប់ទាំងនោះគឺតែងតែប្រមូលយកស្រោមអនាម័យទាំងប្រើរួច និងមិនទាន់ប្រើយកទៅធ្វើជាភ័ស្តុតាងជាតុផ្សំដើម្បីដាក់បន្ទុកមកលើជនជាប់ចោទ ដើម្បីកសាងសំណុំរឿងទៅតុលាការ។

តែកន្លងមកករណីយកស្រោមអនាម័យមកធ្វើជាភ័ស្តុតាងនេះ ត្រូវក្រុមសិទ្ធិមនុស្សមួយចំនួនតូចបានរិះគន់ពីការអនុវត្តរបស់សមត្ថកិច្ចថាបានរំលោភលើសិទ្ធិក្នុងការប្រើប្រាស់ស្រោមអនាម័យ ដើម្បីសុវត្ថិភាពជីវិតរបស់ពួកគេនោះ តែមកទល់ពេលនេះអាជ្ញាធរនៅតែអនុវត្តដដែល។ បញ្ហានេះ គឺត្រូវបានបង្ហាញថា ការអនុវត្តច្បាប់ចំនួន ២ របស់រាជរដ្ឋាភិបាល មានស្តង់ដាជាន់គ្នា ខណៈដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍កំពុងតែអនុវត្តច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ និងជំងឺអេដស៍ដែលមានគោលការណែនាំឲ្យប្រើប្រាស់ស្រោមអនាម័យ ដើម្បីជាមធ្យោបាយទប់ទល់នឹងមេរោគអេដស៍ពោលគឺលើកទឹកចិត្តឲ្យបុរសដែលមានដៃគូច្រើនប្រើប្រាស់ស្រោមអនាម័យដើម្បីសុវត្ថិភាព។ រីឯប៉ូលិសអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីសុវត្ថិភាពរបស់ស្ត្រី និងកុមារី តែនៅពេលអនុវត្តគឺសមត្ថកិច្ចបង្ក្រាបម្តងមានការស៊ើបអង្កេតរួចហើយមុននឹងធ្លាក់ចូលទៅទីតាំងដែលផ្តល់សេវាផ្លូវភេទនោះ តែអ្វីដែលសំខាន់នោះគឺប៉ូលិសតែងតែឆ្លៀតយកស្រោមអនាម័យធ្វើជាភ័ស្តុតាងបន្ថែម។

ការអនុវត្តបែបនេះតែរហូតអ៊ីចឹងគឺធ្វើឲ្យប៉ះពាល់ទៅនឹងការសម្រេចចិត្តរបស់អ្នកប្រព្រឹត្តការរួមភេទថា តើពួកគេគួរតែប្រើស្រោមអនាម័យ ឬមួយក៏អត់? បើមិនប្រើខ្លាចឆ្លងអេដស៍ ហើយប្រើស្រោមអនាម័យខ្លាចប៉ូលិសចុះបង្ក្រាបមកឃើញយកធ្វើជាភ័ស្តុតាងដាក់បន្ទុក ដើម្បីបញ្ជូនទៅតុលាការទៅវិញ ។ កន្លងមកមិនមានប្រទេសណាមួយដែលមានបទពិសោធអនុវត្តដូចនេះទេ។ ប៉ុន្តែនៅពេលដែលអនុវត្តមែនទែននោះ ហើយសមត្ថកិច្ចកម្រចាប់បានទៀតនោះ គឺការទិញសេវាផ្លូវភេទយកមកធ្វើជាស្រីចិញ្ចឹម ឬក៏ស្រីកំណាន់របស់តាតាទៅវិញដែលទិញឡាន ផ្ទះ និងសម្ភារទំនើបៗទៀតក៏មានដែរគឺពួកគេកម្រប្រើស្រោមអនាម័យទៅវិញទេ។ នេះបើតាមរបាយការណ៍ការសិក្សាស្រាវជ្រាវរបស់អង្គការ PSI ឆ្នាំ ២០០២។ ផ្ទុយទៅវិញ ប្រសិនបើអ្នកដឹងខ្លួនថាមានផ្ទុកមេរោគអេដស៍មានបំណងចម្លងមេរោគទៅអ្នកដទៃដោយមិនប្រើស្រោមអនាម័យគឺត្រូវមានទោសទៅវិញ។ នេះបើតាមច្បាប់ទប់ស្កាត់មេរោគអេដស៍។ ចំណុចនេះបានយកស្រោមអនាម័យមានសារៈសំខាន់ទៅវិញដែលអាចដាក់បន្ទុកបាន ប្រសិនបើមិនមានជាតុផ្សំស្រោមអនាម័យមកធ្វើជាភ័ស្តុតាងទេនោះ។

យ៉ាងណាមិញ បើមើលទៅក្នុងច្បាប់ប្រឆាំងនឹងការជួញដូរនេះវិញ គឺមិនមានមាត្រាណាដែលនិយាយអំពីស្រោមអនាម័យយកមកធ្វើជាភ័ស្តុតាងនោះទេ។ អ៊ីចឹងហើយទាំងប៉ូលិស ទាំងតុលាការ មិនគួរយកជាតុផ្សំបន្ថែមស្រោមអនាម័យដែលត្រូវបានគេហៅថា «លោកជួយ» នោះមកវិនិច្ឆ័យដាក់បន្ទុកបន្ថែមនោះទេ ក្នុងការបង្ក្រាបទីតាំង

ផ្តល់សេវាផ្លូវភេទម្តងៗ ព្រោះយកជាតុផ្សំផ្សេងដែលពាក់ព័ន្ធទៅនឹងច្បាប់ចែងក្នុងច្បាប់គឺវាគ្រប់គ្រាន់ទៅហើយ ណាមួយការអនុវត្តបែបនេះវាផ្ទុយទៅនឹងច្បាប់ និងគោលការណ៍ណែនាំឲ្យប្រើប្រាស់ស្រោមអនាម័យនៅពេលរួមភេទ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺអេដស៍។ បើមិនដូច្នេះទេ ករណីបង្ក្រាបការជួញដូរមនុស្ស និងអំពើពេស្យាកម្ម ដោយយកស្រោមអនាម័យមកធ្វើជាភ័ស្តុតាងគឺអាចមានករណីផ្ទុះការរីករាលដាលនៃជំងឺអេដស៍ដូចនៅឃុំរកាខេត្ត បាត់ដំបងនោះជាដើម៕

## កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តរ៉ាក់យ៉ង ធ្វើការឃាត់ខ្លួនពលករខុសច្បាប់ សញ្ជាតិខ្មែរនិង ភូមា បានចំនួន១៧នាក់

https://www.facebook.com/LabourOfficial/ 10/10/19 09:00

កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តរ៉ាក់យ៉ង ធ្វើការឃាត់ខ្លួនពលករខុសច្បាប់ សញ្ជាតិខ្មែរនិង ភូមា បានចំនួន ១៧នាក់ ខណៈពេលលបលួចធ្វើការសំណង់នៅក្នុងតំបន់ម៉ាបតាពុត ខេត្តរ៉ាក់យ៉ង ។

## ហេតុការណ៍រថយន្ត Pick up បើកគេចរថយន្តធុន ជ្រុលទៅបុកនិងពលករកំពុងធ្វើការសាងសង់ផ្លូវ

https://www.facebook.com/LabourOfficial/ 10/10/19

វេលាម៉ោង ០៣ រសៀល កើតហេតុការណ៍រថយន្ត Pick up បើកគេចរថយន្តធុន ជ្រុលទៅបុកនិងពលករកំពុងធ្វើការសាងសង់ផ្លូវ មុំបរិវេណ តាឡាតប៉ងកុន ស្ថិតក្នុងខេត្តឆាកឈើងសៅ បណ្តាលអោយមានមនុស្សស្លាប់និងកន្លែងកើតហេតុ ១នាក់ និងរបួសដាច់ជើងទាំងសងខាង ១នាក់ ប្រភពបឋម សមត្ថកិច្ចថៃបញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីពេទ្យពុធចាក់សូរថន ខេត្តឆាកឈើងសៅ។

## ពលករវៀតណាមជាង១០៤ពាន់នាក់បញ្ជូនទៅបរទេស

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ ម៉ោង ០៧:៣០ ខាន់ សុខយន

ប្រទេសវៀតណាម ៖ នាយកដ្ឋានគ្រប់គ្រងពលករវៀតណាមនៅបរទេស នៃក្រសួងការងារ អតីតយុទ្ធជននិងសង្គមកិច្ចវៀតណាមរាយការណ៍នាថ្ងៃទី៩តុលាថា រវាងខែមករា និងខែកញ្ញាពលករវៀតណាម ១០៤.៦១៥នាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅបរទេសដែលត្រូវជា៨៧,២%នៃទិសដៅប្រចាំឆ្នាំ។ ក្នុងខែកញ្ញាតែមួយគត់ចំនួនពលករដែលបញ្ជូនទៅបរទេសមានដល់១២.៩៥០នាក់។ ប្រទេសសំខាន់ៗដែលទទួលពលករវៀតណាមរយៈពេល៩ខែចុងក្រោយនេះ មានប្រទេសជប៉ុនជាមួយពលករ ៥៣.៦១០នាក់ តៃវ៉ាន់៤១.១៧៤នាក់ កូរ៉េខាងត្បូង ៥.៨៩៨នាក់ រូម៉ានី ១១០៣នាក់ អារ៉ាប៊ីសាអូឌីត៨១៧នាក់ ម៉ាឡេស៊ី៣០៤នាក់។ សម្រាប់ឆ្នាំ២០១៩ទាំងមូលក្រសួងវៀតណាមនោះគ្រោងបញ្ជូនពលករទៅបរទេសឲ្យបានដល់១២០.០០០នាក់។ តៃវ៉ាន់និងជប៉ុនជាទីផ្សារប្រពៃណីនៃការនាំចេញពលករវៀតណាម៕ (កែសម្រួលដោយ ៖ បុប្ផា)

# ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៩

## ហាងម៉ាស្សា២កន្លែង នៅសៀមរាបសុទ្ធតែបង្កប់សេវាផ្លូវភេទ

https://kbn.news/ October 11, 2019

**ខេត្តសៀមរាប៖** កាលពីវេលាម៉ោង៩ និង៣០នាទី ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចខេត្តសៀមរាប ដោយបានការឯកភាពពីលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូង បានចុះបង្ក្រាបហាងម៉ាស្សា២កន្លែង ដែលលួចបង្កប់សេវាបម្រើផ្លូវភេទ។ សមត្ថកិច្ចបានឲ្យដឹងថា ហាងម៉ាស្សាដែលបង្កប់សេវាបម្រើផ្លូវភេទ ត្រូវសមត្ថកិច្ចធ្វើការបង្ក្រាបនេះ ទី១-ហាងម៉ាស្សាយីហោ «លីលី១៦៨» ទី២-ហាងម៉ាស្សា «សំណាងល្អ» ស្ថិតនៅភូមិត្រៀក សង្កាត់សៀមរាប ក្រុង/ខេត្តសៀមរាប ប្រមូលបានស្រ្តីរកស៊ីផ្លូវភេទចំនួន០៥នាក់ (អនីតិជនចំនួន០២នាក់) និងឃាត់ខ្លួនថៅកែចំនួន០២នាក់ ទី១-ឈ្មោះ ហ៊ន់ សុខលី ភេទស្រី អាយុ៣៦ឆ្នាំ ថៅកែហាងម៉ាស្សា «លីលី១៦៨» និង២- ឈ្មោះ សឿន ធីតា ភេទស្រីអាយុ៣៦ឆ្នាំ ថៅកែម៉ាស្សា «សំណាងល្អ» ។ ប្រភពបន្តថា ក្រោយឃាត់ខ្លួន ជនសង្ស័យទាំង២នាក់ ត្រូវសមត្ថកិច្ចនាំទៅចាត់ការតាមផ្លូវច្បាប់ ។ ចំណែក នារីរងគ្រោះទាំង០៥នាក់ សមត្ថកិច្ចបានបញ្ជូនទៅមន្ទីរសង្គមកិច្ចខេត្ត ដើម្បីការអប់រំជាមុនសិន ទើបអនុញ្ញាតិឲ្យត្រឡប់ទៅផ្ទះវិញ ៕

## តុលាការកំពុងបន្តសាកសួរជនប្រុស-ស្រី ៦ នាក់ រឿងជួញដូរផ្លូវភេទ

https://www.postkhmer.com/ គឹម សារុំ | Publication date 14 October 2019 | 10:30 ICT

**ប៉ៃលិន/សៀមរាប៖** ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តប៉ៃលិនកាលពីម្សិលមិញនៅកំពុងបន្តសាកសួរជនប្រុស-ស្រី ៦ នាក់ បន្ទាប់ពីចាប់ខ្លួននៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅកាលពីថ្ងៃទី ១០ ខែតុលា ពាក់ព័ន្ធនឹងការបើកកន្លែងម៉ាស្សាបង្កប់សេវាផ្លូវភេទ ខណៈស្ត្រី ២ នាក់ ត្រូវតុលាការឃុំខ្លួននៅពន្ធនាគារខេត្តសៀមរាបពាក់ព័ន្ធពីបទសច្ចារកម្ម ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ៩ ខែតុលា នៅសង្កាត់ ក្រុង-ខេត្តសៀមរាប។

លោក យឹម រដ្ឋា នាយផ្នែកការិយាល័យជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាល ខេត្តប៉ៃលិនបានថ្លែងកាលពីម្សិលមិញថា ជនសង្ស័យក្នុងរឿងនេះមាន ៦ នាក់ ដែល ទី១- ឈ្មោះ សុខ ស្រីលីន (ម្ចាស់ផ្ទះ) ភេទស្រី អាយុ ៣៥ ឆ្នាំ ទី២- រឿង ធីហុង (ហៅ រក្សា) ភេទស្រី អាយុ ២៥ ឆ្នាំ ទី៣- ឈ្មោះ ធិន ណារ៉ាន់ (ហៅ អាម៉ី) ភេទស្រី អាយុ ២២ ឆ្នាំ ទី៤- ថៃ នីតែលិន ភេទស្រី អាយុ ២៧ ឆ្នាំ ទាំង ៤ នាក់ ជាជនជាតិវៀតណាម។ ទី៥- ម៉ៃទ្រី ថាណាផា សាត់ថាណា (ហៅ ម៉ៃទី) ភេទប្រុស អាយុ ៤៥ ឆ្នាំ មុខរបរ គ្រូពេទ្យ ជនជាតិថៃ និង ទី៦- ឆាត ឡុង ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរជាសន្តិសុខមានលំនៅនៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។ លោក រដ្ឋា បន្តថាជនសង្ស័យទាំង ៦ នាក់នេះ សមត្ថកិច្ចបានបញ្ជូនទៅសាលាដំបូងខេត្ត ប៉ៃលិនតាំងពីថ្ងៃទី ១១ ខែតុលា បន្ទាប់ពីចាប់ខ្លួនពួកគេបាន ១ ថ្ងៃ ប៉ុន្តែដោយខាងតុលាការសួរពួកគេមិនទាន់អស់គ្នាទើបបញ្ជូនពួកគេ ផ្ញើនៅស្នងការដ្ឋាននគរបាល ខេត្តប៉ៃលិន ១ យប់ ហើយថ្ងៃម្សិលមិញទើបតុលាការបន្តសួរពួកគេទៀត។

លោកបញ្ជាក់ថា៖ «ពួកគេមិនទាន់ត្រូវតុលាការចោទពីបទអ្វីនៅឡើយទេ ព្រោះតុលាការកំពុងសាកសួរបន្តទៀត។ ប៉ុន្តែពួកគេជាប់ពាក់ព័ន្ធនឹងជួញដូរផ្លូវភេទ»។ បើតាមលោក រដ្ឋា ក្រុមជនសង្ស័យត្រូវកម្លាំងចម្រុះខេត្តប៉ៃលិនចុះបង្ក្រាបកាលពីវេលាម៉ោង ១ រំលងអធ្រាត្រឈានចូលថ្ងៃទី ១០ ខែតុលាឆ្នាំនេះ ពាក់ព័ន្ធជួញដូរផ្លូវភេទខុសច្បាប់ស្ថិតនៅផ្ទះរបស់ឈ្មោះ សុខ ស្រីលីន ដែលជាជនជាតិវៀតណាមនៅក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។ ប្រតិបត្តិការនោះសមត្ថកិច្ចបានឆែកឆេរក្នុងផ្ទះដោយបានរកឃើញ ស្រោមអនាម័យចំនួន ៤ នៅក្នុងកាបូបដៃរបស់ជនសង្ស័យម្នាក់ និងស្រោមអនាម័យដែលប្រើរួចនៅក្នុងធុងសំរាម។

ករណីជួញដូរផ្លូវភេទនេះដែរស្ត្រីខ្មែរ ២ នាក់ត្រូវបានសាលាដំបូងខេត្តសៀមរាបចោទប្រកាន់កាលពីថ្ងៃទី ១១ តុលា បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី ១០ តុលា ក្នុងទីតាំង ២ ផ្សេងគ្នា។ ទីតាំងទី ១ នៅផ្ទះម៉ាស្សា យីហោលីលី ១៦៨ និងទីតាំងទី ២ ផ្ទះម៉ាស្សា សំណាងល្អ ស្ថិតនៅភូមិត្រៀក សង្កាត់ សៀមរាប ក្រុង-ខេត្តសៀមរាប ។

លោក ស្រី ដួង ថាវរី ស្នងការរងទទួលផែនជួញដូរមនុស្សនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាបបានឲ្យដឹងពីម្សិលមិញថា ស្ត្រីដែលតុលាការឃុំខ្លួននោះឈ្មោះ ហ៊ន់ សុខលី អាយុ ៣៦ ឆ្នាំ ជាថៅកែហាងម៉ាស្សាយីហោលីលី ១៦៨ និង ២ សឿន ធីតា អាយុ ៣៦ ឆ្នាំ ថៅកែម៉ាស្សាសំណាងល្អ។ «ពួកគេត្រូវបានចោទប្រកាន់ពីបទសច្ចារកម្ម» ដោយក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទចំនួន ៥ នាក់នោះ គឺមានអនីតិជន ២ នាក់ និងឃាត់ខ្លួនថៅកែ ២ នាក់។ បើតាមលោក ស្រី ថាវរី សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យទាំង ២ នាក់តាមបញ្ជារបស់លោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តនៅវេលាម៉ោង ២៣:៣០ នាទីយប់ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៩ និងសង្គ្រោះជនរងគ្រោះបាន ៥ នាក់ ។ ចំណែកឯជនរងគ្រោះទាំង ៥ នាក់នោះ សមត្ថកិច្ចបានបញ្ជូនទៅមន្ទីរសង្គមកិច្ចខេត្ត៕

## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រៀបចំពិធីផ្សព្វផ្សាយ ស្តីពីការស៊ើបអង្កេតការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

http://cambodiapolice.com/policekh/ 10:32 am 14 តុលា 2019

**ភ្នំពេញ៖** ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩នេះ បានអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយ ស្តីពីការស៊ើបអង្កេតការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ពិធីនេះ មានការចូលរួមពី អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន, ស្នងការរងទទួលផែនប្រឆាំងការជួញដូរ និងនាយការិយាល័យប្រឆាំងការជួញដូរ ទាំង២៥រាជធានី-ខេត្តផងដែរ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានមានប្រសាសន៍ថា នេះជាលើកទី១ ដែលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ទទួលបានការផ្សព្វផ្សាយ ស្តីពីការស៊ើបអង្កេតការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយការផ្សព្វផ្សាយនេះ រៀបចំឡើងដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ អំពីការងារប្រឆាំងការសម្អាតប្រាក់ ដែលជាសញ្ញាណថ្មីសម្រាប់មន្ត្រីអនុវត្តច្បាប់ និងផ្សព្វផ្សាយសេចក្តីណែនាំលេខ០៣៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើនស្មារតីយកចិត្តទុកដាក់អនុវត្តច្បាប់ស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ឯកឧត្តម បន្តថា ការប្រឆាំងការសម្អាតប្រាក់ ដែលយើងត្រូវការស៊ើបអង្កេតផ្តើមចេញការជួញដូរមនុស្ស ដែលកន្លងទៅយើងដឹងតែករណីពាក់ព័ន្ធនឹងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ដូច្នេះទាមទារឲ្យយើងទាំងអស់គ្នាជាមន្ត្រីអនុវត្តច្បាប់ត្រូវយល់ដឹងបន្ថែម អំពីនីតិវិធីបើកការស៊ើបអង្កេតទាក់ទងការប្រឆាំងការសម្អាតប្រាក់។

ឯកឧត្តមប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជាក់ថា បទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងវិធានការស្រាវជ្រាវស៊ើបអង្កេត ជាសញ្ញាណថ្មីមួយសម្រាប់នគរបាលកម្ពុជា ដែលមិនទាន់មានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងនៅមានការភ័ន្តច្រឡំអំពីចរិតលក្ខណៈ នៃបទល្មើសនេះនៅឡើយ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ក៏បានស្នើឲ្យមន្ត្រីអនុវត្តច្បាប់ទាំងអស់យកចិត្តទុកស្តាប់គ្រូឧទ្ទេសនាម ហើយសង្ឃឹមថា បន្ទាប់ពីទទួលការផ្សព្វផ្សាយ ស្តីពីការស៊ើបអង្កេតការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម មន្ត្រីអនុវត្តច្បាប់ទាំងអស់នឹងយកចំណេះដឹង និងបទពិសោធន៍ទាំងនេះ ទៅបម្រើក្នុងវិស័យប្រយុទ្ធប្រឆាំងអំពើប្រឆាំងការសម្អាតប្រាក់ ពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ៕

## សមត្ថកិច្ចថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៤នាក់ មកឲ្យព្រះរាជាណាចក្រកម្ពុជាវិញ

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 11-10-2019

នៅព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៩ សមត្ថកិច្ចថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៤នាក់ មកឲ្យព្រះរាជាណាចក្រកម្ពុជាវិញ តាមច្រកទ្វារតំបន់ព្រំដែនអានសេះ ខេត្តព្រះវិហារ។ សមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០៤នាក់នេះ មាន ១.ឈ្មោះ ហ៊ុន ហន ភេទប្រុស អាយុ ៣៤ឆ្នាំ រស់នៅភូមិរលំថ្ម ឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ចាប់នៅចំណុចភ្នំដាច់ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨, ២.ឈ្មោះ រស់ វ៉ានលីន ភេទប្រុស អាយុ ៣១ឆ្នាំ រស់នៅភូមិខ្យង ឃុំខ្យង ស្រុកជ័យសែន ខេត្តព្រះវិហារ ចាប់នៅចំណុចភ្នំដាច់ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨, ៣.ឈ្មោះ ជួន ចាន់ ភេទប្រុស អាយុ ៥៣ឆ្នាំ រស់នៅភូមិកន្ទួត ឃុំកែតោក ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចាប់នៅច្រកមុនីកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ និង៤.ឈ្មោះ ហួត រហឿន ភេទប្រុស អាយុ ២៣ឆ្នាំ រស់នៅភូមិអានសេះ ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ចាប់នៅចំណុចភ្នំដាច់ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨។ ពលរដ្ឋខ្មែរទាំង ០៤នាក់នេះ ត្រូវបានសមត្ថកិច្ចធ្វើការអប់រំ និងមានការជានាពីអាណាព្យាបាល រួចហើយឲ្យត្រឡប់ទៅមូលដ្ឋានវិញ៕

## សូមបងប្អូនជួយស៊ែរឲ្យដឹងដល់មន្ត្រីផង! ស្ត្រីពលករខ្មែរម្នាក់ធ្វើការនៅកូរ៉េ ត្រូវថៅកែធ្វើបាប ហើយបណ្តេញចេញពីការងារនិងមិនបើកប្រាក់ខែ

http://www.cen.com.kh/ October 14, 2019

ប្រទេសកូរ៉េ៖ ស្ត្រីវ័យក្មេងជាពលករខ្មែរម្នាក់ សែលបានចេញទៅធ្វើការនៅប្រទេសកូរ៉េ បាន Live វីដេអូតាមអាខោនហ្វេសប៊ុក "កញ្ញា ផ្កាស្មៅក្រៀម" បាននិយាយរៀបរាប់ និងត្អូញត្អែរឿងថា ថៅកែ ដែលរូបនាងបានទៅធ្វើការជាមួយនោះ វាបធ្វើបាប ហើយមិនបើកប្រាក់ខែឲ្យគ្រប់ចំនួនទេ ពោលគឺបើកបានតែ ៦៣ម៉ឺនវៀល។ បន្ថែមលើនេះបច្ចុប្បន្ននេះស្ត្រីរូបនោះត្រូវបានថៅកែដេញចេញពីការងារថែមទៀតផងនៅពេលរូបនាងទារប្រាក់ខែចំនួន៨០ម៉ឺនរៀល។ ស្ត្រីរងគ្រោះរូបនោះ ត្រូវបានគេស្គាល់ឈ្មោះពិតថា រឹម ស្រីរ៉ុម មានស្រុកកំណើតនៅខេត្តកំពត។ ស្ត្រីរូបនេះ បានរៀបរាប់ថា ថៅកែប្រើ របស់ខ្លួន បានប្រើសំដីគម្រោះគម្រើយស្រែកដាក់ខ្លាំងៗ ហើយរុញច្រាន ខ្លួនប្រាណនាង រហូតដល់រហែកអាវ និងមិនឲ្យពាក់ម្ហូក ពេលត្រជាក់ខ្លាំង ហើយនៅពេលថ្ងៃក្តៅក៏ក្តៅមុខ របស់នាងពេលឡើងអុចមពណ៌ៗក្រហម។ ជាងនេះទៀត ចំពោះស្រោមដៃ និងម៉ាស់ពាក់បិទមុខ ក៏ថៅកែមិនឲ្យពាក់ដែរ។ ក្នុងនោះពេលត្រជាក់ខ្លាំង ក៏គ្មានទឹកក្តៅឲ្យងូតដែរ ទោះរូបនាងបានខិតខំធ្វើការងារដោយអំណត់ព្យាយាមបែបណាក្តី ក៏នៅតែមិនត្រូវចិត្តថៅកែ របស់ខ្លួនទៀត។ ផ្តើមពីបញ្ហានេះ ស្ត្រីរងគ្រោះ ដែលគេស្គាល់ឈ្មោះពិតថា រឹម ស្រីរ៉ុម និងមានអាខោនហ្វេសប៊ុក "កញ្ញា ផ្កាស្មៅក្រៀម" បានអំពាវនាវដល់ថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសប្រមុខដឹកនាំរាជរដ្ឋាភិបាល ជួយអន្តរាគមន៍ដល់រូបនាង ឲ្យបានវិលមកស្រុកកំណើតវិញផង។ ខាងក្រោមនេះ ជាលេខទូរស័ព្ទរបស់ស្ត្រីរងគ្រោះ ជាពលករខ្មែរកំពុងមានបញ្ហានៅប្រទេសកូរ៉េ ឈ្មោះ រឹម ស្រីរ៉ុម +82 10-9846-5533៕ ដោយ៖ ដែន សីមា

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration GDI October 11 at 4:39 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់ នាវេលាម៉ោង ១៤និង៥០នាទី ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៩

## ក្រសួងសង្គមកិច្ច និងអង្គការចំនួន ១៣ រួមគ្នាធ្វើការលើវិស័យសុខុមាលភាពកុមារ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 16 October 2019 | 09:35 ICT

**ភ្នំពេញៈ** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចុះកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការចំនួន ១៣ មានថវិកាសរុបជាង ១៤ លានដុល្លារអាមេរិក ក្នុងរយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ ២០១៩ នេះតទៅដោយផ្ដោតសំខាន់លើវិស័យសុខុមាលភាពកុមារ និងកុមារអនាថានៅកម្ពុជា។

លោក គួច ចាន់នី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស និងជាអ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលបានដឹកនាំការចុះកិច្ចព្រមព្រៀងនេះកាលពីថ្ងៃទី ១៤ ខែតុលា ជាមួយតំណាងអង្គការទាំងនេះបានថ្លែងថា កិច្ចព្រមព្រៀងជាមួយអង្គការទាំង ១៣ ក្នុងទំហំទឹកប្រាក់សរុប ១៤ ២៨៣ ៨៣៦ ដុល្លារអាមេរិក សម្រាប់ប្រើប្រាស់ក្នុងរយៈពេល ៣ ឆ្នាំ។ ទិសដៅនៃកិច្ចសហការនេះគឺដើម្បីជួយក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ លោកថ្លែងថាៈ «ការចូលរួមសហការរបស់អង្គការដៃគូពិតជាសំខាន់ណាស់ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចនៅកម្ពុជា។ ការចុះកិច្ចព្រមព្រៀងនេះបានផ្ដោតលើការងារសំខាន់ចំពោះសុខុមាលភាពកុមារបម្រើផលប្រយោជន៍ដល់កុមារដែលជាជនរងគ្រោះ និងសមស្របទៅតាមគោលនយោបាយរបស់ក្រសួងផងដែរ»។

លោក គួច ចាន់នី បានបន្ថែមថាការងាររបស់អង្គការទាំង ១៣ ដោយផ្ដោតការជួយសុខុមាលភាពកុមារនេះមានដូចជាការជួយសង្គ្រោះកុមារអនាថាដែលគ្មានទីលំនៅច្បាស់លាស់នៅតាមទីសាធារណៈជាដើម។ មន្ត្រីនាំពាក្យរូបនេះបានស្នើឲ្យក្រុមការងារក្រសួង និងអង្គការដែលសហការនាពេលនេះរួមគ្នា ដើម្បីធ្វើការងារដោយយកចិត្តទុកដាក់ឲ្យខ្លាំងបំផុតតាមដែលអាចធ្វើបាន។ សម្រាប់ក្រសួងសង្គមកិច្ចវិញនៅតែស្វាគមន៍ជានិច្ចជាមួយដៃគូពាក់ព័ន្ធ ដើម្បីជួយដល់ជនរងគ្រោះ ងាយរងគ្រោះនៅកម្ពុជាឲ្យមានជីវភាព និងជីវិតរស់នៅល្អប្រសើរថែមមួយកម្រិតទៀត។ លោកបន្ថែមថាៈ «រាល់អង្គការដៃគូទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង សូមធ្វើប្រតិបត្តិការទៅតាមលក្ខខណ្ឌ ហើយសុំធ្វើតែកិច្ចការសង្គមតែប៉ុណ្ណោះ មិនត្រូវធ្វើការងារនយោបាយឡើយ។ ប្រសិនបើក្រសួងរកឃើញថាអង្គការណាមួយមិនបានគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង យកការងារសង្គមមកធ្វើជាការងារនយោបាយ ក្រសួងនឹងបញ្ចប់កិច្ចព្រមព្រៀងភ្លាម និងឈានដល់បញ្ឈប់សកម្មភាព»។

លោក ដួង សុភា ប្រធានរដ្ឋបាលនៃអង្គការជំរំកុមារដែលម៉ុនកម្ពុជា (FOYER INFANT DEL MON CAMBODGE) ដែលជាអង្គការមួយក្នុងចំណោមអង្គការទាំង ១៣ បានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ចកាលពីថ្ងៃចន្ទបានថ្លែងពីម្សិលមិញថា អង្គការជំរំកុមារដែលម៉ុនកម្ពុជាមានមូលដ្ឋាននៅខេត្តបន្ទាយមានជ័យ។ តាមរយៈគម្រោង ៣ ឆ្នាំនេះអង្គការនឹងប្រើប្រាស់ថវិកាជាង ៣០ ម៉ឺនដុល្លារអាមេរិក ដើម្បីជួយលើសុខុមាលភាពកុមារ។ លោកបញ្ជាក់ថាៈ «កិច្ចសហការថ្មីជាមួយក្រសួងនេះ អង្គការយើងនឹងធ្វើការងារមួយចំនួនលើការថែទាំសុខុមាលភាពកុមារដូចជាការចិញ្ចឹមក្មេងៗអនាថានៅក្នុងមណ្ឌលរបស់យើងដោយមានរយៈពេលវែង។ យើងក៏មានការចូលរួមជួយដល់ការបំប៉នសិស្សនៅក្នុងសហគមន៍ផងដែរ»។ លោក សុភា ឲ្យដឹងថា កិច្ចសហការជាមួយក្រសួងសង្គមកិច្ចកាលពីថ្ងៃចន្ទកន្លងទៅនេះគឺជាកិច្ចសហការលើកទី ៣ ហើយដែលអង្គការរបស់លោកបានចូលរួមការងារលើសុខុមាលភាពកុមារ។ ជួយសង្គ្រោះដល់កុមារក្រីក្រ កុមារកំព្រាឲ្យទទួលបានការស្នាក់នៅ ផ្គត់ផ្គង់អាហារ សម្លៀកបំពាក់ និងការអប់រំដល់ពួកគេជាដើម។

តាមការប្រកាសរបស់ក្រសួងសង្គមកិច្ច អង្គការទាំង ១៣ ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ចនោះរួមមាន ១. អង្គការសាកលវិទ្យាល័យអន្តរជាតិសម្រាប់ប្រជាជាតិ ២. អង្គការ មិត្តសំឡាញ់ ៣. អង្គការថែរក្សា និងអប់រំមនុស្សសម្រាប់កម្ពុជា ៤. អង្គការ អភិវឌ្ឍន៍ចំរូតនៃជាតិខ្មែរ ៥. អង្គការ Friends International ៦. អង្គការ

ហូលចំអន្តរជាតិ ៧. អង្គការសង្គ្រោះ និងអភិវឌ្ឍន៍កុមារកំព្រា ស្ត្រីមេម៉ាយ ៨. អង្គការជម្រកគ្មានទីពឹង ៩. អង្គការកុមារកូនកសិករ ១០. អង្គការមូលនិធិអឺរ៉ុបសម្រាប់កុមារកម្ពុជា ១១. អង្គការ ជំរំកុមារដែលមុំនកម្ពុជា ១២. អង្គការ Safe Place Mission និងទី ១៣. អង្គការ Cambodia Neighbor៕

## ឯកអគ្គរាជទូតជប៉ុន ប្ដេជ្ញាបង្កើនទីផ្សារការងារសម្រាប់ពលករខ្មែរធ្វើការនៅជប៉ុន

https://www.postkhmer.com/ រី សុចាន់ | Publication date 15 October 2019 | 09:10 ICT

**ភ្នំពេញៈ** ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាដែលទើបចូលកាន់តំណែងបានប្ដេជ្ញាខិតខំប្រឹងប្រែងបង្កើនទីផ្សារការងារឱ្យកាន់តែច្រើនថែមទៀតដល់ប្រជាពលរដ្ឋកម្ពុជា ដែលមានបំណងចង់ទៅធ្វើការនៅប្រទេសជប៉ុន ខណៈដែលកម្ពុជានឹងខិតខំបង្កលក្ខណៈងាយស្រួលក្នុងការបំពេញសំណុំបែបបទផ្សេងៗ។ នេះបើតាមមន្ត្រីជាន់ខ្ពស់ក្រសួងការងារ។ ការបញ្ជាក់របស់ឯកអគ្គរាជទូតជប៉ុនលោក MIKAMI Masahiro នេះបានធ្វើឡើងនៅក្នុងជំនួបរវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកាលពីថ្ងៃចន្ទម្សិលមិញ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានថ្លែងប្រាប់អ្នកកាសែតក្រោយជំនួបនោះថាជប៉ុននឹងបន្តបើកទីផ្សារការងារបន្ថែមទៀត សម្រាប់ពលករ និងកម្មសិក្សាការីកម្ពុជា និងផ្តល់ឱកាសសម្រាប់បន្តការបណ្តុះបណ្តាលនៅជប៉ុនផងដែរ។ តាមរយៈកំណែទម្រង់ច្បាប់នៅប្រទេសជប៉ុនកម្មសិក្សាការី ឬពលករជំនាញដែលត្រូវធ្វើការនៅប្រទេសជប៉ុននេះ គឺមិនតម្រូវថាត្រូវតែជាអ្នកកំពុងធ្វើការនៅក្នុងសហគ្រាសគ្រឹះស្ថានណាមួយនោះទេ ហើយពេលវេលានៃការធ្វើការនៅទីនោះក៏មានរយៈពេលវែងជាងមុនដែរ។ លោក ហេង សួរ ថ្លែងថា៖ «រីឯរយៈពេលនៃការបញ្ជូនក៏យើងបានខិតខំកាត់បន្ថយ ដោយសារទីមួយ យើងមិនមានតម្រូវការនៃការបញ្ជាក់អំពីបែបបទ ឬក៏បទពិសោធការងារដូចមុននោះទេ។ ប៉ុន្តែនេះគឺជាបែបបទរួមដែលជប៉ុនបានធ្វើហើយបែបបទដែលពាក់ព័ន្ធជាមួយនឹងភាគីកម្ពុជាគឺយើងខិតខំធ្វើម៉េចឱ្យបែបបទនេះកាន់តែខ្លី កាន់តែងាយស្រួល សម្រាប់បងប្អូនប្រជាពលរដ្ឋរបស់យើង ដែលមានបំណងចង់ធ្វើកម្មសិក្សានៅទីនោះ»។ លោកបន្តថាសម្រាប់កម្មសិក្សាការីដែលកំពុងធ្វើការនៅសហគ្រាសណាមួយ ឬមិនកំពុងធ្វើការទេនោះហើយប្រសិនបើពួកគាត់មានវិញ្ញាបនបត្រជំនាញណាមួយ ហើយបន្ទាប់មកមានចំណេះដឹងភាសាជប៉ុនហើយដាក់ពាក្យស្វែងរកការងារធ្វើតាមទីភ្នាក់ងារស្របច្បាប់ដែលទទួលស្គាល់ដោយក្រសួងការងាររបស់កម្ពុជា ភាគីនិយោជកជប៉ុននឹងមកធ្វើសម្ភាសហើយបើសម្ភាសជាប់គឺនឹងបានទៅធ្វើការនៅជប៉ុន។ លោកបញ្ជាក់ថា៖ «ក្រសួងគឺនឹងសម្របសម្រួលធ្វើម៉េចគ្រប់គ្រងទីភ្នាក់ងារស្របច្បាប់ឱ្យបានល្អ រីឯការសម្រេចជ្រើសរើសគឺនៅលើនិយោជកជប៉ុនផ្ទាល់ ដោយផ្អែកទៅលើការធ្វើតេស្តសម្ភាសរបស់និយោជកជាមួយនឹងអ្នកដែលមានបំណងទៅធ្វើការនៅទីនោះ»។

ហ្វេសប៊ុកក្រសួងការងារកាលពីម្សិលមិញបានដកស្រង់សម្ដីលោក MIKAMI Masahiro ថាតំណាងក្រុមហ៊ុនរបស់ជប៉ុន ដូចជាក្រុមហ៊ុនអ៊ីអននៅកម្ពុជាជាដើមបានកោតសរសើរពីការខិតខំប្រឹងប្រែងធ្វើការរបស់បុគ្គលិកកម្ពុជា ព្រោះមានភាពអត់ធ្មត់ ឧស្សាហ៍ព្យាយាម និងស្មោះត្រង់ចំពោះការងារ។ ហ្វេសប៊ុកក្រសួងការងារបន្តថា៖ «មិនតែប៉ុណ្ណោះឯកអគ្គរាជទូតជប៉ុនបានសន្យាថា នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយរាជរដ្ឋាភិបាលកម្ពុជាឱ្យកាន់តែរឹងមាំថែមទៀត មិនថានៅប្រទេសជប៉ុន ឬនៅប្រទេសកម្ពុជា នោះឡើយ»។ ហ្វេសប៊ុកក្រសួងការងារក៏បានដកស្រង់សម្ដីលោក អ៊ិត សំហេង ថាកម្មសិក្សាការីកម្ពុជាដែលបានទៅធ្វើកម្មសិក្សា និងបម្រើការងារនៅប្រទេសជប៉ុនមានចំនួនប្រមាណ ១ ម៉ឺន ២ ពាន់នាក់។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស (Central) បានថ្លែងថា វាជាឱកាសសម្រាប់ពលរដ្ឋកម្ពុជាក្នុងការចាប់យកជំនាញផ្សេងៗដែលមានការរៀនជំនាញផងហើយទទួលបានប្រាក់បៀវត្សរ៍ទៀត។ ប៉ុន្តែលោកបានចោទសួរថា តើរដ្ឋាភិបាលកម្ពុជាបានគិតដែរឬទេថា តើប៉ុន្មានឆ្នាំទៅមុខទៀតកម្ពុជាត្រូវការពលរដ្ឋនៅក្នុងជំនាញណា? ឧទាហរណ៍ដូចជាជំនាញខាងផ្នែកអេឡិចត្រូនិក ឬផ្នែកកសិកម្ម។ «កម្មសិក្សាការីទៅ

ដល់ប្រទេស ជប៉ុន គឺតម្រូវឱ្យធ្វើការដូចពលករទូទៅអ៊ីចឹង។ យើងហៅគាត់ថា ជាកម្មសិក្សាការី ប៉ុន្តែលក្ខខណ្ឌការងាររបស់គាត់ពិតប្រាកដ គឺដូចពលករទូទៅ ហើយប្រសិនជាអ៊ីចឹង គាត់គួរតែត្រូវបានប្រាក់ឈ្នួលដូចពលករទូទៅ»។ លោកថ្លែងថាលោកមើលឃើញមានការកើនឡើងនូវរោងចក្រអេឡិចត្រូនិក និងរោងចក្រកង់នៅក្នុងប្រទេសកម្ពុជា។ ពលរដ្ឋកម្ពុជាគួរតែត្រូវបានបញ្ជូនឱ្យទៅរៀនជំនាញទាំងនេះហើយនៅថ្ងៃក្រោយនៅពេលជប៉ុនមកបើករោងចក្រទាំងនេះនៅកម្ពុជា កម្ពុជានឹងមានកម្មករជំនាញដើម្បីធ្វើការងារទាំងនោះ៕

## ពលរដ្ឋខ្មែរជាង ១ម៉ឺន ២ពាន់នាក់ហើយកំពុងធ្វើកម្មសិក្សា និងធ្វើការនៅជប៉ុន

http://kleykley.sabay.com.kh/ ច័ន្ទ, 14 តុលា 2019 15:38

លោក អិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា កម្មសិក្សាការីកម្ពុជាដែលបានទៅធ្វើកម្មសិក្សា និងបម្រើការងារនៅប្រទេសជប៉ុន មានចំនួនប្រមាណ ១ម៉ឺន ២ពាន់នាក់ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩នេះ។ ការលើកឡើងនេះនៅក្នុងជំនួបជាមួយ លោក MIKAMI Masahiro ឯកអគ្គរាជទូតថ្មីប្រចាំនៅកម្ពុជា កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង។

ក្នុងជំនួបនេះដែរ ឯកអគ្គរាជទូតជប៉ុនបានសន្យាថា នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយរាជរដ្ឋាភិបាលកម្ពុជាឱ្យកាន់តែរឹងមាំថែមទៀត មិនថានៅប្រទេសជប៉ុន ឬនៅប្រទេសកម្ពុជានោះឡើយ។ លោកក៏បានមើលឃើញអំពីសារៈសំខាន់ នៃការប្រកួតប្រជែងលើវិស័យឧស្សាហកម្មរបស់កម្ពុជា ដោយឯកឧត្តមបានប្តេជ្ញាថានឹងជួយពង្រឹង និងពង្រីកឧត្តមភាពប្រកួតប្រជែងលើវិស័យឧស្សាហកម្មរបស់កម្ពុជា ឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត។

គួសបញ្ជាក់ដែរថា កម្ពុជាបានបញ្ជូនពលករជំនាញលើកដំបូងទៅបម្រើការនៅជប៉ុនចំនួន ១១នាក់ ក្រោយអនុស្សារណៈនៃការយោគយល់គ្នារវាងកម្ពុជា-ជប៉ុន លើការបញ្ជូននិងទទួលពលករជំនាញ ត្រូវបានចុះហត្ថលេខារួចរាល់ផងដែរ៕ អត្ថបទ៖ ម៉េងឌី

## ខ្មែរម្នាក់នៅកូរ៉េត្រូវបានថៅកែធ្វើបាប និងមិនបើកប្រាក់ឈ្នួលឲ្យគ្រប់ចំនួន

https://www.postkhmer.com/ វី សុចាន់ | Publication date 15 October 2019 | 14:56 ICT

**កូរ៉េ:** ស្ត្រីពលករខ្មែរម្នាក់ដែលកំពុងធ្វើការនៅប្រទេស កូរ៉េខាងត្បូង បានអះអាងថា នាងត្រូវថៅកែស្រីធ្វើបាប និងមិនបើកប្រាក់ឈ្នួលឲ្យគ្រប់ចំនួន ទៅតាមកម្លាំងពលកម្ម ហើយនាងបានអំពាវនាវឲ្យមានការជួយអន្តរាគមន៍ឲ្យនាងបានទៅធ្វើការនៅកន្លែងផ្សេង។

កញ្ញា រឹម ស្រីរ៉ុម ដែលធ្វើការគិតជាប្រាក់ម៉ោងបានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃចន្ទថា ថៅកែរបស់នាងបានរុញច្រាននាងដេរស្តី និងមិនឱ្យនាងពាក់មួក និងពាក់ស្រោមដៃសម្រាប់ទប់ទល់នឹងអាកាសធាតុដែលត្រជាក់ខ្លាំងនោះទេ។ ថៅកែក៏បានយកកន្ត្រកសម្រាប់ដាក់បន្លែរុញលើជើងនាងបណ្តាលឱ្យមានស្នាមជាំផងដែរ។ កញ្ញា រឹម ស្រីរ៉ុម ថ្លែងថា៖ «ខ្ញុំពិបាកខ្លាំងណាស់រាល់ថ្ងៃនេះ។ ខ្ញុំខំប្រឹងធ្វើការដែរតែថៅកែអត់ពេញចិត្ត ព្រោះអីខ្ញុំទើបនឹងមកថ្មី។ ខ្ញុំបេះ (បន្លែ) អត់បាន ១ ៧០០ (ទៅ) ១ ៨០០ (ក្នុង ១ ថ្ងៃ) ដូចអ្នកចាស់អ៊ីចឹងណា។ ខ្ញុំអាចបេះបាន ១ ០០០។ អ៊ីចឹងហើយទើបយាយ (ថៅកែ) ហ្នឹងគាត់រុញច្រានខ្ញុំ ចេះតែក្តៅចិត្តជាមួយខ្ញុំ»។ កញ្ញាបានបន្ថែមថា៖ «គាត់ដេញឱ្យខ្ញុំទៅដេក អត់ឱ្យខ្ញុំធ្វើការ។ ថ្ងៃណា គាត់ពេញចិត្តឱ្យធ្វើការ គាត់ដេញឱ្យទៅធ្វើការតាំងពីម៉ោង ១២ កន្លះថ្ងៃ ខណៈម៉ោងត្រូវចូលធ្វើការម៉ោង ១។ ថៅកែហ្នឹងគាត់អត់យល់ទេ។ គាត់ថា យើងធ្វើម៉េចឱ្យតែបានទៅធ្វើការឱ្យគាត់។ តាមពិតវាអត់ទាន់ដល់ម៉ោង»។ កញ្ញា ស្រីរ៉ុម ដែលបម្រើការងារខាងផ្នែកកសិកម្មបញ្ជាក់ថាកញ្ញាចង់បានអ្នកប្រឹក្សាយោបល់

ម្នាក់ដែលអាចជួយឱ្យកញ្ញាបានចាកចេញពីកន្លែងការងារបច្ចុប្បន្នេះដោយស្របច្បាប់ដោយមិនអស់ប្រាក់ ឬអស់ប្រាក់តិចតួច ហើយទៅរកការងារធ្វើនៅកន្លែងផ្សេង។

កញ្ញាថា ការងារនៅប្រទេស កូរ៉េ មិនសូវជាហត់នឿយប៉ុន្មាននោះទេ។ ទោះបីជាហត់នឿយ ក៏ត្រូវទ្រាំដែរ ព្រោះប្រាក់ខែនៅទីនោះក៏ទទួលបានខ្ពស់ដែរ។ «សំខាន់ឱ្យតែថៅកែយល់ចិត្តយើង។ យើងទើបមកថ្មី។ យើងប្រាប់ថា យើងអត់ចេះអីទេ។ យើងអត់ដែលធ្វើអាហ្នឹងនៅខ្មែរហើយយើងនឹងខំប្រឹងប្រែង»។ កញ្ញា ស្រីរ៉ុម បន្តថា ក្រោយកញ្ញាចូលធ្វើការបានរយៈពេល ៤២ ថ្ងៃ ហើយដល់ថ្ងៃបើកប្រាក់ឈ្នួលថៅកែមិនបានបើកប្រាក់ឈ្នួលនោះឱ្យនាងគ្រប់ចំនួននោះទេ។ ថៅកែបានបើកប្រាក់ឈ្នួលឱ្យនាងបានតែ ៦៣០ ០០០ វ៉ុនប៉ុណ្ណោះ (ជាង ៥០០ ដុល្លារ) ដែលកញ្ញាអះអាងថា កញ្ញាត្រូវទទួលប្រាក់ឈ្នួលក្នុងរយៈពេលនេះរហូតដល់ទៅជាង ១ ០០០ ដុល្លារអាមេរិក។ កញ្ញាបានបន្ថែមថា៖ «គាត់ (ថៅកែ) និយាយថាបើសិនជាខ្ញុំនៅតែធ្វើការអត់បានល្អឱ្យគាត់ទៀត គាត់នឹងស៊ីញ៉េដេញខ្ញុំចេញ។ បន្ទាប់មកទៀតខ្ញុំប្រាប់ថា ខ្ញុំចង់ចេញ ខ្ញុំចង់ចេញ គាត់ទារ ៨០០ ០០០ វ៉ុនកូរ៉េ (ជាង ៦០០ ដុល្លារអាមេរិក)»។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃចន្ទថា ទីប្រឹក្សាទទួលបន្ទុកពលកររបស់កម្ពុជាអមនៅស្ថានទូតនៅប្រទេស កូរ៉េខាងត្បូង ក៏ដូចជាស្ថានឯកអគ្គរាជទូតកម្ពុជាទាំងមូលនៅឯទីក្រុងសេអ៊ូល បានទទួលនូវព័ត៌មាននេះ ហើយក៏កំពុងស៊ើបអង្កេតករណីនេះជាមួយនឹងអាជ្ញាធរប្រទេសកូរ៉េ។

លោក យុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ បានប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃចន្ទថា ពលករគួរស្វែងរកជំនួយនៅនាយកដ្ឋានអធិការកិច្ចរបស់កូរ៉េ និងស្ថានទូតកម្ពុជានៅប្រទេសកូរ៉េ ដែលកន្លងមកមានការផ្ដល់សេវាប្រសើរដែលមានផ្ដល់លេខទូរស័ព្ទហតឡាញ (Hotline) សម្រាប់ទំនាក់ទំនង។ លោក យុន ថារ៉ូ បន្ថែមថា៖ «នៅក្នុងក្របខ័ណ្ឌបញ្ជូន (ពលករ) ក្រសួង (ការងារ) អាចត្រួតពិនិត្យ និងអធិការកិច្ចទៅនឹងទីភ្នាក់ងារបញ្ជូនហ្នឹងទៅ។ បញ្ជូនគាត់ទៅក្រុមហ៊ុនណា? មួយណាច្បាស់លាស់។ ទីតាំង និងទីកន្លែង (ណា?) ព្រោះគាត់ (ក្រសួង) មានព័ត៌មានទាំងអស់នេះ...។ ប្រសិនជាគាត់ (ក្រសួង) មានស្ថានទូតនៅទីនោះ។ គាត់ធ្វើការជិតស្និទ្ធជាមួយគ្នាអ៊ីចឹង ខ្ញុំគិតថាគាត់អាចអន្តរាគមន៍បាន»៕

# ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៩

## គណៈមេធាវីគ្រោងបង្កើតស្នាក់ការនៅបរទេសសម្រាប់ការពារពលករខ្មែរ

https://kohsantepheapdaily.com.kh/ ថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៩ ម៉ោង ១១:៣១ ស.សុខុម (អ៊ាង ម៉េងឡេង)

រាជធានីភ្នំពេញ ៖ ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងនៅក្នុងមហាសន្និបាតលើកទី២៤ ក្នុងការពង្រឹងវិជ្ជាជីវៈមេធាវីប្រចាំឆ្នាំ២០១៩ថា គណៈមេធាវីគ្រោងបង្កើតការិយាល័យនៅឯបរទេសនាឆ្នាំក្រោយ ដើម្បីការពារពលករខ្មែរដែលកំពុងធ្វើការនៅឯបរទេស ។ ថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីព្រឹកទី១៦ ខែតុលា នៅក្នុងមហាសន្និបាតលើកទី២៤របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លោក សួន វិសាល ប្រធានគណៈមេធាវីបានបញ្ជាក់ថា មហាសន្និបាតឆ្នាំនេះមានលក្ខណៈខុសប្លែកពីឆ្នាំមុនបន្តិច ដោយមានការអញ្ជើញវាគ្មិនមានជំនាញមកធ្វើបទបង្ហាញ ដើម្បីស្វែងរកបញ្ហាប្រឈម ពង្រឹងសមត្ថភាព និងវិជ្ជាជីវៈមេធាវីផងដែរ ។

លោក សួន វិសាល បានបន្តទៀតថាមហាសន្និបាតនេះក៏មានគោលបំណងទៅខាងមុខដើម្បីធ្វើយ៉ាងណាឲ្យមេធាវីកម្ពុជាមានសមត្ថភាពអាចប្រកួតប្រជែងជាមួយមេធាវីបរទេសបាននិងព្យាយាមពង្រីកដល់ទីផ្សារអន្តរជាតិ ។ ទោះបីជាបែបណា ពេលនេះគណៈមេធាវីមិនទាន់ចាត់តាំងមេធាវីកម្ពុជាទៅកាន់ការិយាល័យមេធាវីបរទេសឬទៅកាន់

ប្រទេសណាមួយនៅឡើយទេ ដោយកំពុងពង្រឹងសមត្ថភាពជាមុនសិន ។ លោក សួន វិសាល បានបញ្ជាក់ថា កាលពីឆ្នាំមុន គណៈមេធាវីបានទទួលព័ត៌មានពីបញ្ហាប្រឈមរបស់មេធាវីក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនបើប្រៀបធៀបនឹងមេធាវីបរទេស ។ លោក សួន វិសាល អះអាងថា មហាសន្និបាតនេះ ក៏បានសម្រេចក្នុងការបង្កើតការិយាល័យមេធាវីកម្ពុជានៅឯបរទេស ដើម្បីការពារពលករខ្មែរនៅបរទេស ។ លោកលើកឡើងថា ការិយាល័យមេធាវីអាចបើកនៅប្រទេសថៃ កូរ៉េ ម៉ាឡេស៊ីជាដើម ពីព្រោះកន្លងមកលោកបានដឹងថាពលករខ្មែរយើងទៅធ្វើការងារនៅទីនោះមានចំនួនច្រើន ។ លោក សួន វិសាល បន្តទៀតថា បញ្ហាលើកឡើងខាងលើកនេះ ស្របតាមស្មារតីនិងគោលនយោបាយរបស់ប្រមុខរាជរដ្ឋាភិបាលសម្ដេចតេជោ ហ៊ុន សែន ក្នុងការជួយប្រជាពលរដ្ឋខ្មែរ។ក្រោមការឧបត្ថម្ភពីសម្ដេចតេជោ ដើម្បីការពារប្រជាពលរដ្ឋកម្ពុជាយើង ទោះបីនៅទីណាក៏ ដោយ ហើយការិយាល័យមេធាវីនៅបរទេសនឹងមាននៅឆ្នាំ ២០២០ ។

បច្ចុប្បន្ន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានមេធាវីពេញសិទ្ធិ១.៤៦០រូប និងមេធាវីកម្មសិក្សា(មិនទាន់ពេញសិទ្ធិ)ជាង៤០០រូបសរុបជាង១.៧០០រូប តែក៏មានមេធាវីកំពុងប្រកបវិជ្ជាជីវៈប្រមាណ១.០០០រូប ។ លោកបន្តថា ចំនួនមេធាវីកម្ពុជាបច្ចុប្បន្ននេះមិនទាន់សមាមាត្រទៅនឹងចំនួនប្រជាជនកម្ពុជាដែលមានជាង១៥លាននាក់នោះទេ បើប្រៀបធៀបនឹងប្រទេសជិតខាង ដូចជាថៃមាន៧០លាននាក់ តែថៃមានមេធាវីប្រមាណ៩ម៉ឺននាក់ ។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចូលអាណត្តិទី១២ក្នុងការការពារកូនក្ដីនៅតាមពន្ធនាគារទូទាំង២៥រាជធានី-ខេត្ត ហើយរាជរដ្ឋាភិបាលបានផ្ដល់ថវិកាទ្រទ្រង់ចំនួន១.៦០០លានរៀលដល់គណៈមេធាវី ដើម្បីផ្ដល់ដល់មេធាវីការពារក្ដីជនក្រីក្រដោយមិនគិតថ្លៃក្នុងមួយករណី៤០ម៉ឺនរៀល ៕

## រដ្ឋមន្ត្រីក្រសួងការងារអនុញ្ញាតឲ្យវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្របង្រៀនភាសាកូរ៉េ និងជប៉ុន ដើម្បីឆ្លើយតបទៅតាមទីផ្សារការងារ

http://kampucheathmey.com/ 16/10/2019 7:07 Pm

ភ្នំពេញ ៖ លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុញ្ញាតឲ្យវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្របន្ថែមការបណ្ដុះបណ្ដាលភាសាកូរ៉េ និងជប៉ុន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត ពិសេសគឺឆ្លើយតបទៅនឹងការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ក្រោយមានការស្នើសុំផ្ទាល់ពីនាយកវិទ្យាស្ថានជាតិមួយនេះ។ ការអនុញ្ញាតឲ្យមានការបន្ថែមការបណ្ដុះបណ្ដាលភាសាបរទេសខាងលើនេះ ត្រូវបានធ្វើឡើងក្នុងឱកាសដែលលោកបណ្ឌិត អ៊ិត សំហេង អញ្ជើញសំណេះសំណាលជាមួយសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកនៃវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ស្ថិតក្នុងសង្កាត់ស្ទឹងមានជ័យ១ ខណ្ឌមានជ័យកាលពីព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។ ក្រៅពីនោះ លោករដ្ឋមន្ត្រីក៏បានឲ្យវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រពិចារណាបន្ថែមការបណ្ដុះបណ្ដាលជំនាញសេវាកម្មទេសចរណ៍ ទំនាក់ទំនងអន្តរជាតិ និងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិផងដែរ។

នាឱកាសនោះ លោករដ្ឋមន្ត្រីក៏បានផ្ដល់អនុសាសន៍មួយចំនួនដល់វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ត្រូវពង្រីកសមត្ថភាពបង្រៀនរបស់គ្រូ និងសាស្ត្រាចារ្យ ពីកម្រិតបរិញ្ញាបត្រទៅដល់កម្រិតអនុបណ្ឌិត និងបណ្ឌិត តាមរយៈការសិក្សាបន្តនៅក្នុងប្រទេស ពិសេសនៅក្រៅប្រទេស។ ក្រៅពីនេះ ត្រូវបន្តពង្រឹងបរិយាកាសការងារ និងសាមគ្គីភាពផ្ទៃក្នុងឲ្យបានល្អថែមទៀត ត្រូវមានវិធីសាស្ត្រគ្រប់គ្រងដឹកនាំ ប្រកបដោយតម្លាភាព គណនេយ្យភាព តាមទ្រឹស្ដី «ទឹកត្រជាក់ត្រីកុំ» ព្រមទាំងបន្តអនុវត្តតាមអភិក្រម «មុជទឹក ដុះក្អែល ឆ្លុះកញ្ចក់ ព្យាបាល វះកាត់» និងពង្រីកដៃគូនៅក្រៅប្រទេស ទស្សនាកិច្ចសិក្សា ផ្លាស់ប្ដូរគ្រូ និងរៀបចំឱ្យមានកម្មសិក្សាដល់សិស្សទាំងក្នុង និងក្រៅប្រទេសថែមទៀត។ លោកបណ្ឌិតអ៊ិត សំហេង ក៏បានថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ គ្រូ បុគ្គលិកសិក្សា សិស្សនិស្សិតក្នុងវិទ្យាស្ថាន

ដែលបានចូលរួមការពារសុខសន្តិភាព ស្ថិរភាពនយោបាយជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ពិសេសសូមកុំចូលរួមជាមួយក្រុមមួយក្តាប់តូច ដែលព្យាយាមបំផ្លិចបំផ្លាញសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរបស់កម្ពុជា។

គួរបញ្ជាក់ថា ការចុះពិនិត្យផ្ទាល់នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រនេះ គឺជាលើកទី៣ហើយ បន្ទាប់ពីស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈខេត្តកំពង់ស្ពឺ។ ការចុះតាមគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនេះ គឺធ្វើឡើងស្របពេលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននឹងកំពុងអនុវត្តយុទ្ធសាស្ត្រទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) និងដាក់ចេញអនុសាសន៍ជំរុញឲ្យគ្រឹះស្ថានអប់រំទាំងអស់ ដែលស្ថិតក្រោមឱវាទរបស់ខ្លួន ត្រូវយកចិត្តទុកដាក់អនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាពទៅដល់សិក្ខាកាម ដើម្បីឆ្លើយតបនឹងការរីកចម្រើនបច្ចេកវិទ្យាទំនើប ឬបដិវត្តឧស្សាហកម្ម ៤.០។ គោលបំណងនៃការចុះតាមគ្រឹះស្ថានបណ្តុះបណ្តាលនេះ ដើម្បីជំរុញលើកទឹកចិត្តក្នុងការអនុវត្តនូវគោលនយោបាយជាតិស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ និងអនុវត្តទៅតាមផែនការអាទិភាពទី២ ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ដែលពង្រឹងបន្ថែមទៅលើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)៕ សំអឿន

## សហគមន៍អាស៊ីអាមេរិកាំងសហការគ្នាប្រឆាំងនឹងការចាប់ខ្លួនជនជាតិខ្មែរបញ្ជូនទៅកម្ពុជា

https://khmer.voanews.com/ 17 តុលា 2019 ទែន សុខស្រីនិត

វ៉ាស៊ីនតោន៖ កាលពាក់កណ្តាលឆ្នាំ២០១៧ អ្នកស្រី ជុំ ម៉ុនថា (Montha Chum) ដែលជាពលរដ្ឋអាមេរិកាំងដើមកំណើតខ្មែរមួយរូប រស់នៅរដ្ឋមីនីសូតា បានឈរនិយាយទៅកាន់សមាជិកនៃសហគមន៍អាស៊ីអាមេរិកាំងនៅមុខសេតវិមានប្រចាំរដ្ឋធានីវ៉ាស៊ីនតោន ជាលើកដំបូង ដើម្បីទាមទាររកយុត្តិធម៌ជូនប្អូនប្រុសរបស់អ្នកស្រី ដែលត្រូវបានមន្ត្រីគយនិងអន្តោប្រវេសន៍ (U.S. Immigration and Customs Enforcement) ឬហៅកាត់ថា ICE ឃុំខ្លួនដើម្បីបញ្ជូនទៅប្រទេសកម្ពុជា ដោយសារតែប្រវត្តិប្រព្រឹត្តឧក្រិដ្ឋកម្ម។ ការតវ៉ារបស់អ្នកស្រី រួមជាមួយនឹងសហគមន៍ខ្មែរនៅរដ្ឋមីនីសូតាអស់រយៈពេលជាងពីរឆ្នាំនោះ បានទទួលជោគជ័យ ដោយប្អូនប្រុសរបស់អ្នកស្រីគឺលោក ផាន ចំរើន (Chamroeun Phan) ត្រូវបានចៅក្រមនៃតុលាការអន្តោប្រវេសន៍ សម្រេចលុបចោលដីកាចាប់ខ្លួនលោកបញ្ជូនទៅប្រទេសកម្ពុជា ហើយអនុញ្ញាតឲ្យលោកទទួលបានសិទ្ធិរស់នៅដោយស្របច្បាប់នៅអាមេរិក ដោយផ្អែកលើសម្អាងថាលោក ផាន ចំរើន បានកែខ្លួន ហើយការចាប់បញ្ជូនខ្លួនរូបលោកទៅប្រទេសកម្ពុជា អាចនឹងបង្កផលវិបាកធ្ងន់ធ្ងរដល់ក្រុមគ្រួសារលោកនៅសហរដ្ឋអាមេរិក។

លោក ផាន ចំរើន ត្រូវបានចោទប្រកាន់ពីបទល្មើសមួយចំនួន រួមមានទាំងបទបង្កឲ្យមានការខូចខាតទ្រព្យសម្បត្តិសាធារណៈ កាលពីឆ្នាំ២០០៩។ លោកត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ ក៏ប៉ុន្តែលោកត្រូវបានដោះលែងមុនពេលកំណត់ដោយសារតែអាកប្បកិរិយាល្អ ដោយបានជាប់ឃុំរយៈពេល៤០ថ្ងៃប៉ុណ្ណោះ។ ទាំងអ្នកស្រី ជុំ ម៉ុនថា និងលោក ផាន ចំរើន ដែលសព្វថ្ងៃរស់នៅទីក្រុង Saint Paul រដ្ឋមីនីសូតា បានកើតនៅជំរំជនភៀសខ្លួនខាវអ៊ីដាង ប្រទេសថៃ នៅពេលដែលឪពុកម្តាយរបស់អ្នកទាំងពីរបានភៀសខ្លួនពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅចុងពាក់កណ្តាលទសវត្សរ៍១៩៧០។ យ៉ាងណាមិញ ពីរឆ្នាំក្រោយពីការតវ៉ារបស់អ្នកស្រីបានជោគជ័យ គេនៅតែឃើញ អ្នកស្រី ជុំ ម៉ុនថា ចូលរួមតវ៉ាជាមួយសមាជិកនៃសហគមន៍អាស៊ីអាមេរិកាំងផ្សេងៗទៀត រួមមានវៀតណាមនិងឡាវ នៅមុខការិយាល័យអាជ្ញាធរគយនិងអន្តោប្រវេសន៍ នៅទីក្រុង Sacramento រដ្ឋកាលីហ្វ័រញ៉ា។ នៅក្នុងបទ

សម្ភាសន៍តាមទូរស័ព្ទជាមួយ VOA អ្នកស្រីបានបញ្ជាក់ពីមូលហេតុនៃការបន្តតវ៉ារកយុត្តិធម៌ដល់ជនជាតិខ្មែរផ្សេងៗទៀតថា៖ «[ការតវ៉ារកយុត្តិធម៌នេះ] បានអនុញ្ញាតឲ្យខ្ញុំក្លាយជាសំឡេងតំណាងឲ្យបងប្អូនជនជាតិខ្មែរជាច្រើនដែលមិនអាចបញ្ចេញសំឡេងតំណាងឲ្យសមាជិកគ្រួសាររបស់ពួកគេបាន។ ដូច្នេះ ការតវ៉ានេះគឺជាមធ្យោបាយមួយរបស់ខ្ញុំក្នុងការធ្វើការជំរុញឲ្យមានការផ្លាស់ប្ដូរគោលនយោបាយ ដើម្បីធ្វើយ៉ាងណាឲ្យក្រុមគ្រួសារខ្មែរបាននៅជួបជុំគ្នា។ ដោយសារតែនៅក្រោមរដ្ឋបាលនេះ ជនជាតិខ្មែរជាច្រើននាក់ត្រូវបានចាប់បញ្ជូនខ្លួន គឺកើនដល់ទៅ២២៩ភាគរយតាំងពីរដ្ឋបាលថ្មីនេះចូលកាន់តំណែង»។ ការតវ៉ាទ្រង់ទ្រាយធំមួយនេះបានធ្វើឡើងកាលពីដើមខែតុលានេះ ដោយមានការចូលរួមពីពលរដ្ឋជាង៥០០នាក់ មកពីសហគមន៍អាស៊ីអាមេរិកាំង នៅទីក្រុង Boston រដ្ឋម៉ាស្សាឈូសេត ទីក្រុង Sacramento និងទីក្រុង San Francisco រដ្ឋកាលីហ្វ័រញ៉ា និងនៅរដ្ឋ Rhode Island និងរដ្ឋវ៉ាស៊ីនតោន ដើម្បីតវ៉ាប្រឆាំងនឹងការអនុវត្តច្បាប់អន្តោប្រវេសន៍បែបអមនុស្សធម៌របស់អាជ្ញាធរគយនិងអន្តោប្រវេសន៍ មកលើសហគមន៍ជនជាតិខ្មែរ ដែលជាក្រុមអតីតជនភៀសខ្លួន ដែលធ្លាប់បានប្រព្រឹត្តបទល្មើសពីអតីតកាល បើទោះបីជាពួកគេបានជាប់ទោសរួចហើយក្ដី។

តាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៦ របស់សហរដ្ឋអាមេរិក (Illigal Immigration and Immigrant Responsibility Act of 1996) ជនអន្តោប្រវេសន៍ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងត្រូវបាត់បង់សិទ្ធិរស់នៅស្របច្បាប់នៅសហរដ្ឋអាមេរិក ហើយត្រូវប្រឈមនឹងការនិរទេសទៅប្រទេសដើមកំណើតរបស់ខ្លួនវិញ។ ហើយកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍រវាងសហរដ្ឋអាមេរិកនិងកម្ពុជា ចុះកាលពីឆ្នាំ២០០២ បានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចក្នុងការទទួលយកពលរដ្ឋខ្មែរដែលបានប្រព្រឹត្តខុសច្បាប់អន្តោប្រវេសន៍ ទៅប្រទេសកម្ពុជាតាមការស្នើសុំរបស់រដ្ឋាភិបាលអាមេរិក ដោយគ្មានករណីលើកលែង។

*អតីតជនភៀសខ្លួន៖ ភាពក្រីក្រ អវិជ្ជា ការប្រព្រឹត្តបទល្មើស*

ក៏ប៉ុន្តែ ភាពចម្រូងចម្រាសបានកើតមានឡើង នៅពេលដែលមន្ត្រីគយនិងអន្តោប្រវេសន៍បានរឹតបន្តឹងការអនុវត្តច្បាប់អន្តោប្រវេសន៍នេះ ដោយស្វែងរកចាប់ខ្លួនជនអន្តោប្រវេសន៍ដែលធ្លាប់បានប្រព្រឹត្តបទល្មើសពីអតីតកាល បើទោះបីជាពួកគេបានជាប់ទោសរួចហើយ និងបានកែប្រែខ្លួនរស់នៅក្នុងសង្គមដោយមិនបន្តប្រព្រឹត្តបទល្មើសទៀតក្ដី។ ហើយជនរងគ្រោះនៃការស្វែងរកចាប់ខ្លួនរបស់មន្ត្រីគយនិងអន្តោប្រវេសន៍ជាលក្ខណៈទ្រង់ទ្រាយធំ រួមទាំងអតីតជនភៀសខ្លួនខ្មែរ វៀតណាម និងឡាវជាដើម។ សកម្មជនគាំពារសិទ្ធិពលរដ្ឋអាស៊ីអាមេរិកាំង ដូចជាអ្នកស្រី ជុំ ម៉ុនថា បានចាត់ទុកថា ការធ្វើបែបនេះ គឺជាការរំលោភសិទ្ធិរបស់សមាជិកនៃសហគមន៍អាស៊ីអាគ្នេយ៍ដែលជាក្រុមជនជាតិភាគតិចនៅសហរដ្ឋអាមេរិក ជាពិសេសក្រុមអតីតជនភៀសខ្លួនមកពីកម្ពុជា ឡាវ និងវៀតណាម ដែលបានភៀសខ្លួនមករស់នៅសហរដ្ឋអាមេរិក ដោយសារតែសង្គ្រាមដែលសហរដ្ឋអាមេរិកធ្លាប់ពាក់ព័ន្ធ។ អ្នកស្រី ជុំ ម៉ុនថា បានថ្លែងថា៖ «សហគមន៍ខ្មែរយើងមិនបានទទួលការអប់រំអីទេ។ [អាមេរិក] យកពួកយើងមករស់នៅក្នុងប្រទេស ក្នុងនាមជាជនភៀសខ្លួន ហើយដាក់ពួកយើងឲ្យរស់នៅក្នុងតំបន់ពោរពេញដោយភាពក្រីក្រ ហើយពួកយើងត្រូវបានគេចម្អកដោយសារពួកយើងខុសពីគេ»។

អ្នកស្រី Katrina Dizon Mariategue អ្នកគ្រប់គ្រងគម្រោងគោលនយោបាយអន្តោប្រវេសន៍នៃអង្គការ SEARAC ដែលធ្វើការគាំពារមតិនិងសិទ្ធិរបស់សហគមន៍ខ្មែរ ឡាវ និងវៀតណាម ប្រចាំរដ្ឋធានីវ៉ាស៊ីនតោន បញ្ជាក់ថា ភាពក្រីក្រ ការខ្វះឱកាសទទួលបានការអប់រំ និងការមិនទទួលបានជំនួយឲ្យបានគ្រប់គ្រាន់ពីរដ្ឋាភិបាលអាមេរិក បានបង្កជាបញ្ហាប្រឈមធ្ងន់ធ្ងរជាច្រើនដល់សហគមន៍ជនភៀសខ្លួនខ្មែរ ដែលអ្នកខ្លះបានធ្លាក់ខ្លួនចូលក្រុមជនពាល និងប្រព្រឹត្តបទល្មើស ដែលតាមច្បាប់អន្តោប្រវេសន៍អាមេរិក បណ្ដាលឲ្យពួកគេប្រឈមនឹងការចាប់បញ្ជូនខ្លួនទៅកម្ពុជា។ អ្នកស្រី Katrina បានថ្លែងថា៖ «ពួកគេមិនចេះនិយាយភាសាអង់គ្លេសទេ ហើយព្យាយាមកសាងជីវិតថ្មី។ ដោយខ្វះ

ឱកាសទទួលបានការអប់រំដើម្បីប្រកបរបរចិញ្ចឹមជីវិត ក្រុមជនភៀសខ្លួនទាំងនេះជួបនឹងបញ្ហាប្រឈមជាច្រើន ដែលបណ្តាលឲ្យពួកគេខ្លះធ្លាក់ក្នុងស្ថានភាពដែលប្រឈមនឹងការនិរទេសខ្លួន។ ជាញឹកញាប់ យុវជននៃសហគមន៍ជនភៀសខ្លួនបានធ្លាក់ខ្លួនក្លាយជាក្រុមជនពាល ហើយជាលទ្ធផល ពួកគេបានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងៗ ដែលយើងយល់ថា ឧក្រិដ្ឋកម្មនោះកើតឡើងដោយសារភាពក្រីក្រ»។ សកម្មជនគាំពារសិទ្ធិសហគមន៍អាស៊ីអាមេរិកាំងរូបនេះបានបន្ថែមថា សហគមន៍ដទៃទៀតគួរតែស្វែងយល់បន្ថែមពីប្រវត្តិតស៊ូរបស់សហគមន៍ខ្មែរនៅដើមទសវត្សរ៍១៩៨០ ដើម្បីអប់រំខ្លួនអំពីឫសគល់នៃបញ្ហាប្រឈមនានា ដែលបានបណ្តាលឲ្យជនជាតិខ្មែរមួយចំនួនធំធ្លាក់ខ្លួនប្រព្រឹត្តបទល្មើសកាលពីក្មេង។ ប៉ុន្តែអ្នកស្រីក៏បានកត់សម្គាល់ផងដែរថា អ្នកដែលធ្លាប់បានប្រព្រឹត្តបទល្មើសពីមុនភាគច្រើនបានកែខ្លួន បន្ទាប់ពីទទួលទោសរួចហើយ ហើយរស់នៅក្នុងសង្គមដោយសាមញ្ញ។

ចាប់តាំងពីដើមឆ្នាំ២០១៩ រហូតមកដល់ពេលនេះ ជនជាតិខ្មែរចំនួន ៨០នាក់ ត្រូវបាននិរទេសទៅប្រទេសកម្ពុជា។ ហើយគិតពីថ្ងៃទី២១ ខែកញ្ញាមកទល់ពេលនេះ ជនជាតិខ្មែរចំនួន ១,៧៦៤នាក់ បានទទួលដីកាចាប់បញ្ជូនខ្លួនទៅកម្ពុជា។ ក្នុងចំណោមអ្នកទាំងនោះ ជនជាតិខ្មែរចំនួន ១,២៧៦នាក់ មានប្រវត្តិប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយក្នុងនោះ ២៤នាក់ កំពុងតែត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់អាជ្ញាធរគយនិងអន្តោប្រវេសន៍។ នេះបើតាមការបញ្ជាក់របស់អ្នកស្រី Paige D. Hughes អ្នកនាំពាក្យរបស់អាជ្ញាធរគយនិងអន្តោប្រវេសន៍ នៅក្នុងសារអេឡិចត្រូនិក ឬអ៊ីមែលមកកាន់ VOA។ បើគិតចាប់តាំងពីកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍ឆ្នាំ២០០២មក ជនជាតិខ្មែរសរុបចំនួន ៧៣៣នាក់ ត្រូវបានចាប់បញ្ជូនទៅកម្ពុជា។

***ការតស៊ូមតិជាសហគមន៍៖***

ទោះជាយ៉ាងណាក្តី អ្នកស្រី ជុំ ម៉ុនថា បានប្រាប់ VOA ថា ការប្រមូលផ្តុំគ្នារបស់សហគមន៍អាស៊ីអាមេរិកាំងមានសារៈសំខាន់ក្នុងការស្វែងរកអន្តរាគមន៍ពីភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានៃការចាប់ឃុំខ្លួន និងបញ្ជូនខ្លួនពលរដ្ឋអាស៊ីនៅសហរដ្ឋអាមេរិក ដោយគ្មានមនុស្សធម៌។ ការប្រមូលផ្តុំគ្នា និងការតវ៉ាជាក្រុមនេះ គឺជាយុទ្ធសាស្ត្រមួយដែលសហគមន៍អាស៊ីអាមេរិកាំងកំពុងតែពង្រីក ដើម្បីធានាថា ការចាប់ខ្លួនសមាជិកនៃសហគមន៍នេះដោយមន្ត្រីគយនិងអន្តោប្រវេសន៍ ត្រូវបានធ្វើឡើងដោយត្រឹមត្រូវតាមនីតិរដ្ឋ និងផ្អែកលើគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន។

អ្នកស្រី ជុំ ម៉ុនថា បានថ្លែងថា៖ «បើនិយាយពីសកម្មភាពជាថ្នាក់ជាតិវិញ យើងបានចេញតវ៉ាពេញប្រទេសអំពីការស្វែងរកចាប់ខ្លួនមនុស្សនៅក្នុងសហគមន៍ខ្មែរ ហើយកាលពីសប្តាហ៍មុន យើងបានដឹងថា ជនជាតិខ្មែរយើងមួយចំនួនត្រូវបានសម្ភាសដោយមន្ត្រីកុងស៊ុលខ្មែរ។ ដូច្នេះយើងមិនទាន់ដឹងថា ជនជាតិខ្មែរចំនួនប៉ុន្មាននាក់ឲ្យប្រាកដទេ ដែលនឹងត្រូវបានចាប់បញ្ជូនខ្លួន។ ប៉ុន្តែ យើងកំពុងធ្វើការរួមគ្នាជាថ្នាក់ជាតិ ដើម្បីព្យាយាមជួយឲ្យគ្រួសារខ្មែរបាននៅជុំគ្នា»។

អ្នកស្រី Katrina Dizon Mariategue នៃអង្គការ SEARAC ក៏បានបញ្ជាក់ផងដែរថា នាពេលបច្ចុប្បន្ននេះ សហគមន៍អាស៊ីអាមេរិកាំងនៅទូទាំងសហរដ្ឋអាមេរិក កំពុងតែប្រមូលផ្តុំមតិគ្នា ដើម្បីទាមទារឲ្យមានការអន្តរាគមន៍ពីថ្នាក់រដ្ឋ ជាពិសេសពីអភិបាលរដ្ឋ ក្នុងការផ្តល់ការលើកលែងទោសដល់អ្នកដែលមានប្រវត្តិប្រព្រឹត្តបទល្មើស។ ការផ្តល់ការលើកលែងទោសនេះ មានន័យថា ពួកគេត្រូវបានដកឈ្មោះចេញពីបញ្ជីក្រុមដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលជាលទ្ធផលនឹងជួយឲ្យពួកគេអាចរួចផុតពីការចាប់បញ្ជូនខ្លួនទៅប្រទេសកំណើតវិញ ក្នុងករណីដែលសំណុំរឿងថ្មីរបស់ពួកគេទទួលបានជោគជ័យ តាមនីតិវិធីនៃតុលាការអន្តោប្រវេសន៍។ អ្នកស្រី Katrina លើកឡើងថា៖ «នៅថ្នាក់រដ្ឋ ដោយមានការលើកលែងទោសពីអភិបាលរដ្ឋ វានឹងជួយសម្រួលដល់ការរៀបចំសំណុំរឿងដើម្បីទាមទារឲ្យមានការលុបចោលការចាប់បញ្ជូនខ្លួនពួកគេបាន»។ ក៏ប៉ុន្តែ ក្រោមរដ្ឋបាលលោកប្រធានាធិបតី ដូណាល់ ត្រាំ គេឃើញមានការបង្កើនការរឹតបន្តឹងនិងអនុវត្តច្បាប់អន្តោប្រវេសន៍បែបទ្រង់ទ្រាយធំ និងយ៉ាងរហ័ស ដែលបង្កជាការលំបាកដល់សហ

គមន៍ក្នុងការស្វែងរកការអន្តរាគមន៍ណាមួយឲ្យទាន់ពេលវេលា ដើម្បីកុំឲ្យមានការចាប់បញ្ជូនខ្លួនបែបអមនុស្សធម៌។ ជាក់ស្តែង នៅឆ្នាំ២០១៧ រដ្ឋាបាលលោក ត្រាំ បានដាក់ទណ្ឌកម្មលើរដ្ឋាភិបាលកម្ពុជា ដោយផ្អាកការផ្តល់ទិដ្ឋាការដល់មន្ត្រីជាន់ខ្ពស់កម្ពុជាដែលធ្វើការនៅក្រសួងការបរទេស ដោយសារតែកម្ពុជាមិនបានអនុវត្តតាមកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍ឆ្នាំ២០០២រវាងអាមេរិកនិងកម្ពុជាឲ្យបានត្រឹមត្រូវ។

អ្នកស្រី Katrina បានថ្លែងថា៖ «ដោយសារតែមូលហេតុនេះ យើងកំពុងតែឃើញថា អាជ្ញាធរគយនិងអន្តោប្រវេសន៍អនុវត្តច្បាប់យ៉ាងសាហាវ ហើយដាក់សម្ពាធបន្ថែមលើកម្ពុជា»។ ក្រុមសកម្មជនគាំពារសិទ្ធិសហគមន៍អាស៊ីអាមេរិកាំងកំពុងព្រួយបារម្ភថា ជនជាតិខ្មែរជាច្រើននាក់ នឹងត្រូវបានចាប់បញ្ជូនខ្លួនទៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់សកម្មជនការពារសិទ្ធិសហគមន៍ដូចជា អ្នកស្រី ជុំ ម៉ុនថា ក្តីសង្ឃឹមក្នុងការជួយគ្រួសារខ្មែរឲ្យបាននៅជួបជុំគ្នា ត្រូវតែមានជាបន្តទៀត ទោះបីជាកាលៈទេសៈបច្ចុប្បន្ននេះលំបាកយ៉ាងណាក៏ដោយ។ អ្នកស្រីបានថ្លែងថា៖ «ប៉ុន្តែយើងមិនត្រូវបោះបង់ការតស៊ូចោលទេ ហើយត្រូវមានក្តីសង្ឃឹម ហើយត្រូវសកម្មក្នុងការទាក់ទងទៅសហគមន៍ទាំងមូល មុននឹងការស្វែងរកចាប់ខ្លួនមនុស្ស [ដោយមន្ត្រីគយនិងអន្តោប្រវេសន៍] កើតឡើង ដើម្បីឲ្យយើងអាចជួយពួកគេបានមុននឹង វិបត្តិកើតឡើង»៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 16-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៩

## សពពលករខ្មែរ២នាក់ ត្រូវបានបញ្ជូនមកព្រមគ្នាទាំងយប់

http://mmcnews.asia/local-news/ October 17, 2019

ខេត្តបន្ទាយមានជ័យ ៖ ពិតជាកម្សត់ខ្លាំងណាស់ តើពលករខ្មែរប៉ុន្មាននាក់ហើយ ដែលត្រូវបញ្ជូនសពមក ក្នុងមូលហេតុមិនច្រើនករណី ? នៅយប់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩នេះ សពពលករខ្មែរ២នាក់ ត្រូវបានបញ្ជូនមកព្រមគ្នា តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ដោយម្នាក់ដេកស្លាប់ ដោយមិនដឹងមូលហេតុ និងម្នាក់ទៀតលោតទឹកសម្លាប់ខ្លួន សង្ស័យមានវិបត្តិផ្លូវចិត្ត។

សពរងគ្រោះទី១ឈ្មោះ ណោក ណាង ភេទប្រុស អាយុ៤៦ឆ្នាំ រស់នៅភូមិគោកគ្រប់ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ទៅធ្វើជាអ្នកកសាង នៅទីក្រុងបាងកក ប្រទេសថៃ ដេកស្លាប់កាលពី១៦ អត់ដឹងមូលហេតុ។ សពរងគ្រោះទី២ ឈ្មោះ ចង់ តាក់ ភេទប្រុស អាយុ២៨ឆ្នាំ ភូមិខ្វម ឃុំក្អាច់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ជាជាងកាត់កញ្ចក់ នៅខេត្តឆាក់ឈឹងសៅ សង្ស័យមានវិបត្តិផ្លូវចិត្ត ក្រោយទូរស័ព្ទលានិងសុំទោសបងប្អូននៅខ្មែរ រួចក៏លោតទឹកសម្លាប់ខ្លួន តាំងពីថ្ងៃទី១៤ ហើយរកឃើញសពនៅថ្ងៃទី១៥ ខែឆ្នាំដដែល។

ក្រោយបញ្ជូនសពចេញពីច្រកព្រំដែន សព១ដែលដេកស្លាប់ ត្រូវបានផ្ទេរដាក់រថយន្តដឹកបន្ត ទៅបូជាតាមប្រពៃណី នៅឯខេត្តឧត្តរមានជ័យ រីឯសពដែលស្លាប់ ដោយសារលោតទឹកសម្លាប់ខ្លួន កំពុងត្រូវបានរៀបចំបូជាតែម្តងនៅក្នុងវត្តបាលិលេយ្យ ស្ថិតក្នុងភូមិក្បាលស្ពាន១ សង្កាត់និងក្រុងប៉ោយប៉ែត ព្រោះសពមិនអាចទុកយូរ ម្យ៉ាងត្រូវដឹកទៅខេត្តឆ្ងាយមិនកើត ទើបត្រូវបូជារួចទើបយកធាតុ ទៅខេត្តតាកែវវិញ៕ ដោយ ធីតា

## គណៈមេធាវីកម្ពុជាគ្រោងដំណើរការការិយាល័យច្បាប់មួយនៅប្រទេសថៃនៅដើមឆ្នាំក្រោយ ដើម្បីជួយពលករខ្មែររងគ្រោះ

http://km.rfi.fr/cambodia/ ដោយ ញឹម សុផល ថ្ងៃទី 17-10-2019 នៅ 08:28

ផ្ដើមចេញពីកិច្ចប្រជុំចំរុះរវាងគណៈមេធាវី កម្ពុជា-ថៃ កាលពីខែសីហា កន្លងទៅនេះ គណៈមេធាវីកម្ពុជា កំពុងតែធ្វើសេចក្ដីព្រាងអនុស្សរណៈយោគយល់មួយ ដើម្បីបង្កើតការិយាល័យមេធាវីនៅក្នុងប្រទេសថៃ ដើម្បីជួយទៅដល់ពលករកម្ពុជា កំពុងបំរើការងារនៅទីនោះ ប្រមាណជិត២លាននាក់។ លោក សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានប្រាប់វិទ្យុបារាំងអន្តរជាតិ RFI នៅថ្ងៃព្រហស្បតិ៍នេះថា ការដែលគណៈមេធាវីកម្ពុជាគ្រោងបើកការិយាល័យច្បាប់មួយនៅក្នុងប្រទេសថៃ គឺដោយសារតែមានពលរដ្ឋខ្មែរមួយចំនួនដែលធ្វើការនៅថៃ បានរងនូវអំពើអយុត្តិធម៌ផ្សេងៗ ហើយមិនមានអ្នកណាជួយពួកគាត់។ គម្រោងជំនួយផ្នែកច្បាប់នេះ ត្រូវលោកប្រធានគណៈមេធាវីបញ្ជាក់ថា មិនបានគិតថ្លៃ និងមិនគិតពីនិន្នាការនយោបាយអ្វីឡើយ។

## ឆ្នាំសហប្រតិបត្តិការអនុវត្តច្បាប់ ចិន-កម្ពុជា៖ ចាប់ជនសង្ស័យជនជាតិចិនច្រើនជាង១000នាក់ និងបញ្ជូនចេញពីកម្ពុជា

https://www.facebook.com/RFIKhmer/ 18-10-2019

ស្ថានទូតចិនប្រចាំកម្ពុជា កាលពីថ្ងៃម្សិលមិញបានលើកឡើងថា ឆ្នាំ២០១៩ ជា "ឆ្នាំសហប្រតិបត្តិការអនុវត្តច្បាប់រវាងចិននិងកម្ពុជា"។ ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងនគរបាលទាំងពីរប្រទេស នគរបាលភាគីកម្ពុជាបានធ្វើការចាប់ខ្លួនជនសង្ស័យជនជាតិចិនមានចំនួនលើសពី១០០០នាក់ ដែលបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងពេស្យាចារ ល្បែងភ្នាល់តាមប្រព័ន្ធInternet គ្រឿងញៀន សង្គមងងឹតនិងបទល្មើសផ្សេងទៀត ហើយក៏បានធ្វើការចាប់បញ្ជូនត្រឡប់ទៅប្រទេសចិនវិញ។ ក្រោយពីការិយាល័យសហប្រតិបត្តិការអនុវត្តច្បាប់រវាងចិន និងកម្ពុជាត្រូវបានបង្កើតឡើង ស្ថាប័នអនុវត្តច្បាប់នៃប្រទេសទាំងពីរ បានសហការគ្នាយ៉ាងជិតស្និទ្ធថែមមួយកម្រិតទៀត ចុះបង្ក្រាបយ៉ាងតឹងរឹងនូវបទឧក្រិដ្ឋណា ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតទ្រព្យសម្បត្តិ សុវត្ថិភាពប្រជាពលរដ្ឋទាំងពីរប្រទេស។ នេះបើតាមសំណេរជាភាសាខ្មែរ និងភាសាចិន នៅលើទំព័រហ្វេសប៊ុកស្ថានទូតចិនប្រចាំនៅកម្ពុជា៕

## កុំខកខានឲ្យសោះ! រឿង"សោត់អណ្តែត" សាច់រឿងអប់រំ បង្ហាញពីព្រឹត្តិការណ៍ពិត ដោយអ្នកធ្វើចំណាកស្រុក ត្រូវចាញ់បោកឈ្មួញ ក្លាយខ្លួនជាទាសកររបស់ក្រុមនេសាទជនជាតិថៃ

https://khmernote.tv/news/ PR October 18, 2019 naren khmernote

ទីបំផុតខ្សែភាពយន្ត "សោត់អណ្តែត" ឬ 'Buoyancy' ដែលនិពន្ធ និងដឹកនាំដោយជនជាតិអូស្ត្រាលី លោក Rodd Rathjen បានមកដល់រោងភាពយន្ត Major Cineplex ហើយ បន្ទាប់ពីខ្សែភាពយន្តនេះបានបង្ហាញនៅក្នុងមហោស្រពភាពយន្តជាច្រើននៅជុំវិញពិភពលោក។ រឿង "សោត់អណ្តែត" ត្រូវបានសរសេរឡើងផ្អែកលើព្រឹត្តិការណ៍ពិតនៃទាសភាពបច្ចុប្បន្ន សាច់រឿងអប់រំដល់ប្រជាជនខ្មែរដែលមានគំនិតចង់ធ្វើចំណាកស្រុកទៅប្រទេសជិតខាង អោយគិតគូរ

ច្បាស់លាស់ព្រោះការចំណាកស្រុក ដោយគ្មានការប្រឹក្សាយោបល់ គ្មានចំណេះដឹង គឺភាគរយច្រើនណាស់ដែលយើងនឹងក្លាយជាទាសករដាច់ថ្លៃរបស់គេ។

សាច់រឿង "សោត់អណ្តែត" ឬ 'Buoyancy' និយាយពីកុមារអាយុ១៤ឆ្នាំម្នាក់ រស់នៅក្នុងគ្រួសារកសិករ មានជីវភាពខ្វះខាត ដោយមានសមាជិកក្នុងគ្រួសារច្រើន ចក្រា ក៏សម្រេចចិត្តចំណាកស្រុកចង់ធ្វើការរោងចក្រនៅប្រទេសថៃ ដើម្បីបានថវិកាមកជួយដល់គ្រួសារ។ ប៉ុន្តែបែរជាត្រូវចាញ់បោកមេខ្យល់ធ្លាក់ខ្លួនធ្វើជាទាសករនេសាទតាមទូកទៅវិញ ដោយធ្វើការនេសាទត្រីទាំងយប់ទាំងថ្ងៃ បាយទឹកមិនគ្រប់គ្រាន់ ធ្វើឲ្យ ចក្រា ទ្រាំមិនបានទើបសម្រេចចិត្តរកវិធីរត់គេច។ ចង់ដឹងថា ចក្រា អាចរត់គេចពីសុបិន្តអាក្រក់នេះបានឬក៏យ៉ាងណា កុំភ្លេចណាមកទស្សនារឿង "សោត់អណ្តែត" ឬ 'Buoyancy'ដែលចាប់ផ្តើមចាក់បញ្ចាំងពីថ្ងៃទី១៨ ខែតុលានេះតទៅ នៅរោងភាពយន្ត Major Cineplex by Smart គ្រប់សាខា៕

## ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៩

## ហាងម៉ាស្សា ស្ទីម-សូណា និងបង្គប់សេវាផ្លូវភេទរបស់ជនជាតិចិន ប្រុងបើកអាជីវកម្ម ត្រូវបង្ក្រាបទាន់ពេល

---

http://kampucheathmey.com/ 18/10/2019 5:32 Pm

ភ្នំពេញ ៖ ទីតាំងអាជីវកម្មមួយកន្លែង របស់ជនជាតិចិន ដែលត្រៀមបើកហាងម៉ាស្សា ស្ទីម-សូណា និងបង្កប់សេវាផ្លូវភេទ ស្ថិតក្នុងសង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ត្រូវបានលោក សុខ ពេញវុធ អភិបាល នៃគណៈ អភិបាលខណ្ឌដូនពេញចាត់ឲ្យមន្ត្រីជំនាញចុះពិនិត្យ និងបង្ក្រាបជាក់ស្តែងកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩នេះ។

លោក សុខ ពេញវុធ អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញបានមានប្រសាសន៍ថា បន្ទាប់ពីទទួលបានព័ត៌មានថា ទីតាំងនោះបានត្រៀមបើកអាជីវកម្មនោះលោកក៏ចាត់ឲ្យលោក យស យុទ្ធី អភិបាលរងខណ្ឌ លោក ថោង ពិសិដ្ឋ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ និងលោក ហែម វណ្ណា អធិការរងខណ្ឌ ដឹកនាំកម្លាំងគណៈកម្មការចម្រុះចុះត្រួតពិនិត្យជាក់ស្តែងនៅទីតាំងអាជីវកម្មរបស់ជនជាតិចិន ដែលត្រៀមរៀបចំបើកហាងម៉ាស្សា ស្ទីម-សូណា និងបង្កប់សេវាផ្លូវភេទ ដែលមានយីហោ "ឡុងពាន អ៊ីឡុងវ៉ន ងូតទឹក " មានទីតាំង ផ្ទះលេខ ៧Eo ផ្លូវលេខ១៧២ ភូមិ១០ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ។ ក្នុងប្រតិបត្តិការនោះ ក្រោយចុះពិនិត្យជាក់ស្តែងឃើញថា ទីតាំងខាងលើបានត្រៀមបើកប្រកបអាជីវកម្ម ម៉ាស្សា ស្ទីម-សូណា និងមាន បង្ហាញនូវផ្ទាំងរូបភាពអាសអាភាស ជាច្រើនផ្ទាំងដែលធ្វើឲ្យប៉ះពាល់ដល់វប្បធម៌ជាតិ តម្លៃស្ត្រី និងគ្រួសារខ្មែរ រួមទាំងមានស្រោមអនាម័យ មិនទាន់ប្រើមួយចំនួនធំផងដែរ។

គណៈកម្មការបានសំរេចដូចខាងក្រោមទី១-ដកហូតរូបភាពអាសអាភាសទាំងអស់ ដែលបានដាក់តាំងបង្ហាញនៅលើជញ្ជាំង។ ២-ផ្អាកអាជីវកម្មនេះ បណ្តោះអាសន្នរង់ចាំបំពេញបែបបទ និងច្បាប់អាជីវកម្មត្រឹមត្រូវទើបអនុញ្ញាតឲ្យប្រកបអាជីវកម្មវិញបាន។ ៣-មិនអនុញ្ញាតឲ្យដាក់តាំងរូបភាពអាសអាភាស ឬខ្លឹមសារផ្សេងៗ ដែលនាំឲ្យប៉ះពាល់ដល់សីលធម៌សង្គម។ ៤-ហាមដាច់ខាតធ្វើអាជីវកម្មបម្រើសេវាផ្លូវភេទ ការប្រើប្រាស់គ្រឿងញៀន ឬយកទីតាំងអាជីវកម្មប្រព្រឹត្តិបទល្មើសផ្សេងៗ។ ក្រៅពីសម្ភារៈខាងលើ ក្រុមការងារពុំបានដកហូតសម្ភារៈ ផ្សេងៗ ដែលមិនពាក់ព័ន្ធឡើយ និង បានឲ្យម្ចាស់ទីតាំងផ្តិតមេដៃលើកំណត់ហេតុផងដែរ៕ ស្មើ

## ជនជាតិរុស្ស៊ីម្នាក់ត្រូវឃាត់ខ្លួនបញ្ជូនទៅតុលាការករណីទិញពេស្យាចារលើកុមារ

http://www.rasmeinews.com/ October 20, 2019, 6:51 PM

ដោយបាយ័ន/សៀមរាបៈ ប្រភពព័ត៌មានមួយបានឱ្យដឹងថាបុរសជនជាតិរុស្ស៊ីម្នាក់ត្រូវបានឃាត់ខ្លួននៅឯរាជធានីភ្នំពេញហើយបញ្ជូនមកស្នងការនគរបាលខេត្តសៀមរាប។ បន្តបញ្ជូនទៅឱ្យសាលាដំបូងខេត្តសៀមរាបឃុំខ្លួនដាក់ពន្ធនាគារដែលជាប់ពាក់ព័ន្ធលើការទិញពេស្យាចារកុមារនៅខេត្តសៀមរាបនាពេលកន្លងទៅ។

ជនជាប់ចោទដែលជាបរទេសត្រូវបានសមត្ថកិច្ចខេត្តសៀមរាបបញ្ជាក់ឱ្យដឹងនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ នេះថារូបគាត់ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៨ ខែតុលា នៅរាជធានីភ្នំពេញដោយកម្លាំងរបស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាបសហការជាមួយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ប្រភពខាងលើបាននិយាយថាការចាប់ខ្លួនជនបរទេសរូបនេះគឺធ្វើឡើងតាមការបញ្ជារឱ្យចូលខ្លួនរបស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។ជនជាតិរុស្ស៊ីខាងលើមានឈ្មោះRomanBakTigzih ភេទប្រុស អាយុ៣០ឆ្នាំ ពេលចាប់ខ្លួនគឺសមត្ថកិច្ចរកមិនឃើញលិខិតឆ្លងដែននៅជាប់នឹងខ្លួនទេ ហើយក៏បញ្ជូណខ្លួនមកកាន់ខេត្តសៀមរាបភ្លាមៗនោះដែរដើម្បីចោទប្រកាន់តាមផ្លូវច្បាប់។

ជនសង្ស័យត្រូវបានបញ្ជូនទៅកាន់សាលាដំបូងខេត្តសៀមរាបនាថ្ងៃទី១៩ ខែតុលារួចហើយដើម្បីឃុំខ្លួនដាក់ពន្ធនាគារបណ្ដោះអាសន្ន។ ដោយប្រភពសមត្ថកិច្ចគ្រាន់តែបញ្ជាក់ថាជនជាប់ចោទបានជាប់ពាក់ព័ន្ធនឹងករណីទិញពេស្យាចារលើកុមារនៅខេត្តសៀមរាប ។ក្នុងអំឡុងខែឧសភា ឆ្នាំ២០១៩កន្លងទៅ ក្រោយពីកើតហេតុជនជាប់ចោទបានគេចខ្លួនទៅរាជធានីភ្នំពេញ៕ទS/

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 18-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក អូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្ត ឧត្តរមានជ័យ ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial General Department of Immigration - GDI Sok Heng 18-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់ នាវេលាម៉ោង ១៧និង២០នាទី ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial General Department of Immigration – GDI 19-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកដាំ ខេត្តឧត្តរមានជ័យ ៕

## តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកខេត្តត្រាត ដើម្បីចូលរួមក្នុង "វេទិកាស្តីពីសំណេចពលករចំណាកស្រុក" ជាមួយបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅនិងបម្រើការងារនៅក្នុងខេត្តត្រាត

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 20-10-2019

ថ្ងៃអាទិត្យ ៧រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ កម្មវិធីនេះរៀបចំឡើង ក្នុងគោលបំណងបង្កើនចំណេះដឹងពាក់ព័ន្ធផ្នែកច្បាប់ការងារ សិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ ដល់បងប្អូនពលករខ្មែរមានលទ្ធភាពជួយខ្លួនឯងបាន នៅពេលពួកគាត់ជួបបញ្ហាផ្សេងៗនៅកន្លែងធ្វើការ និងការរស់នៅប្រចាំថ្ងៃនៅក្នុងប្រទេសថៃ។

# ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១៩

## នគរបាលខេត្តព្រះសីហនុ ឃាត់ខ្លួនជនជាតិចិន ៤នាក់ ពីបទផ្សព្វផ្សាយ ខិត្តបណ្ណ រូបភាពអាសអាភាស

https://www.dap-news.com/kh/ សៅរ៍, ២៥ សីហា ២០១៨ 11:22 ដោយ: ព្រឿង វិសាល ID:113

**ភ្នំពេញ៖** កម្លាំងប៉ុស្តិ៍នគរបាល រដ្ឋបាលសង្កាត់លេខ២ សហការជាមួយកម្លាំងអធិការ ដ្ឋាននគរបាលក្រុងព្រះសីហនុ ឃាត់ខ្លួនជនជាតិចិនប្រុសស្រី៤នាក់ ពីបទផ្សព្វផ្សាយខិត្តបណ្ណ រូបភាពអាសអាភាស នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង២៣និង៣០នាទី នៅចំណុចភ្នំខៀវ ក្នុងក្រុមទី១ ភូមិ១ សង្កាត់២ ក្រុង-ខេត្តព្រះសីហនុ ។

នគរបាលខេត្តព្រះសីហនុ បានឲ្យដឹងថា ជនជាតិចិន ដែលសមត្ថកិច្ចឃាត់ខ្លួនរួមមាន ទី១-ឈ្មោះ Xiang zi អាយុ ១៩ឆ្នាំ ភេទស្រី, ទី២-ឈ្មោះ Chao jian ring អាយុ ១៨ឆ្នាំ ភេទស្រី, ទី៣-ឈ្មោះ Liu xiong fei អាយុ ២៧ឆ្នាំ ភេទប្រុស និងទី៤-ឈ្មោះ Duan yu cheng អាយុ ៣៦ឆ្នាំ ភេទប្រុស ។ បានធ្វើសកម្មភាព ដោយចតរថយន្តនៅចំណុចខាងលើ ក្នុងគោលបំណង ចែកខិតបណ្ណផ្សព្វផ្សាយរូបអាសអាភាស ។ ពេលសមត្ថកិច្ចត្រួតពិនិត្យ ពួកគាត់បានកាន់ខិតបណ្ណ ផ្សព្វផ្សាយរូបភាពអាសអាភាស ក្នុងន័យបង្កប់សេវាផ្លូវភេទ ទម្លាក់ចុះពីតាបឡូរថយន្តមកក្រោម ឃើញសភាពបែបនេះកម្លាំងជំនាញ បាននាំពួកគាត់មក អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ដើម្បីធ្វើការសាកសួរ តែពួកគាត់មិនព្រមសហការ ជាមួយសមត្ថកិច្ចឡើយ ។

សមត្ថកិច្ចបានដកហូតវត្ថុតាងៈ ទូរស័ព្ទចំនួន៤គ្រឿង, ខិត្តបណ្ណមានរូបអាសអាភាសចំនួន ៦៨៤សន្លឹក និងរថយន្តមួយគ្រឿងម៉ាកលុចស៊ីស ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 20-8959 ។ បច្ចុប្បន្នកម្លាំងជំនាញ កំពុងបន្តតាមនីតិវិធី បញ្ជូនទៅសាលាដំបូងខេត្តព្រះសីហនុ ៕

## ពលករ ខ្មែរ ឈ្មោះ ថាច់ លី ភេទ ប្រុស អាយុ៣១ឆ្នាំ រងគ្រោះ ថ្នាក់រអិលជ្លួលជុងដែក បណ្តាលអោយរងរបួស

https://www.facebook.com/ Prak Pheaktra 22/10/19 10:14

មានករណីពលករខ្មែរឈ្មោះ ថាច់ លី ភេទប្រុស អាយុ៣១ឆ្នាំ រងគ្រោះថ្នាក់រអិលជ្លួលជុងដែកបណ្តាលអោយរងរបួស ហេតុការណ៍នេះកើតឡើងនៅក្នុងការដ្ឋានសំណង់ស្ថិតនៅម៉ុំវិធារ៉ឌី៦ ទីក្រុងបាងកកបច្ចុប្បន្នជនរងគ្រោះត្រូវបានសមត្ថកិច្ចបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យណុបរ៉ាត់រាជទេវី។

## ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៩

## សម្តេចក្រឡាហោម ស ខេង អញ្ជើញដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-10-24

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩នេះ អញ្ជើញដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយ ផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ កិច្ចប្រជុំផ្សព្វផ្សាយនេះ ត្រូវបានធ្វើឡើងនៅទីស្តីការក្រសួងមហាផ្ទៃ ដែលមានការចូលរួមពីតំណាងស្ថាប័នពាក់ព័ន្ធ និងតំណាងស្ថានទូតនានានៅក្នុងប្រទេសកម្ពុជា អង្គការសង្គមស៊ីវិល ជាច្រើនរូបផងដែរ។

ថ្លែងក្នុងឱកាសនោះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានលើកឡើងអំពីគោលដៅ គឺបន្តលើកកម្ពស់រាល់កិច្ចខិតខំប្រឹងប្រែង ក្នុងសង្គម និងរិះរកវិធានការ និងវិធីសាស្ត្រថ្មីៗ ដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ រាល់ទម្រង់ចាស់ ថ្មី នៃអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងរាល់អំពើពាក់ព័ន្ធដែលកើតមាននៅក្នុង ប្រទេសកម្ពុជា និងទៅលើប្រជាជនកម្ពុជា ទោះជានៅទីណាក៏ដោយ។

ដោយឡែក សម្រាប់គោលបំណងវិញ ត្រូវបានលោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ធានាឲ្យមានប្រព័ន្ធគាំពារសង្គម ដើម្បីការបង្ការទប់ស្កាត់ភាពរងគ្រោះ ឲ្យមានប្រសិទ្ធភាព ការអនុវត្តច្បាប់ដែលមានឥទ្ធិពល និងការផ្តន្ទាទោសយ៉ាងសុក្រឹត្យចំពោះបទឧក្រិដ្ឋនេះ ដើម្បីយុត្តិធម៌សង្គម ជាពិសេសការការពារសិទ្ធិ ផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាមនុស្សគ្រប់វ័យ គ្រប់ភេទ និងនៅគ្រប់ស្ថានភាព៕

## សម្តេច ស ខេង៖ បទល្មើសជួញដូរមនុស្ស-ផ្លូវភេទ នឹងកាន់តែពិបាកទប់ស្កាត់ដោយសារកត្តាទាំងនេះ

http://kleykley.sabay.com.kh/ ថ្ងៃនេះ 24-10-2019 ម៉ោង 10:53

សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ឆ្នាំ២០១៩ និងឆ្នាំបន្តទៅទៀត អំពើជួញដូរមនុស្ស ជួញដូរផ្លូវភេទ និងអំពើកេងប្រវ័ញ្ចលើកម្លាំងពលកម្ម នៅតែកើតមានក្រោមរូបភាពថ្មីៗ និងស្មុគស្មាញ ដែលនាំឱ្យមានការលំបាកទប់ស្កាត់។ ការថ្លែងខាងលើនេះ ធ្វើឡើងក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩។

សម្តេចក្រឡាហោម លើកឡើងថា របៀបនៃការប្រព្រឹត្តបទល្មើស មានការប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ច និងសង្គម របស់ប្រទេសពាក់ព័ន្ធក្នុងពិភពលោក និងប្រកបដោយបច្ចេកវិទ្យាកាន់តែទំនើប កាន់តែអាថ៌កំបាំង គួបផ្សំនឹងមនោគមន៍វិជ្ជា និងការគ្រប់គ្រងចិត្តសាស្ត្រលើជនរងគ្រោះ។ កត្តាទាំងនេះ ធ្វើឱ្យការស៊ើបអង្កេត និងបង្ក្រាប កាន់តែលំបាកឡើង ដែលឱ្យមានភាពប្រឈមថ្មីៗ ក្នុងការរៀបចំយុទ្ធសាស្ត្រ យុទ្ធវិធី និងសកម្មភាព ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនោះ ឱ្យមានប្រសិទ្ធភាព។

សម្តេច ស ខេង ក៏បានគូសបញ្ជាក់ដែរថា ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើជួញដូរមនុស្ស ៥ឆ្នាំ ពីឆ្នាំ ២០១៩-២០២៣ មានគោលដៅបន្តលើកកម្ពស់រាល់កិច្ចខិតខំប្រឹងប្រែងក្នុសង្គម និងរិះរកវិធានការ និងវិធីសាស្ត្រ

ថ្មីៗដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់រាល់ទម្រង់ចាស់ថ្មីនៃអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្ម ពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងទៅលើប្រជាជនកម្ពុជា ទោះជានៅទីណាក៏ដោយ៕ អត្ថបទ៖ សំភី

## កិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://gdlf-kh.com/ 24/10/2019 Kim Sopha

រាជធានីភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួង-ស្ថាប័ន ស្ថានតំណាងប្រទេសជាមិត្ត ប្រចាំព្រះរាជាណាចក្រកម្ពុជា អង្គការដៃគូរជាតិ និងអន្តរជាតិ ប្រមាណ ៤៥០រូប។

## សំណុំរឿងស្ត្រីខ្មែរ៣នាក់ ពពោះជំនួស តុលាការបញ្ឈប់សវនាការ ដោយសារជនជាប់ចោទ៣នាក់អត់មានមេធាវី

---

http://kampucheathmey.com/ មករា 24/10/2019 11:58 Am

ភ្នំពេញ ៖ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩នេះ បានបើកសវនាការលើសំណុំរឿងចាក់មេជីវិតចូលទៅក្នុងផ្ទៃស្ត្រីខ្មែរ ដើម្បីឲ្យពពោះជំនួសជនជាតិចិនដែលចង់បានកូន។ ជនជាប់ចោទទាំង១០នាក់ដែលតុលាការលើកយកមកកាត់ទោសនេះ មានចំនួន៥នាក់ ស្ថិតនៅក្នុងការឃុំឃាំងរបស់តុលាការ។ ចំណែក៥នាក់ទៀតនៅក្រៅឃុំ ( ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ )។ ក្នុងថ្ងៃសវនាការនេះ ជនជាប់ចោទ៥នាក់ ដែលនៅក្រៅឃុំមានតែ២នាក់ប៉ុណ្ណោះដែលបានមកចូលរួម មានឈ្មោះ ញ៉ន ស្រីមឿន អាយុ២៦ឆ្នាំ និងឈ្មោះ សិទ្ធ ស្រីមុំ អាយុ៣៣ឆ្នាំ។

ចំណែកជនជាប់ចោទដែលតុលាការឃុំខ្លួន ៖

ទី១/ឈ្មោះ Tiu Qiang ភេទប្រុស ជនជាតិចិន ឆ្នាំកំណើត១៩៦៩ ជាមេការ។

ទី២/ឈ្មោះ ស្វាយ ស៊ីណុច ហៅ សី ភេទស្រី ជនជាតិខ្មែរ អាយុ៣៤ឆ្នាំ ជាមេការ។

ទី៣/ឈ្មោះ នឿន ស្រីឡាង ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរជាមេការ។

ទី៤/ឈ្មោះ លឹម សុភាព ហៅស្តើង ភេទស្រី អាយុ១៩ឆ្នាំ ជាអ្នកបកប្រែ។

ទី៥/ឈ្មោះ ថៃ ភាព ភេទស្រី អាយុ៤៣ឆ្នាំ ជាមេការ។

បុរសជនជាតិចិន និងនារីខ្មែរទាំង៥នាក់ ត្រូវបានជាប់ចោទក្នុងការប្រព្រឹត្តបទល្មើសលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន តាមមាត្រា១៦ នៃច្បាប់ ស្តីពីការបង្រ្កាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើផ្លូវភេទ និងបទអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះជំនួស មាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ។

សូមបញ្ជាក់ថា នៅពេលតុលាការចាប់ផ្តើមសវនាការ ក្នុងចំណោមជនជាប់ចោទទាំងអស់ គឺមានជនជាប់ចោទចំនួន៣នាក់ អត់មានមេធាវីការពារផ្លូវច្បាប់ឲ្យ។ យោងតាមច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីបទល្មើសជាបទឧក្រិដ្ឋ ហើយជនជាប់ចោទពុំមានមេធាវីការពារ នោះតុលាការចាត់តាំងមេធាវីឲ្យជនជាប់ចោទ ឬត្រូវបញ្ឈប់សវនាការ

ដើម្បីឲ្យជនជាប់ចោទរកមេធាវីការពារក្តីជាមុនសិន។ ដូច្នេះ ក្នុង សំណុំរឿងក្តីនេះ តុលាការ បានផ្អាកសវនាការដើម្បីឲ្យជនជាប់ចោទរកមេធាវីការពារក្តី និងលើកពេលសវនាការទៅ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ខាងមុខ។

សូមរំលឹកថា ការឃាត់ខ្លួនជនជាប់ចោទទាំង៥នាក់ខាងលើនេះ ធ្វើឡើងកាលពីវេលាម៉ោង៦ល្ងាចថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ចំណុចផ្ទះវីឡាលេខ២A ផ្លូវ៣៤៨ និង ផ្ទះវីឡាលេខ៩A ផ្លូវ៣៤៨ ស្ថិតនៅក្នុងបុរី វិមានភ្នំពេញ តាមបណ្តោយផ្លូវលេខ៥ ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ។ ប្រតិបត្តិការនេះ មានការសម្របសម្រួលពី លោក គុជ គីមឡុង ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដឹកនាំមន្ត្រីនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជនរាជធានីភ្នំពេញ។

ក្នុងប្រតិបត្តិការនេះ ផ្ទះទី១ ផ្ទះផ្ទះលេខ២A ផ្លូវ៣៤៨ ឃាត់ខ្លួនមនុស្សបានចំនួន២៥នាក់ ប្រុស២នាក់ ដែលបុរសម្នាក់ ឈ្មោះ LIU QIANG ភេទប្រុស អាយុ៤៩ឆ្នាំ (ជនជាតិចិន) និង រថយន្ត១គ្រឿងម៉ាក់ស្តារិច ពណ៌ស ពាក់ស្លាកលេខ ព្រះសីហនុ ២A -៦៨៨៣ ម៉ូតូហុងដា today ពណ៌ខ្មៅ ១គ្រឿង និងផ្ទះទី២ ផ្ទះលេខ៩A ផ្លូវ៣៤៨ ឃាត់ខ្លួនបានមនុស្សចំនួន១៨នាក់ រួមទាំងក្មេង២នាក់ និងរថយន្ត១គ្រឿង ម៉ាកLexus 470 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2C-8863។ ថែមទាំងដកហូតឯកសារមួយចំនួនរួមមាន លិខិតឆ្លងដែនមួយចំនួន និងឯកសារពាក់ព័ន្ធនឹងឱសថការពារទារកមួយចំនួនធំ។

តាមចម្លើយនារីពពោះជំនួសទាំង៣៣នាក់ គឺក្នុងកូន១ ដែលពួកគាត់ពពោះជំនួសនេះទទួលបានប្រាក់កម្រៃចំនួន១ម៉ឺនដុល្លារ គិតចាប់ពីខែដំបូងឲ្យចំនួន៥០០ដុល្លារ ខែបន្ទាប់៣០០ដុល្លារ រហូតដល់កើត ទើបទទួលបានចំនួន៦០០០ដុល្លារបន្ថែមទៀត។

ចំពោះការថែទាំគភ៌ ការប្រសូត គឺជាបន្ទុករបស់ក្រុមហ៊ុន។ លក្ខណៈពិសេស នៃការពពោះជំនួសក្នុងករណីនេះ គឺពេលជិតដល់ត្រូវឆ្លងទន្លេ ប្រសូត គឺ ក្រុមហ៊ុនបញ្ជូនស្ត្រីពពោះទៅប្រទេសចិនសម្រាលកូនរួចទើបបញ្ជូនមកស្រុកខ្មែរវិញ ហើយប្រគល់លុយបង្គ្រប់១ម៉ឺនដុល្លារ។ ឥឡូវនេះ ស្ត្រីពពោះជំនួសទាំង៣៣នាក់ ត្រូវបញ្ជូនឲ្យមន្ទីរសង្គមកិច្ចរាជធានីគ្រប់គ្រងបណ្តោះអាសន្ន រង់ចាំសម្រេចពីតុលាការ។ ចំណែកមេការក្រុមហ៊ុនទាំង៥នាក់ ត្រូវបានបញ្ជូនឡើងតុលាការឃុំខ្លួនតាំងពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃកាត់ទោសនេះ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/ General Department of Immigration – GDI 22-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរ ០១នាក់នេះ មានស្រុកកំណើតនៅខេត្តបាត់ដំបង៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៨នាក់

https://www.facebook.com/ General Department of Immigration – GDI 22-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៨នាក់ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក អូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្ត ឧត្តរមានជ័យ ៕

## ជនជាតិខ្មែរ ៦នាក់ ប្រដាប់ដោយសម្ភារៈចម្លែកៗ ត្រូវប៉ូលិសម៉ាឡេស៊ីចាប់បានក្នុងព្រៃ

http://angkorfresh.com/archives/ 23-10-2019

អត្ថបទដោយ៖ សេង ផៃយ៉ារ៉ា October 23. 2019

បើតាមប្រភពព័ត៌មាន Malaysia Kini របស់ប្រទេសម៉ាឡេស៊ី ចេញផ្សាយកាលពីយប់មិញនេះ បានឲ្យដឹងថា ជនជាតិខ្មែរ ៦រូប ប្រដាប់ដោយសម្ភារៈចម្លែកៗសម្រាប់បរបាញ់សត្វ ត្រូវបានចាប់ខ្លួននៅក្នុងព្រៃអភិរក្ស Tembat Forest Reserve នៅរដ្ឋ Terengganu។ ព័ត៌មានស្តីពីការចាប់ខ្លួននេះ ត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងធនធានធម្មជាតិ នៃប្រទេសម៉ាឡេស៊ី។

ការចាប់ខ្លួននេះ កើតឡើងបន្ទាប់ពីមានប្រតិបត្តិការរួមគ្នារវាងសមាជិកនាយកដ្ឋានការពារសត្វព្រៃ សមត្ថកិច្ចពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត។ បើតាការបញ្ជាក់របស់រដ្ឋមន្ត្រីដដែលបានឲ្យដឹងថា ជនសង្ស័យដែលចាប់ខ្លួនបានមានសរុបចំនួន ៦នាក់ គឺជនជាតិខ្មែរទាំងអស់។

តាមប្រភពបានឲ្យដឹងថា ជនសង្ស័យជាជនជាតិខ្មែរទាំង ៦នាក់ ប្រដាប់ទៅដោយឧបករណ៍មួយចំនួន ដែលច្នៃសម្រាប់បរបាញ់។ ក្រៅពីនោះគេបានឃើញស្នូកអណ្តើកនិងបំណែកនៃភ្លុក រោមសត្វ ចៃ និងស្នែងសត្វជាច្រើនប្រភេទ។ តាមលោករដ្ឋមន្ត្រីបានបញ្ជាក់ថា ករណីនេះនឹងត្រូវស៊ើបអង្កេតបន្តតាមមាត្រា ៦០ និង ៦៨ នៃច្បាប់ស្តីពីការអភិរក្សសត្វព្រៃឆ្នាំ២០១០។ ប្រសិនរកឃើញថា ប្រព្រឹត្តខុសមែន ជនជាតិខ្មែរទាំង ៦នាក់ នឹងត្រូវទទួលទោសទៅតាមច្បាប់ជាធរមាន។

តាមពិតទៅមិនមែនតែជនជាតិខ្មែរទេ ដែលលបលួចកាប់ព្រៃ និងបរបាញ់សត្វដោយខុសច្បាប់នៅក្នុងប្រទេសម៉ាឡេស៊ី។ ពីមុនមកសមត្ថកិច្ចចាប់បានមនុស្ស ២៩នាក់ ហើយ ដោយក្នុងនោះជនជាតិម៉ាឡេស៊ីម្នាក់ បង់ក្លាដេស ៦នាក់ ឥណ្ឌូណេស៊ី ២នាក់ មីយ៉ាន់ម៉ា ៦នាក់ និងចិន ១៤នាក់។

## រកឃើញសាកសពចំនួន ៣៩នាក់ ក្នុងទូរកុងតឺន័រមួយ នៅ Essex ចក្រភពអង់គ្លេស

https://dap-news.com/international/ Posted on October 23, 2019

BBC៖ ប៉ូលីសរបស់ចក្រភពអង់គ្លេស បាននិយាយថា សាកសពមនុស្សចំនួន ៣៩ នាក់ ត្រូវបានគេរកឃើញនៅក្នុងកុងតឺន័រដឹកទំនិញមួយ នៅតំបន់ Essex ។ យោងតាមសារព័ត៌មាន BBC ចេញផ្សាយនៅរសៀលថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៩ បានឱ្យដឹងថា មន្ត្រីបានហៅរថយន្តសង្គ្រោះបន្ទាន់នៅមុនម៉ោង ១ និង៤០ នាទី បន្ទាប់ពីការរកឃើញ នៅសួនឧស្សាហកម្ម Waterglade នៅខាងកើត Avenue, ទីក្រុង Grays។ អ្នកបើកបររថយន្តដឹកទំនិញ ត្រូវបានចាប់ខ្លួន៕ ប្រែសម្រួលៈ ណៃ តុលា

# ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៩

## សម្តេច ហេង សំរិន ស្នើឱ្យទូតខ្មែរទៅបំពេញភារៈងារនៅបរទេស យកចិត្តទុកដាក់ពីផលប្រយោជន៍ជាតិ

http://bayontv.com.kh/ 25/10/2019

ភ្នំពេញ ៖ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា បានស្នើឱ្យឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រៀមចេញទៅបំពេញបេសកកម្មការទូតនៅក្រៅប្រទេសថា នៅពេលបំពេញការងារ ត្រូវ តម្កល់ប្រយោជន៍ជាតិជាធំ ទោះក្នុងកាលៈទេសៈណាក៏ដោយ ត្រូវរក្សាការពារ និងលើកតម្លៃជាតិជានិច្ច។ ត្រូវរក្សាការសម្ងាត់របស់ជាតិ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយការបរទេសរបស់កម្ពុជា។ សម្តេចអគ្គមហាពញាចក្រី ហេង

សំរិន ប្រធានរដ្ឋសភា ក្នុងពេលទទួលជួបជាមួយឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ដែលទើបតែងតាំងប្រចាំនៅប្រទេសចំនួន៩ នៅព្រឹកថ្ងៃទី២៥ ខែតុលា នេះ បានបញ្ជាក់ប្រាប់ឯកអគ្គរាជទូតទាំងនោះថា បេសកកម្មការ ទូតត្រូវបង្ហាញ និងប្រកាន់ខ្ជាប់នូវអត្ត សញ្ញាណជាតិ និងសេចក្ដីថ្លៃថ្នូរ ដោយត្រូវបន្តលើកកម្ពស់ផ្សព្វផ្សាយឱ្យបរទេសស្គាល់កម្ពុជាឱ្យបានច្បាស់ ទាំងផ្នែកសិល្បៈ វប្បធម៌ ប្រពៃណី របស់ខ្មែរ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីអត្តសញ្ញាណរបស់ជាតិ ដែលមាន វប្បធម៌ផូរផង់ តាំងពីសម័យអង្គរមក។

សម្ដេចប្រធានរដ្ឋសភា បានរំលឹកដល់តំណាងកម្ពុជា តាមប្រទេសនានា ដែលទើបតែងតាំងនោះ បន្តជំរុញ និងលើកកម្ពស់ការផ្សព្វផ្សាយសំដៅទាក់ទាញអ្នកវិនិយោគ និងទេសចរបរទេស មកប្រទេស កម្ពុជា ឱ្យកាន់តែច្រើនថែមទៀត ដោយផ្អែកលើសក្ដានុពល ដែលប្រទេសមានស្រាប់ ហើយត្រូវបង្កើនកិច្ច សហប្រតិបត្តិការល្អជាមួយឯកអគ្គរដ្ឋទូត-រាជទូត នៃបណ្ដាប្រទេសដទៃទៀត ប្រចាំនៅប្រទេសនោះផង ដែរ។ សម្ដេច ប្រធានរដ្ឋសភា មានសង្ឃឹមយ៉ាងមុតមាំថា តំណាងកម្ពុជាទាំងអស់ នឹងប្រតិបត្តិតួនាទីរបស់ ខ្លួន បានល្អជានិច្ច សក្តិសមជាឯកអគ្គរាជទូតដែលរាជរដ្ឋាភិបាលបានផ្ដល់នូវទំនុកចិត្ត។ សម្ដេច ក៏បានផ្ដាំផ្ញើ ដល់ឯកអគ្គរាជទូតទាំងអស់ ចុះស្វែងយល់សុខទុក្ខ និងក្ដាប់ព័ត៌មានឲ្យបាន ច្បាស់លាស់ជាក់ស្ដែង អំពីប្រជាពលរដ្ឋ សិស្ស និស្សិត និងពលករខ្មែរ ដែលកំពុងរស់នៅក្រៅប្រទេស ហើយបង្កលក្ខណៈងាយស្រួល លើសេវាកម្មនានារបស់ស្ថានទូត លើកកម្ពស់សុខុមាលភាព និងការពារ ផលប្រយោជន៍របស់ពួកគេ។

ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ដែលទើបតែងតាំង ប្រចាំនៅប្រទេសវៀតណាម រុស្ស៊ី អូស្ត្រាលី ស្វីស មីយ៉ាន់ម៉ា ម៉ាឡេស៊ី គុយបា គុយវ៉ែត និង ប្រទេសប្រ៊ុយណេ ដារ៉ូសាលឹម។ តំណាងឯកអគ្គរាជទូតកម្ពុជា ដែលបានចូលជម្រាបលា និងទទួលអនុសាសន៍ពីសម្ដេចប្រធានរដ្ឋ សភា នាឱកាសនេះ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដែលសម្ដេច បានចំណាយពេលវេលាអនុញ្ញាត បានចូលជម្រាបលា និងទទួលបានអនុសាសន៍ល្អៗ ដែលជាចក្ខុវិស័យ សម្រាប់យកទៅអនុវត្តការងារ ទទួលបានជោគជ័យ ស្របតាមគោលនយោបាយការទូតរបស់កម្ពុជា៕

## មន្ត្រីជំនាញ ដាក់ចេញយុទ្ធសាស្ត្រទប់ស្កាត់ទម្រង់ថ្មីៗនៃការជួញដូរមនុស្ស

https://www.postkhmer.com/ ខន សារី | Publication date 25 October 2019 | 09:48 ICT

**ភ្នំពេញៈ** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិរយៈពេល ៥ ឆ្នាំ គិតពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣ ដើម្បីកាត់បន្ថយទម្រង់ថ្មីៗនៃការជួញដូរមនុស្សដូចជា អំពើជួញដូរផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើពពោះជំនួសរួមទាំងកាត់បន្ថយទម្រង់នៃការកើនឡើងវិញនូវការបង្កប់សេវាផ្លូវភេទតាមក្លិបកម្សាន្តផងដែរ។

កាលពីថ្ងៃម្សិលមិញលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការនេះបានធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ២០១៩-២០២៣ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលផ្ដោតលើការបង្ការ ទប់ស្កាត់ បង្ក្រាប ផ្ដន្ទាទោស សង្គ្រោះ ការពារអំពើលក់ដូរមនុស្សអំពើជួញដូរផ្លូវភេទអំពើជួញដូរពលកម្ម និងអំពើជួញដូរសរីរាង្គ។ លោក ស ខេង បានថ្លែងក្នុងកិច្ចប្រជុំនោះថា រាជរដ្ឋាភិបាលមិនដែលព្រងើយកន្តើយដោយទុកឱ្យបទល្មើសជួញដូរមនុស្សរីករាលដាលដោយគ្មានការបង្ក្រាបនោះទេ ហើយកន្លងមកមានបទល្មើសជាច្រើនត្រូវបានបង្ក្រាប និងមានជនសង្ស័យត្រូវបានចាប់បញ្ជូនទៅតុលាការជាបន្តបន្ទាប់។ លោកថា ថ្វីដ្បិតតែមានការបង្ក្រាបបានច្រើនក្ដី ប៉ុន្តែមិនបានធ្វើឱ្យក្រុមជនល្មើសបញ្ឈប់សកម្មភាពប្រព្រឹត្តអំពើជួញដូរមនុស្សនោះទេ។ ផ្ទុយទៅវិញពួកគេរឹតតែខិតខំរកគ្រប់មធ្យោបាយថ្មីៗដើម្បីបង្វែងដានសមត្ថកិច្ច និងតែងរិះរកគ្រប់ភ័ស្ដុតាងដើម្បីដោះបន្ទុកពីការចោទប្រកាន់របស់តុលាការ។ លោកបានបញ្ជាក់ថា៖ «អំពើជួញដូរមនុស្ស ជួញដូរផ្លូវភេទ

និងអំពើកេងប្រវ័ញ្ចកម្លាំងពលកម្មនៅតែកើតមានក្រោមរូបភាពថ្មីៗ និងស្មុគស្មាញ ដែលបង្កឱ្យមានការលំបាកទប់ស្កាត់ ហើយរបៀបនៃការប្រព្រឹត្តបទល្មើសមានការប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសពាក់ព័ន្ធក្នុងពិភពលោក និងបច្ចេកវិទ្យាកាន់តែទំនើប និងកាន់តែអាចំកំបាំងគួបផ្សំនឹងការគ្រប់គ្រងចិត្តសាស្ត្រលើជនរងគ្រោះបានធ្វើឱ្យការស៊ើបអង្កេត និងបង្ក្រាបកាន់តែលំបាកឡើងដែលធ្វើឱ្យយើងប្រឈមថ្មីៗក្នុងការរៀបចំយុទ្ធសាស្ត្រ និងយុទ្ធវិធី និងសកម្មភាពដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនោះឱ្យមានប្រសិទ្ធភាព»។

ជាមួយគ្នានេះលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានលើកឡើងដែរថា ផែនការយុទ្ធសាស្ត្រជាតិឆ្នាំ ២០១៩-២០២៣ នេះគឺមានគោលដៅកាត់បន្ថយឱ្យបាននូវទម្រង់អំពើជួញដូរមនុស្ស និងផ្លូវភេទថ្មីៗដែលទើបកើតមានឡើងដូចជា ការជួញដូរទារកតាមរយៈការពពោះជំនួស និងអំពើជួញដូរផ្លូវភេទ តាមបច្ចេកវិទ្យាដែលមានផ្សព្វផ្សាយរូបភាពអាសអាភាសតាមអនឡាញ រួមទាំងទម្រង់នៃការកើនឡើងវិញនូវសេវាកម្សាន្តសប្បាយដែលមានបង្កប់សេវាផ្លូវភេទ។ លោកស្រីថា៖ «កាលពីពេលមុន បទល្មើសជួញដូរមនុស្សបានកើតឡើងច្រើន ប៉ុន្តែអាជ្ញាធរបង្ក្រាបបានតិចតួចប៉ុណ្ណោះ ឬការបង្ក្រាបខ្លះទៀតមិនបានចំគោលដៅនោះទេ។ តែបច្ចុប្បន្ននេះថ្វីដ្បិតមានបទល្មើសជួញដូរមនុស្សនៅតែកើតឡើងច្រើន ប៉ុន្តែការបង្ក្រាបក៏បានច្រើនករណីដែរក្នុងនោះក៏មានករណីជនជាតិបរទេសជួញដូរជនជាតិបរទេសដូចគ្នាជាច្រើនករណីដែលត្រូវសមត្ថកិច្ចចាប់បញ្ជូនតាមយន្តហោះជាបន្តបន្ទាប់ទៅទទួលទោសនៅប្រទេសកំណើតវិញ»។

តាមរបាយការណ៍ពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរបានបង្ហាញថា ក្នុងមួយឆមាសទី ១ ឆ្នាំ ២០១៩ អាជ្ញាធរបង្ក្រាបបានករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន ៧៨ ករណី ឃាត់ខ្លួនជនសង្ស័យបានចំនួន ៩៧ នាក់ និងសង្គ្រោះបានជនរងគ្រោះបាន ២៦៣ នាក់ ខណៈកាលពីឆមាសទី ១ ក្នុងឆ្នាំ ២០១៨ បង្ក្រាបបាន ៦២ ករណី ឃាត់ខ្លួនជនសង្ស័យបានតែ ៨៥ នាក់ និងសង្គ្រោះបានជនរងគ្រោះចំនួន ១០៦ នាក់។ លោកស្រី ជូ ប៊ុនអេង បញ្ជាក់ដែរថា ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះគឺមានបំណងធានាឱ្យមានប្រព័ន្ធ គាំពារសង្គមដើម្បីបង្ការទប់ស្កាត់ភាពរងគ្រោះឱ្យមានប្រសិទ្ធភាព ការអនុវត្តច្បាប់ដែលមានឥទ្ធិពល និងការផ្តន្ទាទោសយ៉ាងសុក្រឹតចំពោះបទឧក្រិដ្ឋនេះ។

លោកស្រី មាស សាអ៊ីម អនុប្រធានផ្នែកសិទ្ធិស្ត្រី និងកុមារនៃសមាគមអាដហុកបានទទួលស្គាល់ថា រយៈពេលចុងក្រោយនេះអាជ្ញាធររាជរដ្ឋាភិបាលពិតជាបានខិតខំបង្ក្រាបការជួញដូរមនុស្សបានច្រើនករណីមែន៕

## ជួញដូរមនុស្ស៖ សម្តេច ស ខេង ថា មូលហេតុអាមេរិកឱ្យកម្ពុជាជាប់ថ្នាក់លេខ២ ដោយសារផ្ទៃក្នុងធ្វើការមិនយល់គ្នា

https://thmeythmey.com/ 24, Oct 2019 , 9:59 pm

ភ្នំពេញ៖ អាមេរិក បានដាក់ឱ្យកម្ពុជា ស្ថិតនៅចំណាត់ថ្នាក់ទី២ នៃរបាយការណ៍វាយតម្លៃពីការជួញដូរមនុស្សជាសកល។ ចំណាត់ថ្នាក់ទី២នេះ បង្ហាញថា កម្ពុជាស្ថិតនៅក្នុងរូបភាពអាក្រក់ នៃការជួញដូរមនុស្ស។ បើតាមសម្តេច ស ខេង មូលហេតុដែលកម្ពុជាស្ថិតនៅចំណាត់មិនល្អនេះ ដោយសារបញ្ហាមន្ត្រីអនុវត្តការងារ មិនយល់ចិត្តគ្នា។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្តេច ស ខេង បាននិយាយថា ការអនុវត្តការងារ ដោយមិនយល់ចិត្តគ្នានេះ ទើបធ្វើឱ្យកម្ពុជាស្ថិតនៅក្នុងការឃ្លាំមើល និងតាមដានពីសំណាក់អាមេរិក និងដៃគូពាក់ព័ន្ធ ជុំបញ្ហាជួញដូរមនុស្សនេះ។ មូលហេតុដែលសម្តេច ស ខេង អះអាងបែបនេះ ដោយសារសម្តេច បានទទួលព័ត៌មានថា មន្ត្រីកម្ពុជា មិនសូវបញ្ជូនរបាយការណ៍ការងារ ទៅអាមេរិក សម្រាប់ការវាយតម្លៃលើបញ្ហាជួញដូរមនុស្សនេះ។

ថ្លែងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រឹកថ្ងៃទី២៤ តុលានេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បាននិយាយដូច្នេះថា៖«សហរដ្ឋអាមេរិក តាមរយៈ

ក្រសួងការបរទេស ដែលតែងតែវាយតម្លៃដាក់ពិន្ទុឱ្យបណ្តាប្រទេសនានា នៅលើសាកលលោក មិនថាតែកម្ពុជានោះទេ បានផ្តល់ចំណាត់ឱ្យកម្ពុជាស្ថិតលំដាប់លេខ២ ក្រោមការឃ្លាំមើល។ ខ្ញុំបានសួរដេញដោលពីបញ្ហានេះ ជាមួយមន្ត្រីធ្វើការងារនេះរបស់យើងដែរ ថាតើមូលហេតុអ្វី? ពីព្រោះយើងបានបង្ក្រាបក៏ច្រើន បើកសវនាការកាត់ទោសក៏ច្រើន បើប្រៀបធៀបពីមុន។ ប៉ុន្តែចំណាត់ថ្នាក់ វាធ្លាក់ចុះ។ ដល់ពេលសួរចុះឡើងទៅ មកពីអត់មានរបាយការណ៍»។ រាល់បញ្ហាជួញដូរមនុស្សនៅក្នុងពិភពលោក គឺស្ថិតនៅក្រោមការវាយតម្លៃរបស់អាមេរិក ក្នុងការផ្តល់ចំណាត់ថ្នាក់ឱ្យបណ្តាប្រទេសនីមួយៗ។ សម្រាប់ការវាយតម្លៃនោះ គឺសហរដ្ឋអាមេរិក បានបែងចែកជា៣ថ្នាក់ ដោយក្នុងនោះចំណាត់ថ្នាក់ទី១ សំដៅទៅលើប្រទេសដែលមានការជួញដូរមនុស្សច្រើនបំផុត ឬជនរងគ្រោះដោយសារការជួញដូរច្រើន។ ចំណាត់ថ្នាក់ទី២ សំដៅលើប្រទេសដែលមិនបង្ហាញភស្តុតាងនៃការខិតខំប្រឹងប្រែង ក្នុងការបង្ក្រាប និងទប់ស្កាត់បទល្មើសជួញដូរមនុស្ស។ រីឯចំណាត់ថ្នាក់ទី៣ សំដៅទៅលើប្រទេសដែលមានការយកចិត្តទុកដាក់ទប់ស្កាត់បញ្ហាជួញដូរមនុស្ស តាមរយៈការបង្កើតគណៈកម្មការ សម្រាប់ចាត់វិធានការនានាលើបញ្ហានេះ។

ឆ្លើយតបនឹងកម្រិតថ្នាក់លេខ២ នៃការទប់ស្កាត់បទល្មើសជួញដូរមនុស្សនេះ សម្តេច ស ខេង បានសង្កត់ធ្ងន់ថា កម្ពុជាតែងតែឆន្ទៈ ក្នុងការបង្ក្រាប និងទប់ស្កាត់បញ្ហាជួញដូរមនុស្សនេះ ប៉ុន្តែមន្ត្រីអនុវត្តច្បាប់ បែរជាធ្វេសប្រហែសលើបញ្ហានេះទៅវិញ។ «អ៊ីចឹង មានន័យថា មិនមែនមកពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សវាធ្លាក់ចុះ ឬក៏ថារដ្ឋាភិបាលគ្មានឆន្ទៈ(ទប់ស្កាត់) ពិតប្រាកដនោះទេ ប៉ុន្តែដោយសារកិច្ចការងាររដ្ឋបាលរបស់យើង អត់បានសហការគ្នា។ វាមានចំណុចអត់សហការគ្នាល្អដែរ ដោយសារបានកាត់ទោស(ជនល្មើស) ប៉ុន្តែអត់មានព័ត៌មាន ដូច្នេះវាកើតមានបញ្ហា (ធ្វើឱ្យ) អ្នកមិនយល់ពីយើង គេថាយើងខ្សោយ...»។ នេះជាការបញ្ជាក់របស់សម្តេច ស ខេង។ បើតាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិបង្ក្រាប និងទប់ស្កាត់បទល្មើសជួញដូរមនុស្សនេះ មានសមាសភាពមកពីខាងអង្គភាពពាក់ព័ន្ធចំនួន៦ ដោយក្នុងនោះសមាសភាពពីខាងក្រសួងយុត្តិធម៌ គឺជាប្រធាន និងខាងក្រសួងមហាផ្ទៃ រួមស្ថាប័នផ្សេងជាសមាជិក។ «ខ្ញុំសូមស្នើថា កុំមានបញ្ហានេះ ទៅថ្ងៃមុខ នៅឆ្នាំ២០២០តទៅទៀត។ នេះជាការបន្ថែមរបស់ប្រមុខក្រសួងមហាផ្ទៃ។ ក្រៅពីកម្ពុជា ក៏មានប្រទេសវៀតណាម ម៉ាឡេស៊ី ប្រ៊ុយណេ និងឡាវជាដើម ក៏ជាប់ចំណាត់ថ្នាក់ទី២ដែរ៕

## រដ្ឋមន្ត្រីមហាផ្ទៃ៖កម្ពុជាមិនផ្ញើរបាយការណ៍ ជួញដូរមនុស្សទៅអាមេរិក ទើបគេឲ្យកម្ពុជាជាប់លេខ២

https://dap-news.com/ Posted on October 24, 2019

ភ្នំពេញ ៖ ក្រោយពីក្រសួងការបរទេសអាមេរិក បានវាយតម្លៃឲ្យកម្ពុជា ជាប់ចំណាក់ថ្នាក់លេខ២ ក្នុងករណីជួញដូរមនុស្ស សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបកស្រាយទៅវិញថា ដោយសារតែកម្ពុជា មិនបានផ្ញើរបាយការណ៍ ស្តីពី ការជួញដូរមនុស្សទៅអាមេរិក ទើបគេវាយតម្លៃឲ្យកម្ពុជា ជាប់ចំណាក់ថ្នាក់លេខ២បែបនេះ ខណៈកម្ពុជារឹតបន្តឹងយ៉ាងខ្លាំង និងកាត់ទោសជាបន្តបន្ទាប់ ចំពោះអ្នកប្រព្រឹត្ត ក្នុងករណីជួញដូរមនុស្ស ។

យោងតាមរបាយការណ៍ ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៨ របស់ក្រសួងការបរទេសអាមេរិក បានចេញផ្សាយថា កម្ពុជានៅតែបន្តរក្សាចំណាត់ទាបលេខ២ (Tier 2) ដដែលជាប់ៗគ្នា៣ឆ្នាំ គិតចាប់តាំងពីឆ្នាំ២០១៦ ព្រោះកម្ពុជានៅតែមិនទាន់គោរព បានពេញលេញតាមបទដ្ឋាន ដើម្បីលុបបំបាត់ការជួញដូរមនុស្ស។

ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ ផែនការយុទ្ធសាស្ត្រជាតិ២០១៩-២០២៣ ស្តីពី ការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ សម្តេច ស ខេង បានថ្លែងថា មិនមែនមកពីសកម្មភាព ប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្សនៅកម្ពុជាធ្លាក់ចុះនោះទេ ដោយសារតែកិច្ចការរដ្ឋបាល របស់ក្រសួងមហាផ្ទៃ និងភាគីពាក់ព័ន្ធមួយចំនួនទៀត អត់បានសហការគ្នា ទើបអត់មានរបាយការណ៍ផ្ញើទៅអាមេរិក ហើយគេឲ្យកម្ពុជាជាប់លេខ២ ក្នុងការឃ្លាំមើល ។ សម្តេចមានប្រសាសន៍ថា "សហរដ្ឋអាមេរិក តាមរយៈក្រសួងការបរទេស ដែលតែតែងធ្វើការវាយតម្លៃដាក់ពន្ទុឲ្យប្រទេសនានានៅលើសកលលោក បានផ្តល់ចំណាត់ថ្នាក់ឲ្យកម្ពុជា ស្ថិតក្នុងលំដាប់ទី២ ក្រោមការឃ្លាំមើល" ។ សម្តេចបន្តថា "ខ្ញុំបានសួរដេញដាលអំពីបញ្ហានេះ នៅមន្ត្រីការងារនេះ តើមានមូលហេតុអ្វី? ពីព្រោះថា យើងបានបង្ក្រាបក៏បានច្រើន យើងបើកសេវនាការ កាត់ទោសក៏បានច្រើន បើប្រៀបធៀបពេលមុន។ ប៉ុន្តែចំណាត់ថ្នាក់ធ្លាក់ចុះដល់សួរចុះសួរឡើងទៅថា មកពីអត់មានរបាយការណ៍ ដល់អត់មានរបាយការណ៍ អ្នកដែលធ្វើរបាយការណ៍ ដើម្បីកំណត់ចំណាត់ថ្នាក់នោះ អត់មានព័ត៌មាន ចឹងគេដាក់លេខ២ ក្រោមការឃ្លាំមើលទៅ" ។

ដើម្បីឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ មានប្រសិទ្ធិភាព សម្តេច ស ខេង ស្នើទៅភាគីពាក់ព័ន្ធយកចិត្តទុកដាក់សរសេររបាយការណ៍បញ្ជូនទៅអាមេរិក ធ្វើយ៉ាងណាកុំឲ្យមានបញ្ហានេះកើតមានឡើងទៀត ព្រោះរាជរដ្ឋាភិបាលមានឆន្ទៈពិតប្រាកដក្នុងការប្រយុទ្ធប្រឆាំងជួញដូរមនុស្ស ។

សូមរំលឹកថា ឆមាសទី១ ឆ្នាំ២០១៩ សមត្ថកិច្ចបានជួយសង្គ្រោះជនរងគ្រោះ ចេញពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទចំនួន២៦៣នាក់ កើន១៥៧នាក់ ស្មើនឹង១៤៨% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៨ ៕
ដោយ ៖ អេង ប៊ូឆេង

## នគរបាលខណ្ឌដូនពេញ បន្តចុះប្រតិបត្តិការបង្ក្រាបស្ត្រីរកស៊ីផ្លូវភេទជុំវិញរង្វង់មូលវត្តភ្នំ

http://nokorwatnews.com/archives/ 25-10-2019

ភ្នំពេញ៖ ស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរ(អ្នកចាប់ម៉ូយ)ចំនួន៤នាក់ ត្រូវបានកម្លាំងនគរបាលខណ្ឌដូនពេញបន្តចុះប្រតិបត្តិការបង្ក្រាប និងឃាត់ខ្លួនដាក់ស្លែង នៅត្រង់ចំណុចរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ កាលពីយប់ ថ្ងៃទី២៣ និង២៤ ខែតុលា ឆ្នាំ២០១៩ ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ សង្កាត់វត្តភ្នំពេញ ខណ្ឌដូនពេញ ។ មន្ត្រីនគរបាលខណ្ឌដូនពេញ បានឲ្យដឹងថា ដោយអនុវត្តន៍តាមបទបញ្ជាដឹកនាំដ៏ខ្ពង់ខ្ពស់របស់ លោកឧត្តមសេនិយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ និងលោកសុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ សមត្ថកិច្ចត្រូវតែបន្តចុះអនុវត្តជាប្រចាំថ្ងៃ ដើម្បីបង្ក្រាបករណីស្ត្រីកសុ ីផ្លូវភេទ និងអ្នកគកជេរ(អ្នកចាប់ម៉ូយ) ទាំងអស់នោះ កុំឲ្យមានឈរតាមផ្លូវបង្កភាពអនាធិបតេយ្យ ។ ជាលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ សមត្ថកិច្ចប្រមូលបានសរុបរួមចំនួន៧នាក់ ក្នុងនោះស្រី៥នាក់ ។

ចំពោះមុខ អធិការដ្ឋានខណ្ឌបានបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរចំនួន៧នាក់ខាងលើនេះ ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ហើយកិច្ចប្រតិបត្តិការនេះសមត្ថកិច្ចនឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ ៕ស ស្មើ

## កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត

https://www.facebook.com/deputygovernoryousophear/ 24-10-2019 លេខាធិការដ្ឋាន គខបជសៀមរាប

ខេត្តសៀមរាប៖ ថ្ងៃព្រហស្បតិ៍ទី២៤ ខែតុលា ឆ្នាំ២០១៩ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) បានរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពី "កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត" ដល់ថ្នាក់ដឹកនាំ និងមន្ត្រីដែលអញ្ជើញមកពីបណ្តាលមន្ទីរអង្គភាព ជាសមាជិកលេខាធិការដ្ឋាន ចំនួន១៣នាក់ ស្រី០៧នាក់ នៅរដ្ឋបាលសាលាខេត្តសៀមរាប។

កម្មវិធីនេះមានគោលបំណងលើកកម្ពស់ការយល់ដឹងស្តីពី អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ អ៊ីនធឺណិត បណ្តាញរាយការណ៍ពិសេស និងដំណើរការនៃការរាយការណ៍ ក្នុងចំណោមមន្ត្រីសមាជិកសមាជិកានៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដើម្បីជំរុញឲ្យមានការរាយការណ៍អំពីសម្ភាររំលោភបំពានកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងការចូលរួមផ្សព្វផ្សាយព័ត៌មានបន្តទៅកាន់សហគមន៍នានា។ ដោយមានការកើនឡើងនៃកំណើនប្រជាជនទូទាំងសាកលលោក ហើយកំណើននៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក៏បានកើនឡើងផងដែរទៅតាមសាកលភាវូនីយកម្ម។

គួយ៉ាងដូចជាប្រទេសកម្ពុជាដែលមានប្រជាពលរដ្ឋតែជាង១៥លាននាក់ប៉ុណ្ណោះ ប៉ុន្តែទិន្នន័យនៃអ្នកប្រើប្រាស់អ៊ីនធឺណិតមានទៅដល់ជាង១៣លាននាក់ ហើយក្នុងនោះក៏មានអ្នកដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនេះសម្រាប់ជាមធ្យោបាយក្នុងការកេងប្រវ័ញ្ចផ្សេងៗ ឬការរំលោភបំពានផ្លូវភេទជាដើម ពិសេសកុមារ។ ទាំងនេះហើយដែលជាបញ្ហាដែលរាជរដ្ឋាភិបាល និងអង្គការដៃគូជាតិ អន្តរជាតិ បាននឹងកំពុងយកចិត្តទុកដាក់ការទប់ស្កាត់អំពើកេងប្រវ័ញ្ចនានា និងធ្វើការផ្សព្វផ្សាយអំពីសុវត្ថិភាពនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាទៅប្រជាជន ពិសេសយុវជន ដែលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ កិច្ចប្រជុំនេះបានធ្វើការពិភាក្សាលើបញ្ហាមួយចំនួនអំពីការបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ យន្តការនៃការរាយការណ៍ និងការជួយដល់ជនរងគ្រោះ ក្នុងការក្របខ័ណ្ឌច្បាប់។

## កម្ពុជា ស្នើអាមេរិក ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពីរឿងបញ្ជូនពលរដ្ឋខ្មែរ-អាមេរិចកាំងមានទោសមកកម្ពុជាវិញ ដោយផ្តោតលើគោលការណ៍មនុស្សធម៌

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 25 October 2019 | 08:58 ICT

**ភ្នំពេញ:** រដ្ឋមន្ត្រីការបរទេសលោក ប្រាក់ សុខុន ពីម្សិលមិញបានស្នើឲ្យរដ្ឋាភិបាលសហរដ្ឋអាមេរិកធ្វើវិសោធនកម្មកិច្ចព្រមព្រៀង (MoU) ជុំវិញការចាប់បញ្ជូនពលរដ្ឋខ្មែរ-អាមេរិកាំងមានទោសមកកម្ពុជាវិញ ដោយសារវិធានការនេះធ្វើឱ្យពួកគេមិនសប្បាយចិត្តអាចធ្វើអត្តឃាត បើពួកគេមិនបានរស់នៅជួបជុំគ្រួសារ។ សំណើនេះឯកអគ្គរដ្ឋទូតថ្មីអាមេរិកប្រចាំកម្ពុជាអះអាងថា នឹងលើកទៅពិចារណា។

សំណើនេះធ្វើឡើងក្នុងអំឡុងពេលលោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួបពិភាក្សាការងារជាមួយលោក W.Patrick Murphy ឯកអគ្គរដ្ឋទូតថ្មីអាមេរិកប្រចាំកម្ពុជាមុនពេលលោកជួបជាមួយលោក Christian Berger ឯកអគ្គរដ្ឋទូតថ្មីអាល្លឺម៉ង់ប្រចាំកម្ពុជានៅទីស្តីការក្រសួងការបរទេស ដើម្បីសម្តែងការគួរសមមុនពេលចូលកាន់តំណែងពេញសិទ្ធិរបស់ខ្លួននៅកម្ពុជា។

បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សានេះលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិប្រាប់ក្រុមអ្នកសារព័ត៌មានថា លោក ប្រាក់ សុខុន បានលើកឡើងពីបញ្ហាមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរមួយចំនួនដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកបានចាប់បញ្ជូនមកកម្ពុជាវិញជាបន្តបន្ទាប់។ លោករដ្ឋមន្ត្រីបានស្នើសុំឲ្យមានវិសោធនកម្មចំពោះ MoU ជាលក្ខណៈយោគយល់គ្នាដែលបានធ្វើឡើងកន្លងមក ដើម្បីឲ្យពលរដ្ឋខ្មែរ-អាមេរិកកាំង អាចមានឱកាសរស់នៅជួបជុំបងប្អូន សាច់ញាតិ និងគ្រួសារពួកគេឡើងវិញដោយផ្តោតទៅលើគោលការណ៍មនុស្សធម៌។ លោកបន្ថែមថា ប្រសិនបើអាមេរិកបញ្ជូនពួកគេទាំងដែលពួកគេមិនមានសាច់ញាតិនៅកម្ពុជាអាចធ្វើឲ្យពួកគេខ្លះមិនសប្បាយចិត្ត និងឈានទៅធ្វើអត្តឃាត។ ដូច្នេះសហរដ្ឋអាមេរិកជួយកែប្រែចំណុចខ្លះក្នុង MoU ក្នុងន័យលើកស្ទួយមនុស្សធម៌។ លោក កុយ គួង បញ្ជាក់ថា៖ «កម្ពុជាយើងបានស្នើឲ្យមានវិសោធនកម្មទៅលើ MoU ដែលយើងបានធ្វើកន្លងមក យើងស្នើទៅសហរដ្ឋអាមេរិក យើងផ្តោតទៅលើគោលការណ៍មនុស្សធម៌ យើងចង់ធ្វើយ៉ាងណា គឺអ្នកដែលអាមេរិកបញ្ជូនមកអាចឲ្យពួកគាត់មានឱកាសបានជួបបងប្អូន សាច់ញាតិ កូនចៅគាត់។ ទោះបីជានៅអាមេរិកក៏ដោយនៅប្រទេសកម្ពុជាក៏ដោយ គឺត្រូវឲ្យពួកគាត់រស់នៅជួបជុំគ្នា»។ លោក កុយ គួង បានដកស្រង់សម្តីលោក W.Patrick

Murphy ឯកអគ្គរដ្ឋទូតអាមេរិកថ្មីប្រចាំកម្ពុជាថា រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងលើកយកសំណើនេះទៅពិភាក្សាគ្នាជាមួយមន្ត្រីពាក់ព័ន្ធទើបអាចបញ្ជាក់ប្រាប់មករដ្ឋាភិបាលកម្ពុជាវិញនាពេលក្រោយទៀត។

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ (LICADHO) គាំទ្រឲ្យមានការកែប្រែនូវចំណុចមួយចំនួនដែលលោក ប្រាក់ សុខុន បានលើកឡើងនេះ ព្រោះសហរដ្ឋអាមេរិកគឺជាប្រទេសគោរពសិទ្ធិមនុស្ស។ដូច្នេះគួរពិចារណានូវចំណុចដែលធ្វើឲ្យប្រសើរឡើងសិទ្ធិមនុស្សជាក់ស្តែងដូចជាជនជាតិខ្មែរនេះ។ លោកថ្លែងថា៖ «កន្លងមកគឺធ្លាប់មានបញ្ហាកើតឡើងមែន ព្រោះអ្នកខ្លះកើតនៅសហរដ្ឋអាមេរិក គាត់មានឪពុកម្តាយនៅហ្នឹងដែរ។ តែពេលគាត់មានទោសត្រូវបញ្ជូនគាត់មកស្រុកខ្មែរវិញ គឺអ្នកខ្លះមានសាច់ញាតិចាំទទួល រីឯអ្នកខ្លះគ្មានសាច់ញាតិចាំទទួលទេ។ អ៊ីចឹងអ្នកដែលគ្មានសាច់ញាតិនៅខ្មែរនៅចាំទទួលនេះហើយដែលជាបញ្ហាសម្រាប់ពួកគាត់ ហើយខ្ញុំសង្ឃឹមថា អាមេរិកនឹងពិចារណាលើបញ្ហានេះ»។

តាមរបាយការណ៍របស់អង្គការធ្វើការផ្នែកច្បាប់ និងសិទ្ធិមនុស្សឈ្មោះថា Asian Americans Advancing Justice (AAJC) ឲ្យដឹងកន្លងមកនេះថា កាលពីខែកក្កដា ពលរដ្ឋខ្មែរ-អាមេរិចកាំង ៣៧ នាក់ ត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ ដោយចាកចេញពីទីក្រុងដាឡាស រដ្ឋតិចសាស់ សហរដ្ឋអាមេរិក។ គិតចាប់ពីឆ្នាំ ២០០២ បន្ទាប់ពីមានកិច្ចព្រមព្រៀងរវាងកម្ពុជា-អាមេរិករួចមក ពលរដ្ឋខ្មែរ-អាមេរិកាំង ប្រមាណ ៨០០ នាក់ ត្រូវបានចាប់បញ្ជូនមកកម្ពុជាវិញហើយ រហូតមកដល់ឆ្នាំ ២០១៩ នេះ។

នាយកដ្ឋានអន្តោប្រវេសន៍ និងគយសហរដ្ឋអាមេរិកបានបញ្ជាក់នាពេលនោះថា ការបណ្តេញចេញពលរដ្ឋកម្ពុជាបានកើនឡើង ២៧៩ ភាគរយនៅឆ្នាំ ២០១៨ ប្រៀបធៀបទៅនឹងឆ្នាំ ២០១៧។ ប៉ុន្តែមិនបានបញ្ជាក់អំពីតួលេខប៉ុន្មានភាគរយក្នុងឆ្នាំ ២០១៧ នោះទេ។ នាយកដ្ឋានដដែលក៏បានបញ្ជាក់ថា មានពលរដ្ឋខ្មែរប្រមាណ ១ ៩០០ នាក់ដែលមានដីកាបណ្តេញចេញហើយកំពុងរស់នៅសហរដ្ឋអាមេរិក។ ក្នុងចំនួននេះមានចំនួន ១ ៤០០ នាក់គឺជាឧក្រិដ្ឋជនដែលត្រូវបានកាត់ទោសរួចហើយ។

ក្រោយពីបញ្ចប់ជំនួបជាមួយលោក W.Patrick Murphy រួចមកនៅថ្ងៃដដែលនោះលោក ប្រាក់ សុខុន ក៏បានជួបជាមួយលោក Christian Berger ឯកអគ្គរដ្ឋទូតថ្មីអាល្លឺម៉ង់ប្រចាំកម្ពុជាផងដែរ ដើម្បីសម្តែងការគួរសម។

ក្រោយជំនួបនោះលោក កុយ គួង ថ្លែងថា លោក Christian Berger បានបង្ហាញឆន្ទៈមុតមាំ ដើម្បីធ្វើយ៉ាងណាឲ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងអាល្លឺម៉ង់មានលក្ខណៈកាន់តែស៊ីជម្រៅ និងរីកចម្រើនឡើងថែមទៀត។ លោកថាលោកឯកអគ្គរដ្ឋទូតថែមទាំងបង្ហាញឆន្ទៈចង់ឃើញសហគមន៍អឺរ៉ុបរក្សាប្រព័ន្ធអនុគ្រោះពន្ធ EBA ដល់ប្រទេសកម្ពុជា ដើម្បីប្រយោជន៍រវាងកម្ពុជា និងប្រយោជន៍អឺរ៉ុបបន្តទៀត។ លោក កុយ គួង បានបញ្ជាក់ថា៖ «លោកឯកអគ្គរដ្ឋទូត និងឧបនាយករដ្ឋមន្ត្រី (ប្រាក់ សុខុន) បានលើកឡើងពីបញ្ហា EBA ដែលកម្ពុជា និងអាល្លឺម៉ង់យល់ថា គឺជារឿងសំខាន់រវាងកម្ពុជា និងសហភាពអឺរ៉ុបក៏ដូចជាប្រទេសនីមួយៗនៅក្នុងអឺរ៉ុប។ ភាគីទាំង ២ ក៏បានផ្លាស់ប្តូរមតិយោបល់ ពិភាក្សាបញ្ហានេះថា យើងជំរុញ EBA ឲ្យមានលក្ខណៈទៅមុខ ធ្វើយ៉ាងណាឲ្យមានលក្ខណៈជាវិជ្ជមានជាមួយសហភាពអឺរ៉ុបក៏ដូចជាប្រទេសយើងផងដែរ ហើយយើងក៏មិនបាននិយាយដល់រឿងសិទ្ធិមនុស្ស ឬប្រជាធិបតេយ្យអ្វីទេ»៕

## ពលករខ្មែរម្នាក់ត្រូវរងគ្រោះដោយសាររថភ្លើងបុកប្រកាសស្វែងរកសាច់ញាតិឱ្យមកទទួលយកត្រឡប់មកស្រុកកំណើតវិញ

https://www.facebook.com/neakmeasnews/ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ ដោយ ជីវ័ន្ត គេហទំព័រ នាគមាស

(ខេត្តប៉ាធុមថានី ប្រទេសថៃ )៖ មន្ទីពេទ្យនៃប្រទេសថៃ ចេញសេចក្តីប្រកាសស្វែងរកសាច់ញាតិឱ្យមកទទួលយកខ្លួនទៅស្រុកកំណើតវិញ ក្រោយពលករខ្មែររូបនេះត្រូវបានរងគ្រោះថ្នាក់រថភ្លើងបុក ។ បច្ចុប្បន្នជនរងគ្រោះរូបនេះ

កំពុងសម្រាកនៅមន្ទីរពេទ្យថាមសាតព្វាំងស៊ិត ខេត្តប៉ាធុមថានី ប្រទេសថៃ។បើតាមលោក ប្រាក់ ភក្រ្គា ដែលជាពលខ្មែរ ធ្វើការនៅក្នុងប្រទេសថៃដូចគ្នាបានឲ្យដឹងថា នៅថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៩នេះជនរងគ្រោះ មានឈ្មោះ ឡូម ណេត អាយុ ៣១ឆ្នាំ បានជួបគ្រោះថ្នាក់រថភ្លើងបុក ដោយសារតែពលករខ្មែររូបនេះស្រវឹងស្រា កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ កន្លងទៅ ហើយត្រូវបានបញ្ជូនទៅសង្គ្រោះនៅ មន្ទីរពេទ្យថាមសាតព្វាំងស៊ិតបច្ចុប្បន្នខាងមន្ទីរពេទ្យ ប្រកាសរកសាច់ញាតិ ដើម្បីមកទទួលជនរងគ្រោះវិលត្រឡប់ទៅ ប្រទេសកម្ពុជា វិញ ព្រោះជនរងគ្រោះបានជាសះស្បើយហើយ លោកបានបញ្ជាក់ដែរថា ក្រុមគ្រូពេទ្យថៃ និងរូបលោកផ្ទាល់ពិបាកនៅក្នុងការទំនាក់ទំនងស្វែងរកសាច់ញាតិជនរងគ្រោះ ដោយសារ តែជនរងគ្រោះមិនអាចនិយាយបាន ហើយគ្មានឯកសារបញ្ជាក់ទីលំនៅ មានតែឯកសារឈ្មោះនៅក្នុងប្រទេសថៃតែប៉ុណ្ណោះ៕

## សាកសពរកឃើញនៅក្នុងរថយន្តដឹកទំនិញប្រទេសអង់គ្លេស ជាជនជាតិចិន ជាករណីជួញដូរមនុស្សឆ្លងដែន

http://khmer.peoplenews.asia/ ដោយ ៖ SOVANNA ROTH ថ្ងៃទី25 ខែ10 ឆ្នាំ2019 ម៉ោង 12:28 PM

ប្រទេសអង់គ្លេស៖ ប៉ូលិសអង់គ្លេសបាន បញ្ជាក់ថា៖ សាកសព៣៩នាក់នោះ មានមនុស្សពេញវ័យ៣៨នាក់ និង យុវជនម្នាក់ ក្នុងនោះ ស្ត្រី៨នាក់ និង បុរស៣១នាក់ បានស្លាប់នៅក្នុងរថយន្ត ដឹកទំនិញភ្លាស្សេ មានសីតណ្ហភាព ត្រជាក់ក្រោមសូន្យ ដល់ទៅដក២៥ ។ ដោយសារតែ អ្នកទាំងនោះ នៅក្នុងរថយន្តដល់ទៅ១០ម៉ោង ទើបស្លាប់ ពេលទៅដល់ តំបន់ឧស្សាហកម្ម ភាគខាងកើតទីក្រុងឡុងដុងប្រទេសអង់គ្លេស។ នៅពេលនេះដែរ ក្រុមហ៊ុន អៀកឡង់ ដែលជាម្ចាស់កម្មសិទ្ធិរថយន្តដឹកទំនិញខាងលើបានឲ្យដឹងថា៖ ពួកគាត់បានសហការជាមួយប៉ូលិសដើម្បីស្រាវជ្រាវករណីខាងលើ ។ ក្រុមហ៊ុនរថយន្តដឹកទំនិញបានបញ្ជាក់ថា៖ មិនមានការពាក់ព័ន្ធជាមួយ អ្នកបើកបររថយន្តឈ្មោះ MO ROBINSON អាយុ២៥ឆ្នាំនោះឡើយ។អគ្គរដ្ឋទូតចិនប្រចាំនៅអង់គ្លេស លោក LIU XAOMING បានបញ្ជាក់ថា៖ ស្ថានទូតបានបញ្ជូនមន្ត្រីជំនាញទៅកាន់ តំបន់ ESSEX ដើម្បីធ្វើការជាមួយ កម្លាំងសន្តិសុខអង់គ្លេស ។

ភាពសាហាវឃោឃៅរបស់ក្រុមជួញដូរ មនុស្ស បានបែកធ្លាយក្រោយពេល រកឃើញសាកសព៣៩នាក់ នៅក្នុងរថយន្តកុងទីន័រ ភ្លាស្សេ តំបន់ Essex ប្រទេសអង់គ្លេស គ្រាន់តែជាផ្នែកមួយតូចប៉ុណ្ណោះ ការពិតនៅមានមនុស្សស្លាប់ជាច្រើន លើសពីការស្មាន។ ក្រុមជួញដូរមនុស្ស គឺមានភាពសាហាវឃោឃៅ ដូចទៅនឹងក្រុមជួញដូរគ្រឿងញៀន នៅលើពិភពលោកផងដែរ។ ប៉ុន្តែក្រុមជួញដូគ្រឿងញៀន បានដឹកជញ្ជូនទំនិញ។ ដោយឡែកអ្នកជួញដូរមនុស្សវិញ ក៏បានដឹកជញ្ជូនដូចគ្នាតែជាមនុស្ស និងសាកសព ។ ក្រុមជួញដូរមនុស្ស រកបានទឹកប្រាក់រហូតដល់ទៅ៧ពាន់លានដុល្លារ និងទាក់ទាញមនុស្សជាច្រើនចូលទៅកាន់ប្រទេសអង់គ្លេសដោយខុសច្បាប់។

សារព័ត៌មាន the Sun បានធ្វើបទសម្ភាសន៍ ជាមួយក្រុមអ្នកឯកទេស ពាក់ព័ន្ធនិងការជួញដូរមនុស្ស ។ ក្រុមជួញដូរមនុស្ស បានផ្ទុះអាវុធ បង្ខំឲ្យជនភៀសខ្លួន ឡើងរថយន្តដឹកទំនិញ របស់ខ្លួន ហើយបើកបរទៅតាមផ្លូវ ថ្មីដែលមិនមានការត្រួតពិនិត្យតឹងតែង។ ការជួញដូរមនុស្សកើនឡើងក្រោយពេលមានជនភៀសខ្លួន ជាច្រើន ព្យាយាមចូលទៅកាន់តំបន់អឺរ៉ុប គេចពីអំពើហិង្សា និងសង្គ្រាមនៅក្នុងប្រទេសរបស់ខ្លួន។ ការរកឃើញសាកសព៣៩ នាក់ នៅក្នុងប្រទេសអង់គ្លេស គ្រាន់តែជាផ្នែកមួយតូចនៃការជួញដូរមនុស្សតែប៉ុណ្ណោះ និងជារឿងពិបាកទប់ស្កាត់បំផុតសម្រាប់ប្រទេសអង់គ្លេស ដោយរថយន្តដឹកទំនិញ ត្រូវបានប្រើប្រាស់ដើម្បីដឹកមនុស្ស។ កាលពីឆ្នាំ២០០០ មានជនភៀសខ្លួន៥៨នាក់ មកពីប្រទេសចិន ត្រូវបានគេរកឃើញស្លាប់ទាំងអស់នៅក្នុងរថយន្ត កុងទីន័រ នៅកំពុងផែ Dover ស្ថិតនៅក្នុងតំបន់Kent នោះ។

តាមរបាយការណ៍ របស់អង្គការសហប្រជាជាតិ បានប្រកាសឲ្យដឹងថា«វិស័យឧស្សាហកម្មជួញដូរមនុស្សខុសច្បាប់ រកបានប្រាក់ចំណូលដល់ទៅ៧ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។ ក្រុមជួញដូរមនុស្ស គឺអាចរកប្រាក់ចំណូលបានច្រើនដូចជាការជួញដូរគ្រឿងញៀនផងដែរ ដោយសន្យា ឲ្យជនភៀសខ្លួនទាំងនោះ មានជីវភាពរស់នៅល្អប្រសើរក្នុងប្រទេសអ្នកមាន។ ជនភៀសខ្លួនខុសច្បាប់ម្នាក់ៗ ត្រូវ បង់ប្រាក់ឲ្យ ក្រុមជួញដូរមនុស្ស ដល់ទៅជាង១២ ពាន់ដុល្លារ៕

# ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៩

## អភិបាលខេត្តប៉ៃលិន ជួបពិភាក្សាការងារជាមួយប្រតិភូយោធាថៃ ខេត្តចន្ទបុរី+ត្រាត ដើម្បីពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អ

https://grandnewsasia.com/ ថ្ងៃសុក្រ ទី ២៥ តុលា ២០១៩

ប៉ៃលិនៈ នៅសាលាខេត្តប៉ៃលិន ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ លោក ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានអនុញ្ញាតឱ្យប្រតិភូយោធាថៃ ដែលដឹកនាំដោយ លោកវរៈនាវីឯក ជីឡូត សុខអាឡាម ប្រធានការិយាល័យទំនាក់ទំនងព្រំដែនថៃ+កម្ពុជា ប្រចាំខេត្តចាន់បូរី+ត្រាត ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ដើម្បីពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងខេត្តនៅជាប់ព្រំដែន នៃប្រទេសទាំង២ ឱ្យបានកាន់តែជិតស្និទ្ធថែមទៀត។

លោក ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានថ្លែងអំណរគុណចំពោះប្រតិភូការិយាល័យទំនាក់ទំនងព្រំដែនថៃ+កម្ពុជា ប្រចាំខេត្តចាន់បូរី+ត្រាត នៃព្រះរាជាណាចក្រថៃ ដែលបានអញ្ជើញមកជួបសម្ដែងការគួរសម និងពិភាក្សាការងារ ក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ នៅតាមព្រំដែនរវាងប្រទេសទាំង២ ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាពដ៏ល្អជាមួយគ្នា លើគ្រប់វិស័យ ជាពិសេសវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម និងពលករ នៅតាមបណ្ដោយព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា-ថៃឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។ លោកក៏បានសំនូមពរដល់ភាគីថៃ បន្តសហប្រតិបត្តិការនូវបញ្ហាមួយចំនួនដូចជា បញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់ ព្រមទាំងបទល្មើសឆ្លងដែននានា និងការនាំចេញកសិផល និងការធ្វើពាណិជកម្មឆ្លងដែនរវាងខេត្តចាន់បុរី-ប៉ៃលិន ជាពិសេសសហការបង្ករលក្ខណៈងាយស្រួលសម្រាប់ពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ បានធ្វើដំណើរចេញចូល ឆ្លងដែន ដោយសុវត្ថិភាព។

ជាការឆ្លើយតបលោកវរៈនាវីឯក ជីឡូត សុខអាឡាម ប្រធានការិយាល័យទំនាក់ទំនងព្រំដែនថៃ+កម្ពុជា ប្រចាំខេត្តចាន់បូរី+ត្រាត នៃព្រះរាជាណាចក្រថៃ បានសន្យាខិតខំសហប្រតិបត្តិការ និងដោះស្រាយនូវរាល់សំណូមពរ របស់រដ្ឋបាលខេត្តប៉ៃលិន ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ដើម្បីរកលទ្ធភាព និងដំណោះស្រាយ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២ ឱ្យបានកាន់តែល្អប្រសើរឡើង។ ក្នុងឱកាសនោះលោកវរៈនាវីឯក ក៏បានមានប្រសាសន៍កោតសសើរដល់រដ្ឋបាលខេត្តប៉ៃលិន ដែលកន្លងមកបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយខេត្តជាប់ព្រំដែននៃប្រទេសទាំង២ ដើម្បីរក្សាឱ្យបាននូវសន្តិសុខ សណ្ដាប់ធ្នាប់តាមបណ្ដោយព្រំដែន និងបម្រើឱ្យផលប្រយោជន៍របស់ប្រជាជន និងប្រទេសទាំង២ ដោយស្មើភាព និងស្មោះត្រង់៕

## ថៅកែជនជាតិចិន បង្ខាំងស្រីម៉ាស្សាជនជាតិថៃ៣នាក់ធ្វើការ២៤ម៉ោងនិងមិនបើកប្រាក់ខែត្រូវសមត្ថកិច្ចរំដោះបាន

http://nokorwatnews.com/ 26-10-2019

ខេត្តព្រះសីហនុ: កាលពីវេលាម៉ោង ១និង៣០នាទី រំលងអធ្រាត្រឈានចូលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចកម្ពុជា សហការជាមួយក្រុមតម្រួតថៃ បានចូលរំដោះនារីរងគ្រោះជាជនជាតិថៃ៣នាក់ នៅក្នុងហាងម៉ាស្សាមួយកន្លែង ក្នុងខេត្តព្រះសីហនុ ដែលគ្រប់គ្រងដោយជនជាតិចិន បានដោយសុវត្ថិភាព ព្រមទាំងបានឃាត់ខ្លួនជនជាតិចិន៣នាក់ផងដែរ ដើម្បីនាំខ្លួនយកមកសាកសួរ ។

ក្នុងករណីនេះ នារីរងគ្រោះជនជាតិថៃ៣នាក់ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមសមត្ថកិច្ចកម្ពុជា ដែលបានសហការយ៉ាងឆាប់រហ័ស ក្នុងការចូលទៅរំដោះពួកនាងចេញពីការចាប់បង្ខាំងខ្លួនពីការឃុំឃាំងរបស់ថៅកែចិន នៅក្នុងទីតាំងម៉ាស្សា២៤ម៉ោងលើ២៤ ម៉ោងមួយកន្លែង ក្នុងខេត្តព្រះសីហនុ ប្រទេសកម្ពុជា។ បន្ទាប់មកសមត្ថ

កិច្ចថៃ ក៏បានទំនាក់ទំនងទៅលោកឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង ដើម្បីចាត់កម្លាំងក្នុងការចូលរំដោះនារីរងគ្រោះបានជោគជ័យ ។

ក្នុងឱកាសនោះដែរ កុងស៊ុលថៃប្រចាំទីក្រុងភ្នំពេញ រួមជាមួយកម្លាំងសមត្ថកិច្ចកម្ពុជា បាននាំនារីរងគ្រោះមកសាកសួរ ដោយពួកនាងបានរៀបរាប់ថា ពួកនាងបានចូលទៅធ្វើការនៅក្នុងទីតាំងម៉ាស្សានោះជាង២ខែមកហើយ ដោយក្នុងកិច្ចសន្យាធ្វើតែ៨ម៉ោងប៉ុណ្ណោះ ក្នុង១ថ្ងៃ ប៉ុន្តែពេលចូលទៅធ្វើការ គឺប៉ាស្ព័រពួកនាង ត្រូវបានថៅកែចិនដកទុកទាំងអស់ ថែមទាំងបង្ខំអោយធ្វើការ២៤ម៉ោង ហើយគ្មានប្រាក់ខែ បើកឲ្យទៀត ពិសេស គឺនៅចុងក្រោយនេះ ពួកនាងម្នាក់ បានធ្លាក់ខ្លួនឈឺ ក៏គេមិនអនុញ្ញាតឲ្យចេញក្រៅ ដើម្បីទៅរកគ្រូពេទ្យដែរ ទើបពួកនាងលួចទាក់ទងទៅស្ថានីយតម្រួតក្នុងខេត្តស្រះកែវ ឲ្យជួយធ្វើអន្តរាគមន៍ជាមួយសមត្ថកិច្ចកម្ពុជា ។

ទីបំផុតនៅវេលាម៉ោង៥ល្ងាចថ្ងៃទី២៥ ខែតុលាឆ្នាំ២០១៩ សមត្ថកិច្ចកម្ពុជា ដឹកនាំដោយលោកឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ រួមជាមួយនឹងតំណាងស្ថានទូតថៃប្រចាំក្រុងភ្នំពេញ បានរំដោះនិងបញ្ជូននារីរងគ្រោះទាំង៣នាក់ទៅប្រគល់ឲ្យសមត្ថកិច្ចថៃ ប្រចាំច្រកអន្តរជាតិខ្លងលឹក ក្នុងស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ វិញ ដែលក្នុងនោះមានលោក បេនចៈផុន រ័តសារ៉ាត ប្រធានអន្តោប្រវេសន៍ ខេត្តស្រះកែវ កម្លាំងកងរយលេខ១២០១ និងកម្លាំងពាក់ព័ន្ធជាច្រើនទៀត។ ជាមួយគ្នានេះដែរអាជ្ញាធរថៃ និងស្ត្រីរងគ្រោះទាំង៣នាក់ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់សមត្ថកិច្ចកម្ពុជា ដែលបានធ្វើការទាន់ពេលវេលា ៕ ប្រាថ្នា

## ពលករខ្មែរនៅកូរ៉េ ជួយគ្រួសារនៅស្រុកខ្មែរឲ្យមានជីវភាពធូរធារ

https://www.postkhmer.com/ នៀម ឆេង | Publication date 28 October 2019 | 09:56 ICT

**សេអ៊ូល:** ពលករចំណាកស្រុកកម្ពុជាដែលទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង បានជួយឲ្យគ្រួសារនៅស្រុកខ្មែរមានជីវភាពធូរធារ ខណៈដែលពួកគេបានផ្ញើប្រាក់មកស្រុកខ្មែរប្រមាណជា ៦០០ លានដុល្លារក្នុង ១ ឆ្នាំៗ។ ម៉ោងប្រមាណ ៦ ល្ងាច កម្មករសំណង់ ២១ នាក់ ទើបតែបានចេញពីការដ្ឋានសាងសង់អាងស្តុកទឹកមួយនៅទីក្រុងគីមប៉ូ (Kimpo) ស្ថិតនៅចម្ងាយប្រមាណ ១៥ គីឡូម៉ែត្រ ពីទីក្រុងសេអ៊ូលប្រទេសកូរ៉េខាងត្បូង។ ពួកគេគឺជាពលករទៅពីប្រទេស កម្ពុជា ដែលបានចាប់ផ្តើមធ្វើការនៅការដ្ឋាននេះ ៣ ខែមកហើយ។

កម្មករម្នាក់ឈ្មោះ ខាត់ តុល អាយុ ៣៥ ឆ្នាំ គឺជាពលករមកពីខេត្តកំពង់ធំ។ បុរសដែលមានកូន ២ នាក់រូបនេះនិយាយថា សព្វថ្ងៃលោកសប្បាយចិត្តក្នុងការប្រកបការងារនៅក្នុងប្រទេសកូរ៉េ ជាពិសេសនៅការដ្ឋានសំណង់នេះ ដោយសារតែថៅកែចិត្តល្អ ហើយលោកមិនសូវជួបបញ្ហាអត់ការងារធ្វើដូចនៅកន្លែងផ្សេង។ ខាត់ តុល ថ្លែងថា៖ «ខ្ញុំមក ៣ ឆ្នាំហើយ ក្នុងអាណត្តិទី ២ តែអ្នកផ្សេងទើបមកបាន ១ ឆ្នាំ។ ពេលខ្ញុំមានថវិកាគ្រប់គ្រាន់ខ្ញុំនឹងត្រឡប់ទៅស្រុកខ្មែរវិញ ព្រោះនៅទីនេះលុយបានច្រើនមែន តែពិបាករស់នៅដែរដោយសារតែអាកាសធាតុ។ ឥឡូវខ្ញុំកំពុងសន្សំទិញរបស់របរទុកបានខ្លះដើម្បីពេលទៅវិញយើងបានធូរធារ»។

កម្មករម្នាក់ទៀតមកពីស្រុកពួក ខេត្តសៀមរាប ដែលសុំមិនបញ្ចេញឈ្មោះឲ្យដឹងថា លោកបានមកធ្វើការនៅប្រទេសកូរ៉េជាង ៣ ឆ្នាំហើយ ហើយការងាររបស់លោកនៅទីនេះបានជួយដោះបំណុលគ្រួសាររួចរាល់ហើយព្រមទាំងបានសន្សំប្រាក់សម្រាប់ទិញដីធ្វើកសិកម្មបាន ៥ ហិកតា និងបានទិញក្របើមកចិញ្ចឹមចំនួន ១២០ ក្បាល។ នៅមិនឆ្ងាយពីការដ្ឋាននេះមានរោងចក្រមួយឈ្មោះថា DI Eco Star ដែលផលិតគ្រឿងផ្ទាំងសម្រាប់នាំចេញ។ នៅទីនេះមានពលករខ្មែរចំនួន ៩ នាក់ ក្នុងចំណោមបុគ្គលិកសរុបប្រមាណ ៤០ នាក់។ ពលករម្នាក់ឈ្មោះ ថាន់ សេងហុង មានស្រុកកំណើតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានមកធ្វើការនៅប្រទេសកូរ៉េរយៈពេលជិត ៦ ឆ្នាំហើយ បន្ទាប់ពីបានជាប់អាណត្តិទី ២។

លោក សេង ហុង ថ្លែងថាលក្ខខណ្ឌការងារនៅទីនេះអាចទទួលយកបាន បើទោះជាហត់បន្តិចក៏ដោយ។ លោកចូលធ្វើការពីម៉ោង ៨ កន្លះព្រឹក រហូតដល់ម៉ោង ៨ យប់។ ប៉ុន្តែយូរៗម្តងខាងរោងចក្រតម្រូវឲ្យធ្វើការរហូតដល់យប់ជ្រៅ។ លោករស់នៅក្នុងអគារស្នាក់នៅក្នុងបរិវេណរោងចក្រ ប៉ុន្តែថៅកែបានកាត់ប្រាក់ខែសម្រាប់កន្លែងស្នាក់នៅ និងទឹកភ្លើង។

អ្នកស្រី Im Young Sook អ្នកគ្រប់គ្រងនៅរោងចក្រនេះបានឲ្យដឹងថា អ្នកស្រីពេញចិត្តពលករខ្មែរដោយនិយាយថា៖ «បុគ្គលិកខ្មែរភាគច្រើនខំប្រឹងធ្វើការបានយ៉ាងល្អ គាត់ពូកែ។ បើសិនគាត់ធ្វើការមិនល្អ ខ្ញុំមានសិទ្ធិដូរគាត់ចេញ ប៉ុន្តែសម្រាប់ខ្មែរគាត់ធ្វើការល្អហើយខ្ញុំពេញចិត្ត។ បើមិនអ៊ីចឹងទេ ខ្ញុំមិនបន្តអាណត្តិឲ្យពួកគេទេពេលចប់អាណត្តិ។ អ៊ីចឹងខ្ញុំពេញចិត្ត និងស្រឡាញ់ពួកគេ»។

ពលករម្នាក់ទៀតគឺកញ្ញា អាន ស្រីណែត អាយុ ២៩ ឆ្នាំមកពីស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំបានមកធ្វើការនៅប្រទេសកូរ៉េ ៤ ឆ្នាំ និងកំពុងធ្វើការនៅទីក្រុងក្វាងយូ ក្នុងរោងចក្រផលិតគ្រឿងឡានដែលស្ថិតនៅចម្ងាយប្រមាណ ៤៥០ គីឡូម៉ែត្រពីទីក្រុងសេអ៊ូល។ កញ្ញានិយាយថា៖ «យើងធ្វើការឲ្យគេពេលខ្លះពិបាក ពេលខ្លះសប្បាយចិត្ត។ យើងពិបាកត្រង់ថា យើងត្រូវធ្វើការពេញម៉ោង តែគេអត់គិតលុយឲ្យយើងពេញម៉ោងទេ ដូចជាម៉ោងបាយ យើងត្រូវសម្រាក តែយើងមិនអាចសម្រាកព្រោះម៉ាស៊ីនគេដំណើរការរហូត ដូច្នេះយើងត្រូវធ្វើការ តែគេអត់គិតលុយឲ្យយើង។ តែយើងសប្បាយចិត្តពេលយើងមានកន្លែងធ្វើការច្បាស់លាស់ ហើយការងារក៏មានប្រាក់ខែត្រឹមត្រូវ»។

កម្មករមួយចំនួនដែលត្រូវបានសម្ភាសបានលើកឡើងថា ការបើកប្រាក់ខែយឺតយ៉ាវ និងការធ្វើការច្រើនម៉ោងវាស្ទើរតែក្លាយជាបញ្ហាសាមញ្ញទៅហើយ សម្រាប់ពលករនៅកូរ៉េ។ បញ្ហានេះកើតឡើងជាក់ស្តែងសម្រាប់លោក សេង ហុង ដោយលោកថ្លែងថា៖ «ឥឡូវបានប្រាក់ខែច្រើនដែរ ប៉ុន្តែគ្រាន់តែថា ពេលខ្លះជំពាក់ ២ ខែទើបបើកម្តង។ ឥឡូវជំពាក់ជិត ៣ ខែហើយតាំងពីខែ ៨ មក។ ក្នុងឆ្នាំនេះពិបាក»។

លោក សាម៉ែន សុខា ទីប្រឹក្សាទទួលបន្ទុកការងារពលករអមស្ថានទូតខ្មែរ ប្រចាំសាធារណរដ្ឋកូរ៉េបានឲ្យដឹងថា ពលករទាំងខ្មែរក៏ដូចជាជាតិសាសន៍ដទៃទៀតមានបញ្ហាខ្លះពាក់ព័ន្ធនឹងការអនុវត្តខុសកិច្ចសន្យាការងារដោយថៅកែរួមមានការបើកប្រាក់ខែយឺត បញ្ហាក្នុងការស្នាក់នៅ វិវាទការងារពលករ និងថៅកែ វិវាទពលករ និងពលករ និងពលករខ្មែរជាមួយពលករបរទេសផ្សេងទៀតរួមទាំងគ្រោះថ្នាក់ការងារផ្សេងៗ។ លោកថា នៅពេលជួបបញ្ហាអ្វីមួយពលករគួរតែទាក់ទងស្ថានទូត ឬរកជំនួយនៅតាមមជ្ឈមណ្ឌលគាំពារពលករនៅតាមទីក្រុងនីមួយៗ។ លោកនិយាយថា៖ «នៅក្នុងច្បាប់កូរ៉េ គេបានកំណត់ថា បើមិនបើកប្រាក់ឲ្យគ្រប់ចំនួនប៉ុន្មានខែ ពលករមានសិទ្ធិស្នើសុំថៅកែឲ្យថៅកែស៊ីញ៉េចេញ ប៉ុន្តែមិនមែនមានន័យថា ថៅកែបាត់បង់កាតព្វកិច្ចបង់ប្រាក់ខែដែលមិនទាន់បានបើកឲ្យពលករទេ។ ក្នុងករណីនេះ ក្រុមការងារស្ថានទូតនឹងទំនាក់ទំនងទៅមជ្ឈមណ្ឌលគាំពារពលករក្នុងតំបន់នោះ និងទាក់ទងទៅថៅកែផ្ទាល់ឲ្យគាត់បើកប្រាក់ឲ្យពលករ។ បើថៅកែនៅតែមិនបើកឲ្យ យើងនឹងដាក់ពាក្យទៅក្រុមការងារមានកម្រិតលើនោះ ដើម្បីឲ្យថៅកែបើកប្រាក់ឲ្យ»។ លោកបន្តថា ក្នុងករណីមានគ្រោះថ្នាក់ការងារណាមួយកើតឡើង ក្រុមស្ថានទូតនឹងទាក់ទងទៅថៅកែកូរ៉េផ្ទាល់ ដើម្បីធានាថាពលករដែលគ្រោះថ្នាក់នោះទទួលបានការព្យាបាលពេញលេញ។ ក្នុងករណីគ្រោះថ្នាក់ស្រាល ពួកគាត់នៅទទួលបានប្រាក់ខែគោលដូចដែលមានចែងក្នុងច្បាប់របស់កូរ៉េ ហើយស្ថានទូតក៏ជួយសម្រួលដល់ពលករ ដើម្បីទាមទារប្រាក់សំណងស្របតាមច្បាប់កំណត់។ បើតាមលោក សុខា ពលករខ្មែរនៅកូរ៉េទទួលបានប្រាក់ខែជាមធ្យម ១៤០០ ដុល្លារក្នុង ១ ខែ។

កញ្ញា ស្រេង វួចនី គឺជាបុគ្គលិកមជ្ឈមណ្ឌលផ្តល់ប្រឹក្សាសម្រាប់ជនបរទេសក្នុងទីក្រុងអានសានដែលនៅទីនោះមានពលករ និងពលរដ្ឋខ្មែររស់នៅប្រមាណ ៦០០ នាក់។ កញ្ញាបានស្នើដល់ស្ត្រីដែលរៀបការប្តីកូរ៉េ និងពលករដែលមានបញ្ហាឲ្យទាក់ទងទៅមជ្ឈមណ្ឌល ដើម្បីទទួលបានការជួយរកដំណោះស្រាយ។ កញ្ញានិយាយថា បញ្ហាបើក

ប្រាក់ខែយឺត គឺជាបញ្ហាសាមញ្ញហើយកើតឡើងដោយសារថៅកែកេងប្រវ័ញ្ច ការដំឡើងប្រាក់ខែនៅក្នុងប្រទេសកូរ៉េ និងដោយសារបញ្ហាសេដ្ឋកិច្ចនៅទូទាំងពិភពលោកធ្លាក់ចុះ។ កញ្ញានិយាយថា កញ្ញាធ្លាប់បានជួបការលំបាកជាច្រើន រួចហើយនៅពេលមកប្រទេសកូរ៉េដំបូងរួមទាំងបញ្ហាភាសា និងការងារ។ ដោយសារតែយល់ពីបញ្ហាលំបាកនេះហើយ ទើបកញ្ញាសុខចិត្តធ្វើការនៅមជ្ឈមណ្ឌលផ្តល់ប្រឹក្សាដើម្បីជួយដល់ពលករខ្មែរនៅកូរ៉េ បើទោះបីជាការងារនេះកញ្ញាទទួលបានប្រាក់កម្រៃតិចតួចក៏ដោយ។ ក្រៅពីបញ្ហានៅកន្លែងការងារការមិនបានរៀបចំគោលដៅឲ្យបានច្បាស់គឺជាបញ្ហាមួយទៀតដែលពលករខ្មែរបានជួបប្រទះ។ កម្មករសំណង់ម្នាក់នៅទីក្រុង គីម ប៉ូ ដែលសុំមិនបញ្ចេញឈ្មោះបានឲ្យដឹងថា លោកបានមកដល់ទីនេះប្រមាណ ៣ ឆ្នាំ តែមិនសូវមានអ្វីសល់ទេ ដោយសារតែមិនសូវមានការងារធ្វើ ហើយលោកក៏មិនដឹងថា នាពេលខាងមុខលោកនឹងធ្វើអ្វីទៀតដែរ។

ស្រដៀងគ្នានេះពលការិនីម្នាក់ សុំមិនបញ្ចេញឈ្មោះមកពីខេត្តព្រៃវែងដែលស៊ីឈ្នួលបេះបន្លែក្នុងកសិដ្ឋានមួយដែលមានពលការិនីខ្មែរ ៦ នាក់ បានឲ្យដឹងថា កញ្ញាបានមកធ្វើការនៅកូរ៉េ ៤ ឆ្នាំ ៥ ខែហើយគឺជិតចប់អាណត្តិទី ១ ដែលមានរយៈពេល ៤ ឆ្នាំ ១០ ខែ។ កញ្ញានឹងត្រឡប់ទៅកម្ពុជាវិញពេលចប់អាណត្តិទី ១ នេះ ប៉ុន្តែមិនទាន់ដឹងច្បាស់ថានឹងប្រកបមុខរបរអ្វីទេ អាស្រ័យលើឱកាស ឬអាចត្រឡប់មកប្រទេសកូរ៉េម្តងទៀត។ ទោះយ៉ាងណាកញ្ញាបានជួយដោះបំណុលគ្រួសារដែលមានប្រមាណ ៤ ម៉ឺនដុល្លាររួចហើយ បូករួមទាំងដើមទុនសម្រាប់ត្រៀមមកធ្វើការនៅប្រទេសកូរ៉េ។

លោក គីម តារា ប្រហែលជាគំរូដល់ពលករខ្មែរដទៃទៀត។ បុរសដែលមានវ័យជាង ៣០ ឆ្នាំរូបនេះ បានទៅធ្វើការនៅប្រទេសកូរ៉េរយៈពេល ៧ ឆ្នាំហើយ ដោយដំបូងលោកបានធ្វើការនៅកន្លែងផលិតកប៉ាល់របស់ក្រុមហ៊ុនសាមស៊ុង។ ដោយមានសមត្ថភាពនិយាយភាសាកូរ៉េ និងចេះមើលប្លង់ផងនោះ តារា បានក្លាយជាអ្នកចាត់ការនៅក្រុមហ៊ុននោះ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ លោកទទួលបានបណ្ណបៃតង (green card) ដែលអាចរស់នៅប្រទេស កូរ៉េ ជាអចិន្ត្រៃយ៍។ លោកក៏បានឈប់ពីការងារនេះ ដោយចាប់ផ្តើមបើកមុខរបរនាំចូលយិនស៊ិនពីកូរ៉េមកលក់នៅកម្ពុជា។ លោក តារា បានមើលឃើញថាបញ្ហាមួយចំនួន ដែលពលករខ្មែររស់នៅកូរ៉េជួបប្រទះគឺការមិនមានផែនការជីវិតច្បាស់លាស់ នៅពេលពួកគេកំពុងបំពេញការងារ។ តារានិយាយថា៖ «មិនមែនពលករមកកូរ៉េទាំងអស់សុទ្ធតែនៅតែជាពលករទេ បើសិនយើងមានជំនាញអ្វីមួយ គេនឹងដំឡើងឲ្យយើង។ ករណីដូច្នេះមានច្រើនណាស់ ដូចជាអ្នកកាន់ម៉ាស៊ីនផលិតឡានបើគាត់មានជំនាញអ្វីមួយ គាត់អាចក្លាយជាប្រធានគ្រប់គ្រងបាន។ ដោយសារខ្ញុំចេះភាសា ហើយមានពលករខ្មែរ ៨ នាក់ ខ្ញុំក៏បានក្លាយជាប្រធានគ្រប់គ្រង។ ដំបូងខ្ញុំបានប្រាក់ខែតែ ១១០០ ដុល្លារទេ តែក្រោយមកឡើងដល់ជាង ៣០០០ ដុល្លារ»។ លោក តារា បានឲ្យដឹងថា ថៅកែភាគច្រើនចង់បានពលករមកពីកម្ពុជា ដោយសារតែពួកគេតស៊ូ និងប្រឹងប្រែងធ្វើការ។ ប៉ុន្តែលោកក៏បានរំឭកដល់ពលករកម្ពុជា ជាពិសេសអ្នកទើបមកថ្មីត្រូវមានគោលដៅច្បាស់លាស់ ដើម្បីចៀសវាងការធ្លាក់ខ្លួនជាពលករខុសច្បាប់។ លោកនិយាយថា៖ «ពួកគាត់គួរតែចេះរៀបគម្រោងគោលដៅទៅមុខ។ កុំបណ្តោយទៅតាមអ្វីដែលគាត់ធ្វើ ឬបណ្តោយតាមភាពវ័យក្មេងរបស់ខ្លួន។ អ្នកខ្លះមកភ្លើតភ្លើនវាយគ្នា ផឹកស្រាអូទីន្ទ។ អ្នកខ្លះមានវ័យក្មេងស្ទាវ ហើយគ្មានគោលដៅច្បាស់លាស់»។ លោកបន្តថា៖ «ខ្មែរយើងមានស្លាប់ច្រើន ១ ឆ្នាំៗ ដោយសារមានជំងឺ ហូបស្រាច្រើន អត់លេងកីឡា ជាពិសេសក្នុងខែត្រជាក់។ អ្នកខ្លះបានត្រឹមតែធ្វើការ បើកលុយផ្ញើទៅខ្មែរ សងធនាគារ ជូនឪពុកម្តាយ តែដល់ពេលត្រឡប់ទៅខ្មែរវិញ បន្ទាប់ពី ៤ ឆ្នាំ ១០ ខែ អ្នកខ្លះសល់ត្រឹមតែ ១ ម៉ឺនដុល្លារប៉ុណ្ណោះ។ ចំណុចនេះហើយដែលធ្វើឲ្យគាត់សម្រេចធ្វើការខុសច្បាប់ មិនត្រឡប់ទៅស្រុកខ្មែរវិញហើយប្រឈមបញ្ហាជាច្រើន»។

លោកចង់ចែករំលែកបទពិសោធរបស់លោកដល់ពលករផ្សេងទៀត ដែលនឹងធ្វើដំណើរមកកូរ៉េកុំឲ្យមានការស្តាយក្រោយ បន្ទាប់ពីបានចំណាយពេលធ្វើការនៅកូរ៉េហើយ ប៉ុន្តែចុងក្រោយមិនមានគោលដៅ។ លោក សុខា

និយាយថាមានគុណសម្បត្តិជាច្រើននៃការមកធ្វើការនៅប្រទេសកូរ៉េ នោះគឺការទទួលបានប្រាក់ខែច្រើនសម្រាប់ផ្គត់ផ្គង់គ្រួសារ ទទួលបានឱកាសអភិវឌ្ឍន៍សមត្ថភាពទៅតាមជំនាញដែលពួកគេធ្វើរួមទាំងភាសាកូរ៉េផង។ លោកស្នើឲ្យពលករទៅទទួលយកការបណ្តុះបណ្តាលជំនាញនៅតាមមជ្ឈមណ្ឌលគាំពារពលករនានា ដែលនៅទីនោះមានបង្រៀនវិជ្ជាជីវៈផ្សេងៗ សម្រាប់ពលករដោយឥតគិតថ្លៃរួមមានជំនាញបើករថយន្ត ជួសជុលរថយន្ត បើកត្រាក់ទ័រ ធ្វើនំ និងនំប៉័ង និងធុងកាហ្វេ។

លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េបានថ្លែងថា បច្ចុប្បន្នមានពលករកម្ពុជាកំពុងធ្វើការនៅប្រទេសកូរ៉េប្រមាណ ៤៥ ០០០ នាក់។ ប៉ុន្តែបើគិតទាំងស្ត្រីដែលរៀបការជាមួយបុរសកូរ៉េ និងចំនួននិស្សិតដែលកំពុងរៀននៅទីនេះមានពលរដ្ឋខ្មែរសរុបជាង ៦ ម៉ឺននាក់ ក្នុងប្រទេស កូរ៉េ។ លោកថាក្នុង ១ ឆ្នាំៗ ពលករកម្ពុជាផ្ញើប្រាក់ទៅក្រុមគ្រួសារសរុបប្រមាណ ៦០០ លានដុល្លារ។ លោក ឌីម៉ង់ បន្តថា ដោយសារតែពលរដ្ឋខ្មែររស់នៅតំបន់ផ្សេងៗឆ្ងាយពីក្រុងសេអ៊ូល ក្រុមការងារស្ថានទូតតែងធ្វើដំណើរស្ទើរតែរៀងរាល់ចុងសប្តាហ៍ ចុះទៅតាមតំបន់ទាំងនោះ ដើម្បីជួបពិគ្រោះយោបល់ សួរសុខទុក្ខ និងផ្តល់សេវាសាធារណៈដល់ពួកគេដូចជាពន្យារលិខិតឆ្លងដែនជាដើម។ លោកឯកអគ្គរាជទូតតែងក្រើនរំឭកដល់ពលករខ្មែរឲ្យរក្សាសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ព្រមទាំងសុខភាពផ្លូវចិត្តដែលទទួលសម្ពាធពីការងារ និងសម្ពាធពីក្រុមគ្រួសារនៅស្រុកខ្មែរ។ លោកក៏ស្នើឲ្យអាណាព្យាបាល ឬក្រុមគ្រួសាររបស់ពលករត្រូវយល់ពីស្ថានភាពលំបាករបស់ពលករផង ចៀសវាងដាក់សម្ពាធលើពួកគេ ហើយពលករត្រូវគោរពច្បាប់កូរ៉េក៏ដូចជាច្បាប់កម្ពុជា។

ក្នុងពេលដែលលោកជួបលោកស្រី Im Young Sook លោក ឌីម៉ង់ ក៏បានសុំដល់លោកស្រីឲ្យមានការយោគយល់ដល់ពលករខ្មែរក្នុងករណីមានការខ្វះចន្លោះក្នុងការងារណាមួយដោយលោកនិយាយទៅលោកស្រីថា៖ «លោកស្រីជាមនុស្សល្អហើយទើបប្រើប្រាស់សុទ្ធតែពលករអាណត្តិទី ២ ហើយពួកគាត់សរសើរថា លោកស្រីជាមនុស្សល្អ»។ លោកបន្តថា៖ «ខ្ញុំឆ្លៀតឱកាសនេះ ថ្លែងអំណរគុណគាត់ដែលគាត់បានទទួលយកបងប្អូនខ្មែរយើង ហើយគាត់បានយកចិត្តទុកដាក់ថែរក្សាពួកគាត់ហើយអត់ចាត់ទុកពលករខ្មែរដូចជាជនបរទេសទេគឺចាត់ទុកដូចជាពលរដ្ឋកូរ៉េដែរ សូមសរសើរ និងអរគុណ ហើយសូមបន្តធ្វើដូច្នេះតទៅទៀត»។

នៅសប្តាហ៍ទី ៤ នៃខែវិច្ឆិកាខាងមុខនេះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងចូលរួមក្នុងជំនួបកំពូលអាស៊ាន-កូរ៉េ នៅទីក្រុងប៊ូសាន។ លោក ឌីម៉ង់ ថ្លែងថា ក្រៅពីការចុះហត្ថលេខាលើឯកសារមួយចំនួនលោកសង្ឃឹមថានឹងមានការពិភាក្សាអំពីការដំឡើងកូតាពលករសម្រាប់កម្ពុជាផងដែរ។

លោក សុខា និយាយថាក្នុងចំណោម ១៦ ប្រទេសដែលបញ្ជូនពលករមកធ្វើការនៅកូរ៉េ កម្ពុជាជាប្រទេសទទួលបានការកោតសរសើរពីអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េក្នុងការប្រតិបត្តិតាមលក្ខខណ្ឌណែនាំផ្សេងៗរបស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ។ នេះជាបច្ច័យមួយក្នុងការទទួលបានកំណើនកូតាសម្រាប់ពលករខ្មែរក្នុងឆ្នាំ ២០២០។ លោក សុខា និយាយថា៖ «បងប្អូននេះហើយជាធនធានមនុស្សដ៏សំខាន់ ហើយសូមបងប្អូនមានផែនការជីវិត ព្រោះបងប្អូនធ្វើការទទួលបានប្រាក់កម្រៃខ្ពស់ហើយ តែបងប្អូនក៏ត្រូវរៀបចំចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់ជីវភាព និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមខ្មែរ»៕

## កម្លាំងអធិការកិច្ចនៃនាយកដ្ឋានការងារប្រចាំ ទីក្រុងបាងកក ប្រទេសថៃ ចុះធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ ខុសច្បាប់ចំនួន ០៥នាក់

https://www.facebook.com/prakpheaktraofficial/ ពាក់ ភក្ត្រា-Prak Pheaktra 25-10-2019

កម្លាំងអធិការកិច្ចនៃនាយកដ្ឋានការងារប្រចាំ ទីក្រុងបាងកក ប្រទេសថៃ ចុះធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ ខុសច្បាប់ចំនួន ០៥នាក់ បន្ទាប់ពីលួចធ្វើខុសច្បាប់ ដោយគ្មានប័ណ្ណអនុញ្ញាតិការងារ ការឃាត់ខ្លួននេះបានធ្វើឡើងនៅតូបលក់ពូក-សាឡុងងមួយទឹក មួយកន្លែងស្ថិត ក្នុងតំបន់ណាក់រម៉ឺន សង្កាត់បឹងកុមនៃ ទីក្រុងបាងកក ប្រទេសថៃ ។

## អាជ្ញាធរ អន្តោប្រវេសន៍ ខេត្តភូកេត ប្រទេសថៃ ធ្វើសន្និសីទកាសែតថ្លែងការណ៍ អំពីការបង្ក្រាបបណ្តាញជួញដូរមនុស្ស

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា-Prak Pheaktra 25-10-2019

កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តភូកេត ប្រទេសថៃ ធ្វើសន្និសីទកាសែតថ្លែងការណ៍អំពីការបង្ក្រាបបណ្តាញជួញដូរមនុស្សដែលនាំកុមារកម្ពុជា ចាប់ពីអាយុ១៣ឆ្នាំ ដល់១៦ឆ្នាំ មកធ្វើការបង្ខិតបង្ខំអោយដើរលក់វ៉ែនតាអោយភ្ញៀវទេសចរណ៍នៅក្នុងតំបន់ឆ្នេរសមុទ្រនៃសង្កាត់បាតង ខេត្តភូកេត ប្រទេសថៃ យោងតាមរបាយការណ៍របស់អាជ្ញាធរថៃ បានអោយដឹងថា កម្លាំងសមត្ថកិច្ចថៃបានធ្វើការឃាត់ខ្លួនស្ត្រីជនជាតិខ្មែរម្នាក់ ឈ្មោះ គីម ហាង (Kim Hang) អាយុ២៤ឆ្នាំ តាមដីការបស់តុលា ខេត្តភូកេត ក្នុងបទចោទប្រកាន់ករណី "ជួញដូរមនុស្ស " និងឃាត់ឃាំងរាំង " ដោយមានបក្សពួកចំនួន០៤នាក់ ធ្វើការឆបោកនាំកុមារកម្ពុជា អាយុចាប់ពី១៣-១៦ឆ្នាំ យកមកអោយដើរលក់ផ្កា និងលក់វ៉ែនតា នៅតាមបរិវេណឆ្នេរសមុទ្រ នៃតំបន់ទេសចរណ៍ប៉ាតង ដោយមានស្ត្រី ឈ្មោះ គីម ហាង ជាអ្នកដឹកនាំកុមារទាំងនោះមកកន្លែងលក់ ចាប់ពីម៉ោង០៨ព្រឹក ដល់ម៉ោង០៩យប់ ព្រមទាំងនៅចាំឃ្លាំមើលផ្លូវជារៀងរាល់ថ្ងៃ ។

លុះដល់វេលាម៉ោង០៩យប់ ស្ត្រីឈ្មោះ គីម ហាង បាននាំកុមារទាំងនោះទៅឃុំឃាំងនៅបន្ទប់ជួលមួយកន្លែងម្តុំផ្លូវរាជអូធីត នៃសង្កាត់ប៉ាតង ស្រុកក្រាធូ ខេត្តភូកេត បន្ទាប់មកស្ត្រីខាងលើបានធ្វើការរាប់ប្រាក់ចំណូល ដែលកុមារទាំងនោះលក់បានចាប់២០០០បាត ទៅ៣០០០បាត ដោយពេលខ្លះនាងបានយកទំពួកហាលខោអាវ វាយដំលើកុមារទាំងអស់នោះផងដែរ ។ ចំពោះការឃាត់ខ្លួនជនសង្ស័យខាងលើ និងបក្សពួកលើកនេះ ដោយសារតែមានម្តាយកុមាររងគ្រោះទាំង០២នាក់ បានមកដាក់ពាក្យបណ្តឹងនៅអធិការដ្ឋានតម្រួតប៉ុស្តិ៍បាតង កាលពីខែមករា ឆ្នាំ២០១៨ កន្លងទៅដោយបក្សពួករបស់នាង គីម ហាង បានរត់គេចខ្លួនទៅក្រៅប្រទេស ប៉ុន្តែនាង គីម ហាង កំពុងលាក់ខ្លួនក្នុងប្រទេសថៃ ទើបសមត្ថកិច្ចថៃស្នើរសុំដីកាតុលា ខេត្តភូកេត ដើម្បីឃាត់ខ្លួនជនសង្ស័យយកមកផ្តន្ទាទោសតាមផ្លូវច្បាប់ ។

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 25-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ នាវេលាម៉ោង ១៧និង២០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## សហរដ្ឋអាមេរិក នឹងព្យួរការអនុគ្រោះពាណិជ្ជកម្មពិសេស សម្រាប់ឧស្សាហកម្មគ្រឿងសមុទ្រថៃ

http://www.freshnewsasia.com/ 2019-10-27

**(វ៉ាស៊ីនតោន)៖** ប្រធានាធិបតីអាមេរិក លោក ដូណាល់ ត្រាំ នឹងផ្អាកការអនុគ្រោះពាណិជ្ជកម្មពិសេសសម្រាប់ឧស្សាហកម្មគ្រឿងសមុទ្រថៃ ដោយសារតែបរាជ័យក្នុងការកែលម្អសិទ្ធិរបស់កម្មករ។ នេះបើតាមការចេញផ្សាយដោយសារព័ត៌មាន Bloomberg នៅថ្ងៃអាទិត្យ ទី២៧ ខែតុលា ឆ្នាំ២០១៩។ ថៃគឺជាប្រទេសធំទី៣នៅលើពិភពលោកខាងនាំចេញគ្រឿងសមុទ្រ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយ ឧស្សាហកម្មមួយនេះ មានកេរ្តិ៍ឈ្មោះមិនល្អ និងរងផលប៉ះពាល់យ៉ាងខ្លាំងពីការដាក់ទណ្ឌកម្មមួយចំនួនពីសំណាក់បណ្តាប្រទេស ខាងលោកលិច ដោយសារតែមានការចោទប្រកាន់ពីការរំលោភបំពានសិទ្ធិកម្មករនេសាទ ការជួញដូរមនុស្ស ឬក៏ប្រើ មនុស្សដូចជាទាសករជាដើម។

ជុំវិញបញ្ហានេះដែរ បើតាមការិយាល័យតំណាងពាណិជ្ជកម្មអាមេរិក តាមរយៈការស្រង់សម្តីដោយសារព័ត៌មាន Bloomberg រដ្ឋបាល លោក ដូណាល់ ត្រាំ នឹងផ្អាកការអនុគ្រោះពាណិជ្ជកម្មពិសេសសម្រាប់ឧស្សាហកម្មគ្រឿង សមុទ្រថៃ។ ការិយាល័យដដែល បានបញ្ជាក់ដូច្នេះថា៖ **«រាល់ផលិតផលគ្រឿងសមុទ្រថៃ នឹងបាត់បង់ការអនុគ្រោះ ពាណិជ្ជកម្មពិសេស ដោយសារតែមិនអាចដោះស្រាយបញ្ហាសិទ្ធកម្មករ នៅក្នុងឧស្សាហកម្មគ្រឿងសមទ្រ និងការដឹកជញ្ជូន»**។

គួរបញ្ជាក់ថា បើតាម Bloomberg ការព្យួរ ឬផ្អាកការអនុគ្រោះពាណិជ្ជកម្មពិសេសខាងលើមានតម្លៃជាង ១.៣ពាន់លានដុល្លារ ហើយវានឹងត្រូវចូលជាធរមាននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០៕

## ជនជាតិវៀតណាម២០នាក់អាចស្ថិតក្នុងចំណោមសព៣៩នាក់ក្នុងកុងតឺន័រ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៩ ម៉ោង ១៦:២៨ ខាន់ សុខឃន

ប្រទេសអង់គ្លេស ៖ ជនជាតិវៀតណាមប្រមាណជា២០នាក់អាចស្ថិតក្នុងចំណោមសាកសពមនុស្ស៣៩នាក់ដែលរកឃើញនៅអង់គ្លេសកាលពីថ្ងៃទី២៣តុលាកន្លងមកនេះ ក្នុងកុងតឺន័រក្លេសនៃរថយន្តកាមីញ៉ុងមួយគ្រឿង ក្នុងតំបន់ឧស្សាហកម្មមួយ នាភាគខាងកើត ទីក្រុងឡុងដ៍។ ក្នុងគ្រាដំបូងប៉ូលិសអង់គ្លេសប្រកាសថាក្នុងចំណោមសាកសពទាំង៣៩នាក់នោះមានបុរស៣១នាក់និងនារី៨នាក់សុទ្ធតែជាជនជាតិចិន តែការសង្ស័យកើតមានហើយអ្នកនាំពាក្យម្នាក់ របស់ប៉ូលិសគូសបញ្ជាក់នាថ្ងៃទី២៥តុលាថា ដំណើរការនៃការកំណត់អត្តសញ្ញាណនៅមិនទាន់បញ្ចប់នៅឡើយ។ ទោះបីយ៉ាងណាគ្រួសារជាច្រើនដែលរស់នៅភាគកណ្តាលវៀតណាម បានសម្តែងពីការបារម្ភដែលកូនចៅពួកគេ បានស្លាប់ក្នុងកុងតឺន័រនៃរថយន្តកាមីញ៉ុង ដោយពួកគេកាន់លិខិតឆ្លងដែនចិនក្លែងក្លាយ។ នារីវៀតណាមម្នាក់ឈ្មោះPHAM THI TRAអាយុ២៦ឆ្នាំបានបញ្ជូនសារមួយតាម ទូរស័ព្ទមកម្តាយនាង ដោយថានាងមិនអាចដកដង្ហើមរួច ហើយនាងកំពុងរកកលដាច់ខ្យល់ស្លាប់ហើយ។ ចំណែកបុរសម្នាក់ឈ្មោះBUI VAN DIEP សម្តែងការសង្ស័យថា ប្អូនស្រីរបស់គេឈ្មោះ NHUNG សង្ស័យស្ថិតក្នុងកុងតឺន័រនោះដែរ។ នាងបានចាកចេញពីស្រុកក្នុងខេត្តង៉េអាន២ខែមកហើយ រួចចាប់តាំងពីពេលនោះមកបាត់ដំណឹងសូន្យឈឹង។

មានជនជាតិវៀតណាមច្រើននាក់បានធ្វើដំណើរផ្សងព្រេងចង់ទៅកាន់អឺរ៉ុប ដោយភាគច្រើនកាត់តាមរុស្ស៊ី ឬចិនជាមួយការកាន់លិខិតឆ្លងដែនក្លែងក្លាយ។ ដំណើរប្រកបដោយគ្រោះថ្នាក់នោះពួកគេអាចចំណាយប្រាក់រហូតដល់ ៣៦.០០០អឺរ៉ូ។ ជារឿយៗពួកគេទៅកាន់អង់គ្លេសដើម្បីធ្វើការនៅតាមបារ ឬតាមបណ្តាកសិដ្ឋានដាំកញ្ឆាខុសច្បាប់ ក្នុងក្តីសង្ឃឹមទទួលបានប្រាក់ច្រើនផ្ញើមកផ្ទះ។

## អាជ្ញាធរបារាំងរកឃើញជនភៀសខ្លួនលាក់ក្នុងទូរក្លាសេ ដែលគ្រោងដឹកពីបារាំងចូលទៅអង់គ្លេស!

http://freshnewsasia.com/ 2019-10-28

**(ប៉ារីស)៖** ទើបតែមានករណីរកឃើញសាកសពមនុស្ស ៣៩នាក់ នៅក្នុងទូរក្លាសេលើរថយន្តមួយគ្រឿងនៅតំបន់ អ៊ែសសិក (Essex) របស់ចក្រភពអង់គ្លេស ឥឡូវនេះបែរជាមានព័ត៌មានថ្មីមួយទៀតថា ជនអន្តោប្រវេសន៍ចំនួន ០៨នាក់មកពីអាហ្វហ្គានីស្ថាន ត្រូវបានអាជ្ញាធរបារាំងប្រទះឃើញលាក់ ខ្លួនក្នុងរថយន្តដឹកទំនិញមួយគ្រឿង ដែលមានគោលដៅឆ្ពោះទៅកាន់អង់គ្លេស។ នេះបើតាមការដកស្រង់ការផ្សាយចេញពីសារព័ត៌មាន Sputnik នៅព្រឹកថ្ងៃចន្ទ ទី២៨ ខែតុលា ឆ្នាំ២០១៩។

យោងតាមប្រកពពីអាជ្ញាធរបារាំងជនអន្តោប្រវេសន៍ខាងលើ ដែលរួមមានទាំងកុមារចំនួន ០៤នាក់ផងដែរ ត្រូវបានគេរកឃើញកំឡុងការត្រួតពិនិត្យមួយនៅទីក្រុង កាឡេស (Calais) ប្រទេសបារាំង កាលពីថ្ងៃអាទិត្យ (ពេលវេលាក្នុងតំបន់របស់បារាំង) ពេលត្រៀមឆ្លងទៅកាន់ចក្រភពអង់គ្លេស។ ក្រោយការរកឃើញ ក្រុមជនភៀសខ្លួនទាំងនោះត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ដោយសារតែសីតុណ្ហភាពនៅក្នុងទូរក្លាសេទំនិញ ដែលពួកគេលាក់ខ្លួនគឺត្រឹម ០៧អង្សាសេប៉ុណ្ណោះ។ រីឯអ្នកបើករថយន្តចំនួន ០២នាក់ ដែលជាជនជាតិរ៉ូម៉ានីទាំងពីរត្រូវបានឃាត់ខ្លួន។

គួរជម្រាបថា ព័ត៌មាននេះបានកើតមានឡើង បន្ទាប់ពីសាកសពមនុស្ស៣៩នាក់ ត្រូវបានរកឃើញនៅក្នុងទូរថយន្តដឹកកុងតឺន័រ ដែលមានសីតុណ្ហភាពត្រជាក់ដូចគ្នា នៅក្បែរទីក្រុងឡុងដ៍របស់ចក្រភពអង់គ្លេស កាលពីសប្តាហ៍មុន។ ករណីនោះអាចជាករណី ការរត់ពន្ធជនអន្តោប្រវេស៍ដូចគ្នា ខណៈប៉ូលិសអង់គ្លេសកំពុងបន្តការស៊ើបអង្កេត ក៏ដូចជាកំណត់សញ្ជាតិជនរងគ្រោះដែលគេសង្ស័យថា អាចជាជនជាតិវៀតណាមភាគច្រើន៕

## ហេតុអ្វីជនជាតិវៀតណាម ចំណាយលុយរាប់ម៉ឺនដុល្លារ និងផ្សងព្រេងដ៏គ្រោះថ្នាក់មកទឹកដីអង់គ្លេស?

http://www.cen.com.kh/archives/ October 28, 2019

មានការព្រួយបារម្ភថា មានជនជាតិវៀតណាមមួយចំនួនគឺស្ថិតនៅក្នុងសាកសពចំនួន ៣៩នាក់ដែលត្រូវគេរកឃើញនៅក្នុងទូកុងតឺណឺនៅតំបន់ Essex ប្រទេសអង់គ្លេសកាលពីថ្ងៃពុធ កន្លងទៅនេះ។ មូលនិធិសប្បុរសប្រឆាំងនឹងការជួញដូរមនុស្ស បាននិយាយថា មនុស្សមួយចំនួនដែលធ្វើអន្តោប្រវេសន៍ពីវៀតណាម ទៅកាន់ប្រទេសអង់គ្លេសគឺដើម្បីរកលុយ ផ្ញើត្រឡប់ទៅកាន់គ្រួសាររបស់ពួកគេវិញ។ ប៉ុន្តែ តើហេតុអ្វីបានជាប្រជាជនវៀតណាមផ្សងព្រេងដ៏គ្រោះថ្នាក់ដើម្បីធ្វើដំណើរទៅកាន់ទឹកដីបរទេស? តើពួកគេធ្វើដំណើរទៅក្រៅប្រទេសដោយវិធីណា?

### ហេតុអ្វីពួកគេចាកចេញពីប្រទេសវៀតណាម?

“វៀតណាមគឺជាប្រទេសដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់ខ្លាំង ប៉ុន្តែមិនមែនមានមនុស្សគ្រប់គ្នាទទួលផលបានពីការរីកចម្រើននោះទេ”។ នេះបើតាមការបញ្ជាក់របស់ប្រធានសេវាកម្ម BBC នៅវៀតណាម។ លោកថា “វៀតណាមមានកម្លាំងពលកម្មសេសសល់ដ៏ច្រើន”។ អ្នកជំនាញប្រឆាំងការជួញដូរមនុស្សនៅក្នុងប្រទេសវៀតណាមឈ្មោះ Mimi Vu បាននិយាយថា “ជនអន្តោប្រវេសន៍វៀតណាម ដែលភាគច្រើនបានធ្វើដំណើរទៅកាន់អង់គ្លេស និងអឺរ៉ុបគឺមកពីខេត្តមួយចំនួនប៉ុណ្ណោះក្នុងប្រទេសវៀតណាម”។ “នៅក្នុងតំបន់មួយចំនួននោះ មានប្រពៃណីកាលពីប៉ុន្មានទសវត្សមុនអំពីជនអន្តោប្រវេសន៍នៅក្រៅប្រទេស ខុសច្បាប់ ឬត្រឹមត្រូវតាមច្បាប់ ដែលពួកគេត្រូវស្វែងរកការងារ និងដើម្បីផ្ញើលុយត្រឡប់មកផ្ទះវិញ”។ ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ជនអន្តោប្រវេសន៍វៀតណាម ទៅកាន់ទឹកដីអង់គ្លេសគឺមានដើមកំណើតមកពីទីក្រុង Hai Phong និងខេត្ត Quang Ninh ប៉ុន្តែបច្ចុប្បន្ននេះ មានការកើតឡើងយ៉ាងខ្លាំងពីចំនួនជនអន្តោប្រវេសន៍មកពីខេត្តចំនួន ៣គឺខេត្ត Nghe An ខេត្ត Quang Binh និងខេត្ត Ha Tinh ដែលខេត្តមានប្រជាជនក្រីក្រជាងគេ។

**ហេតុអ្វីបានជាពួកគេចង់ទៅអង់គ្លេស?**

សម្រាប់ជនអន្តោប្រវេសន៍វៀតណាម ទឹកដីអង់គ្លេសប្រហែលជាកន្លែងដ៏មានប្រជាប្រិយខ្លាំងនៅក្នុងតំបន់អឺរ៉ុប។ នេះបើតាមការបញ្ជាក់របស់លោកសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រសង្គម នៅសកលវិទ្យាល័យ Oxford-Brookes ដែលមានជំនាញខាងអន្តោប្រវេសន៍។ អ្នកស្រីសាស្ត្រាចារ្យថ្លែងថា ពួកគេដឹងច្បាស់ណាស់ថា ប្រសិនជាពួកគេបានមកអង់គ្លេស ពួកគេទំនងជានឹងមានការងារធ្វើ និងរកបានលុយច្រើនសម្រាប់ផ្ញើត្រឡប់ទៅកាន់គ្រួសាររបស់ពួកគេវិញ។ វាក៏មានបណ្តាញប្រជាជនវៀតណាមផងដែរ ដែលនៅអង់គ្លេសស្រាប់ ហើយអ្នកទាំងនោះអាចជួយជនជាតិវៀតណាមដែលមកនៅថ្មី ដូចជាជួយជាជួយផ្តល់កន្លែងស្នាក់នៅ និងការងារ។ នៅពេលពួកគេមកដល់អង់គ្លេស វាមានតម្រូវការពលកម្មច្រើនណាស់សម្រាប់អ្នកមិនមានជំនាញ ដូចជានៅភោជនីយដ្ឋានវៀតណាម កន្លែងធ្វើក្រចក និងឧស្សាហកម្មកញ្ឆាខុសច្បាប់ជាដើម។ បើតាមការសម្ភាសន៍ជាមួយនឹងជនជាតិវៀតណាមមួយចំនួនដែលត្រឡប់មកពីអង់គ្លេសវិញ បានឲ្យដឹងថា ការងារភាគច្រើនដែលពួកគេធ្វើគឺនៅក្នុងវិស័យកសិកម្ម និងនេសាទ ប៉ុន្តែក៏មានធ្វើការងារតាមរដូវកាល ឬការងារធម្មតាដែរ ឬក៏បង្កើតមុខរបបតូចៗខ្លួនឯង។ អ្នកមួយចំនួន ក៏អត់ការងារធ្វើដែរ។

**តើពួកគេត្រូវចំណាយប៉ុន្មានសម្រាប់ការធ្វើដំណើរ?**

អ្នកជំនាញប្រឆាំងការជួញដូរមនុស្សនៅវៀតណាម បាននិយាយថា ជនអន្តោប្រវេសន៍អាចចំណាយជាច្រើន។ សម្រាប់អ្នកដែលមានលុយតិច ចន្លោះពី ១០.០០០ ទៅ ១៥.០០០ដុល្លារ ហើយការធ្វើដំណើររបស់ពួកគេគឺពិបាកខ្លាំង និងអាចរួមមានការធ្វើដំណើរឆ្លងកាត់ព្រៃនៅពេលយប់ផងដែរ។ ប៉ុន្តែសម្រាប់អ្នកដែលមានលទ្ធភាពចំណាយចន្លោះ ៤០.០០០ ទៅ ៥០.០០០ដុល្លារ នឹងធ្វើដំណើរភាគច្រើនតាមយន្តហោះ។ សម្រាប់ជនជាតិវៀតណាមមួយចំនួនរស់នៅក្នុងតំបន់ជនបទ ប្រាក់ចំនួន ៣០.០០០ដុល្លា ពួកគេធ្វើការងារនៅវៀតណាមប្រហែល ៣០ឆ្នាំទើបបាន។ បើតាមអង្គការសហប្រជាជាតិ ជនអន្តោប្រវេសន៍វៀតណាម ផ្តល់ចំណូលដល់ជនជួញដូរមនុស្សប្រមាណ ៣០០លានដុល្លារក្នុងមួយឆ្នាំ សម្រាប់ឲ្យមានការជួយយកពួកគេទៅកាន់ទឹកដីអឺរ៉ុប។ អ្នកខ្លះមិនមានលុយសម្រាប់លើការចំណាយនោះទេ ហើយអ្នកមួយចំនួនបានខ្ចីពីគ្រួសារ និងអ្នករាប់អានគ្នាស្និទ្ធ។

**តើពួកគេទៅដល់អង់គ្លេសដោយរបៀបណា?**

ភ្នាក់ងារជួញដូរបានផ្តល់សេវាកម្មចំនួន ២ដើម្បីបញ្ជូនជនអន្តោប្រវេសន៍ទៅកាន់អង់គ្លេសគឺសេវាកម្មល្អ និងសេវាកម្មសន្សំសំចៃ។ នេះបើតាមការស្រាវជ្រាវរបស់គណៈកម្មាការឯករាជ្យប្រឆាំងនឹងទាសភាព។ សម្រាប់សេវកម្មល្អ (Premium) មានការប្រថុយប្រថានតិចតួចសម្រាប់ជនអន្តោប្រវេសន៍ ដែលពួកគេអាចធ្វើដំណើរតាមយន្តហោះ និងមានការឲ្យស្នាក់នៅក្នុងផ្ទះដោយសុវត្ថិភាពមុនពេលធ្វើដំណើរទៅកាន់អង់គ្លេស។ ចំណែកសេវាកម្មទាប (Economy) អាចត្រូវចំណាយពេលរាប់ខែដើម្បីបញ្ជូនជនទាំងនោះឲ្យទៅដល់អង់គ្លេស ប៉ុន្តែទោះបីជាអ្នកជ្រើសរើសយកសេវាកម្មណាក៏ដោយ ចុងក្រោយជនទាំងនោះនឹងត្រូវទៅកន្លែងព្រំដែនដូចគ្នា ជិះនៅលើរថយន្ត ឬកប៉ាល់ដើម្បីឆ្លងចូលទៅទីគោលដៅ៕ អត្ថបទប្រែសម្រួលដោយ៖ សុភ័ក្រ ប្រភព៖ BBC

## ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៩

### រដ្ឋមន្ត្រីមហាផ្ទៃ៖ពលករដើរតួនាទីយ៉ាងសំខាន់ សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

https://dap-news.com/national/ Posted on October 30, 2019

ភ្នំពេញ ៖ នៅចំពោះមុខថ្នាក់ដឹកនាំ ប្រទេសទាំង៣ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថ្លែងថា ពលករទៅធ្វើការងារនៅក្រៅប្រទេស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូល។

ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំង៣ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា ស្តីពី តួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តប្រវេសន៍ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ សម្តេច ស ខេង មានប្រសាសន៍ថា ការធ្វើទេសន្តប្រវេសន៍ គឺជាសិទ្ធិរបស់ពលរដ្ឋ ក្នុងការជ្រើសរើសការងារធ្វើ។ សម្តេចបន្តថា "ពលករមានតួនាទីនៃការអភិវឌ្ឍសេដ្ឋកិច្ច ហើយការបង្កើនប្រសិទ្ធិភាពនៃការអភិវឌ្ឍ និងនៃការទេសន្តប្រវេសន៍ការងារ ត្រូវបានកំណត់យ៉ាងច្បាស់ថា អាទិភាពមួយរបស់រដ្ឋជាសមាជិកអាស៊ាន ទើបមានកិច្ចព្រមព្រៀង ។ អាស៊ានមានកិច្ចព្រមព្រៀង ក្នុងការលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍ ក៏ត្រូវបានអនុម័ត ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៧ ដោយរដ្ឋសមាជិកអាស៊ាន" ។

យោងតាមរបាយការណ៍ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីឆ្នាំ២០១៨ ចំនួនពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេសបានកើនដល់ជាង១លាន ២សែននាក់ និងបានផ្ញើប្រាក់ត្រឡប់មកស្រុកកំណើតវិញក្នុង ១ម្នាក់ៗជាង ២ពាន់លានដុល្លារ ។ ក្នុងនោះពលករធ្វើការនៅថៃ និងកូរ៉េខាងត្បូង ផ្ញើប្រាក់មកស្រុកកំណើតបានច្រើនជាងគេ ៕ ដោយ អេង ប៊ូធេង

## កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បើកកិច្ចប្រជុំពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍ នៅខេត្តសៀមរាប

http://www.freshnewsasia.com/ 2019-10-30

**(សៀមរាប)៖** កិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំង៣ កម្ពុជា ឡាវ និងមីយ៉ាន់មា (CLM) ស្តីពី តួនាទីប្រទេសបញ្ជូនដើម្បីពង្រឹងកិច្ចការពារ ពលករទេសន្តរប្រវេសន៍ ក្រោមអធិបតីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្រុងសៀមរាប នៅព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩នេះ។

ពិធីនេះក៏មានវត្តមានរបស់ឧត្តមសេនីយ៍ឯក អោង ធូ (Aung Thu) អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងគណៈប្រតិភូសហភាពមីយ៉ាន់ម៉ា, លោកវរសេនីយ៍ឯកបណ្ឌិត ផេងសាវ៉ាញ់ ជីផាវង្សសៃ អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ និងគណៈប្រតិភូ នៃសាធារណរដ្ឋប្រជាមានិតឡាវ, លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈប្រតិភូនៃព្រះរាជាណាចក្រកម្ពុជា រួមនិងវត្តមានឯកអគ្គរដ្ឋទូត នៃសហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋប្រជាមានិតឡាវ ប្រចាំនៅកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ នាយឧត្តសេនីយ៍អគ្គស្នងការ អគ្គនាយក អគ្គនាយករង អភិបាល/អភិបាលរងខេត្ត និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិផងដែរ។

សម្តេចក្រឡាហោម បានថ្លែងអំណរគុណ ចំពោះការអញ្ជើញចូលរួមរបស់គណៈប្រតិភូទាំងបីប្រទេស គឺកម្ពុជា ឡាវ និងភូមា និងភ្ញៀវជាតិអន្តរជាតិទាំងអស់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ មន្ត្រីជាន់ខ្ពស់ ថ្នាក់បច្ចេកទេស ស្តីពី « តួនាទីប្រទេសបញ្ជូន ក្នុងការការពារពលករទេសន្តរប្រវេសន៍» ដែលកំពុងតែប្រារព្ធធ្វើឡើង នាទីក្រុងសៀមរាបអង្គរ ខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា។ សម្តេចក្រឡាហោម បានថ្លែងទៀតថា «ប្រទេសយើងទាំងបី ជាប្រទេសជិតខាងគ្នា មានវប្បធម៌ប្រហាក់ប្រហែលគ្នា មានព្រំដែនជាប់ជាមួយប្រទេសថៃដូចគ្នា ហើយប្រជាពលរដ្ឋយើង ក៏បាន និងកំពុងតែនាំគ្នាទៅធ្វើការក្នុងប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់យ៉ាងច្រើនកុះករ។ មួយចំនួនបាន និងកំពុងប្រឈមនឹងបញ្ហាជាច្រើន ក្នុងដំណើរការទេសន្តរប្រវេសន៍ តាំងពីចាកចេញ នៅកន្លែងធ្វើការរហូតដល់ពេលត្រឡប់មកវិញ»។ សម្តេចបានបន្តទៀតថា យើងទទួលស្គាល់ថា ការធ្វើទេសន្តរប្រវេសន៍ គឺជាសិទ្ធិពលរដ្ឋ ក្នុងការជ្រើស

ជើសការងារ មុខរបរ និងទីកន្លែងរស់នៅ តែយើងក៏ត្រូវគិតអំពីសិទ្ធិ ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូរក្នុងនាមជាមនុស្ស របស់ពលករ ការគ្រប់គ្រង និងកិច្ចការពារពលរដ្ឋរបស់យើង ក្នុងនាមជាប្រទេសដែលមានអធិបតេយ្យភាព និងទំនាក់ទំនងល្អរវាងប្រទេសជិតខាង និងរវាងប្រទេសបញ្ជូន និងប្រទេសទទួលផងដែរ។ ទាំងនេះ គឺជាតួនាទីរបស់ប្រទេសយើងទាំងបី ដែលជាប្រទេសបញ្ជូន ដែលចាំបាច់ត្រូវរួមសហការគ្នាក្នុងការដោះស្រាយបញ្ហារួម។

ហើយប្រទេសនីមួយៗ មានរបៀបគ្រប់គ្រង បទដ្ឋាន និងនីតិវិធីក្នុងការអនុវត្តដោយឡែកៗពីគ្នា ហើយក៏មានទាំងចំណុចល្អ ទាំងចំណុចខ្វះខាត។ ហេតុនេះ ការពិភាក្សា ដើម្បីរិះរកស្តង់ដាអនុវត្តមួយ ដែលសមស្របសម្រាប់ប្រទេសទាំង៣ គឺជាការចាំបាច់សម្រាប់ការលើកកម្ពស់សុវត្ថិភាព និងផលប្រយោជន៍ពលករ ក៏ដូចជា កាត់បន្ថយភាពរងគ្រោះក្នុងអំឡុងពេលនៃទេសន្តរប្រវេសន៍ និងផលប៉ះពាល់អវិជ្ជមានចំពោះពលករ គ្រួសារ និងសង្គមជាតិយើង។ ម្យ៉ាងទៀត ពលករមានតួនាទីនៃការអភិវឌ្ឍសេដ្ឋកិច្ច ហើយការបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ ត្រូវបានកំណត់យ៉ាងច្បាស់ថា ជាអាទិភាពមួយរបស់រដ្ឋជាសមាជិកអាស៊ាន ទើបមានកិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ត្រូវបានអនុម័ត ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ដោយរដ្ឋជាសមាជិកអាស៊ាន។ កិច្ចព្រមព្រៀងនេះ កំណត់យ៉ាងច្បាស់ពីកាតព្វកិច្ចរបស់រដ្ឋបញ្ជូនពលករ និងរដ្ឋទទួលពលករ (ក្នុងជំពូកទី ៥ និងជំពូកទី ៦) ដោយរដ្ឋសមាជិក ត្រូវបំពេញកាតព្វកិច្ចគោរព និងការពារសិទ្ធិពលករទេសន្តរប្រវេសន៍។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ សហគមន៍សេដ្ឋកិច្ចអាស៊ានពុំបានបញ្ចូលខ្លឹមសារស្តីពីការផ្លាស់ទីពលករគ្មានជំនាញ ពលករដែលមានជំនាញទាប និងពលករដែលមានជំនាញមធ្យម ក្នុងការឆ្លងព្រំដែនរបស់ប្រទេសនីមួយៗនោះឡើយ។ ដើម្បីសម្រេចឱ្យបាននូវសមធម៌ បរិយាបន្ន និងស្ថិរភាពនៃកំណើនអាស៊ាន ចាំបាច់ត្រូវមានយន្តការ ដែលឆ្លើយតបចំពោះលំហូរទេសន្តរប្រវេសន៍ទាំងនេះ។ នេះក៏ជាហេតុផលចាំបាច់មួយ ដែលក្នុងតួនាទីជាប្រទេសបញ្ជូន ត្រូវពិភាក្សាគ្នា ដើម្បីរិះរកគំនិតផ្តួចផ្តើមសមស្រប សម្រាប់ដំណោះស្រាយទាំងនេះផងដែរ។

លើសពីនេះទៅទៀត «កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់» ដែលបានអនុម័តនៅប្រទេសម៉ារ៉ុក កាលពីខែធ្នូឆ្នាំ២០១៨ កន្លងទៅ ក៏ជាឧបករណ៍សំខាន់មួយ ដែលប្រទេសទាំងអស់ជាសមាជិក ចាំបាច់ត្រូវជម្រុញអនុវត្ត ដើម្បីការពារពលករទេសន្តរប្រវេសន៍ ពីរាល់ទម្រង់ នៃការជួញដូរ និងកេងប្រវ័ញ្ច នៅគ្រប់តំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍ផងដែរ។ សម្តេច ក៏បានគូសបញ្ជាក់ផងដែរថា មានកិច្ចការជាច្រើនដែលត្រូវធ្វើតាមប្រទេសរៀងៗខ្លួន តែក៏មានកិច្ចការខ្លះដែលទាមទារឲ្យមានកិច្ចសហការជាមួយគ្នា ដើម្បីផ្លាស់ប្តូរយោបល់ បទពិសោធន៍ សម្រាប់ការដោះស្រាយបញ្ហារួម និងមានចំណុចសេសសល់មួយចំនួនទៀត ដែលត្រូវលើកយកទៅពិភាក្សាជាមួយភាគីថៃ ដែលជាប្រទេសគោលដៅ ដើម្បីមានវិធានការរួមគ្នា រវាងប្រទេសបញ្ជូន និងប្រទេសទទួល ក្នុងកិច្ចការពារ សិទ្ធិមនុស្ស សិទ្ធិពលករ និងការបែងចែកផលប្រយោជន៍រវាងពលករ និងនិយោជិក និងការចែករំលែកការទទួលខុសត្រូវរវាងប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីលើកកម្ពស់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (Safe, Orderly and Regular Migration)។

ហើយកិច្ចពិភាក្សាពិគ្រោះយោបល់កម្រិតបច្ចេកទេសថ្នាក់មន្ត្រីជាន់ខ្ពស់ «ស្តីពីតួនាទីប្រទេសបញ្ជូន ក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍» នេះ គឺជាការផ្តួចផ្តើមដ៏មានសារសំខាន់ ហើយក៏ជាការបំពេញករណីយកិច្ច របស់យើងដែលជាប្រទេសសមាជិកក្នុងតំបន់ និងក្នុងពិភពលោក ក្នុងការពង្រឹងកិច្ចសហការស្វែងរកគន្លឹះដោះស្រាយរួមគ្នារវាងប្រទេសដែលមានស្ថានភាព ប្រហាក់ប្រហែលគ្នា ហើយក៏ជាការបង្ហាញអំពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្ត ក្នុងកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ពលករពីភាពរងគ្រោះ និងជនរងគ្រោះ គ្រប់ភេទ គ្រប់វ័យ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ជាពិសេស ពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដែលនឹងផ្តល់ផលប្រយោជន៍ប្រកបដោយសមធម៌សម្រាប់ភាគីទាំងសងខាង គឺនិយោជក និងនិយោជិត និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស សម្តេច មានសង្ឃឹមថា កិច្ចពិភាក្សានេះ នឹងទទួលបានលទ្ធផលជាផ្លែផ្កា ដែលប្រតិភូនីមួយៗ នឹងអាចនាំយកលទ្ធផលនៃកិច្ចពិភាក្សា ទៅដាក់ជូនថ្នាក់ដឹកនាំរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្ត ក្នុងការធ្វើឲ្យក្លាយជាសកម្មភាពជាក់ស្តែង ក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ និងកិច្ចការពារប្រជាពលរដ្ឋពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព និងឈានទៅការជួបគ្នារវាងថ្នាក់ដឹកនាំប្រទេសទាំងបី ដើម្បីសម្រេចលើសេចក្តីថ្លែងការណ៍រួម ដំណោះស្រាយរួម នៅពេលអនាគតដ៏ខ្លីខាងមុខ និងអាចដាក់ស្នើការពិភាក្សា ជាមួយភាគីថៃ ដើម្បីរួមសហការគ្នា ដោះស្រាយបញ្ហាពលករឲ្យបានរលូន និងមានប្រសិទ្ធភាព៕

## សមត្ថកិច្ចឆ្មក់បង្ក្រាបទីតាំងម៉ាស្សា២កន្លែងជាប់គ្នា បង្កប់សេវាបម្រើផ្លូវភេទ ឃាត់ខ្លួនថៅកែហាង២នាក់

http://nokorwatnews.com/ 29-10-2019

ភ្នំពេញ៖ កម្លាំងសមត្ថកិច្ចនាយកដ្ឋានការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ សហការជាមួយកម្លាំងសមត្ថកិច្ចនគរបាលខណ្ឌមានជ័យ បានឆ្មក់បង្ក្រាបទីតាំងម៉ាស្សាកោសជប់យីហោ «ម៉ាស្សា & កោសជប់ 72 និង ម៉ាស្សាកោសជប់៩៩៩ »ចំនួន២ទីតាំងជាប់គ្នា ដែលលួចបង្កប់សេវាបម្រើសេវាផ្លូវភេទ ដោយឃាត់ខ្លួនថៅកែស្រីជាជនជាតិវៀមណាម ២នាក់ និងជួយរំដោះក្មេងស្រីរងគ្រោះ៥នាក់ ។

ក្នុងប្រតិបត្តិការណ៍នេះ ធ្វើឡើងកាលពីវេលាម៉ោង ៤ និង ២០ នាទី រសៀល ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ស្ថិតនៅចំណុចផ្ទះលេខ៥៨២ តាមបណ្តោយផ្លូវជាតិលេខ២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ដោយមានការសម្រប សម្រួលពីលោកស្រី ស៊ី វណ្ណនី ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយសមត្ថកិច្ចឃាត់ខ្លួនស្រ្តីថៅកែហាង ជាជនជាតិវៀតណាម២នាក់ រួមមាន ៖ ទី១ឈ្មោះ ចាន់ ធីរ៉េ ភេទស្រី អាយុ ៤៦ឆ្នាំ ជាតិវៀតណាម មុខរបរ ថៅកែហាង យីហោ « ៩៩៩» ស្នាក់នៅកន្លែងឃាត់ខ្លួន និងទីឈ្មោះ វៀង ធីហាយ ភេទស្រីអាយុ ៤៩ឆ្នាំ ជនជាតិវៀតណាម មុខរបរ ថៅកែហាងយីហោ«ម៉ាស្សា & កោសជប់ 72» ស្នាក់នៅកន្លែងឃាត់ខ្លួន ។ ចំពោះសម្ភារដកហូតរួមមាន ៖ ស្រោមអនាម័យប្រើរួច និង មិនទាន់ប្រើមួយចំនួនធំ និង សៀវភៅកត់ត្រាភ្ញៀវចេញចូលចំនួន២ ក្បាល ។

ក្រោយពីបញ្ចប់ប្រតិបត្តិការនេះ កម្លាំងនាយកដ្ឋានការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បាននាំខ្លួនស្រ្តីថៅកែហាង២ នាក់ និងក្មេងស្រីរងគ្រោះ៥នាក់ យកទៅកាន់ការិយាល័យនាយកដ្ឋានការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីសួរនាំបន្ថែម និងកសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញចាត់ការបន្តតាមច្បាប់ ៕ ភារ៉ា ដង្កោ

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ ឃុំ-សង្កាត់/ក្រុង-ស្រុក

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 29-10-2019

ខេត្តសៀមរាប៖ នៅព្រឹកថ្ងៃចន្ទ ទី២៨ ខែតុលា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប សហការជាមួយរដ្ឋបាលក្រុងសៀមរាប និងមានការចូលរួមគាំទ្រពីរដ្ឋបាលសាលាខេត្តសៀមរាប អង្គការUN WOMEN និងអង្គការសេកម្មភាពដើម្បីកុមារ បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ

អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។

វគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំរដ្ឋបាលក្រុងសៀមរាប ដែលដឹកនាំដោយលោកស្រីឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងជាតំណាងលោកជំទាវ យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមពីលោកស្រី លឹម ផល្លីកា អភិបាលរងក្រុងសៀមរាប លោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត តំណាងអង្គការសកម្មភាពដើម្បីកុមារ ការិយាល័យជុំវិញក្រុង ចៅសង្កាត់ ស្មៀន អ.ក.ន.ក អធិការ កងរាជអាវុធហត្ថ ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍នាយកសាលា យុវជន និងអង្គការដៃគូ សរុប ៨១នាក់ ស្រី៣០នាក់។ វគ្គបណ្តុះបណ្តាលបានផ្តោតសំខាន់លើប្រធានបទចំនួន០៦ រួមមាន ៖

១. ការរំលឹកអំពីតួនាទីភារកិច្ច និងយន្តការគាំទ្រពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវ ភេទ

៣. យន្តការគ្រប់គ្រង និងការការពារពលករទេសន្តរប្រវេសន៍

៤.ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

៥.ហានិភ័យនិងយន្តការឆ្លើយតបនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត

៦. និងអំពើជួញដូរកម្លាំងពលកម្ម

## ពលករខ្មែររាប់ពាន់នាក់នៅតែបន្តវិលត្រឡប់ចូលស្រុកតាមច្រកដូង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៩ ម៉ោង ១៣:២៥ ឆោម ពិសម័យ

ខេត្តបាត់ដំបង ៖ យោងតាមប្រភពព័ត៌មានបានឱ្យដឹងថា រហូតមកដល់ថ្ងៃទី២៩ តុលា នេះ ពលករខ្មែរទាំងប្រុសទាំងស្រី ដែលធ្វើការងារនៅប្រទេសថៃនៅតែបន្តភ្លូកទឹកភ្លូកដីខុសប្រក្រតី សម្រុកចូលមកកាន់ប្រទេសកំណើតខ្លួនវិញ ដែលគេកត់សម្គាល់បានថា អាចមានចំនួនរហូតដល់ទៅរាប់ពាន់នាក់ឯណោះ តាមច្រកទ្វារអន្តរជាតិ «ដូង» នៅក្នុងស្រុកកំរៀង ខណៈមន្ត្រីអន្តោប្រវេសន៍នៃច្រកនេះ រួមទាំងកម្លាំងប្រដាប់អាវុធគ្រប់ស្ថាប័នប្រដាប់ ដោយកាំភ្លើងគ្រប់ដៃផង បាននិងកំពុងដាក់ពង្រាយពាសពេញខាងមុខច្រកទ្វារចេញ-ចូល ថែមទាំងបានរារាំងមិនអនុញ្ញាតមានការថតរូបភាពអំពីដំណើរវិលចូលស្រុករបស់ពលករខ្មែរទាំងហ្វូងនោះទៀតផង។

បើតាមការពិនិត្យជាក់ស្តែង ពលករខ្មែរបានវិលត្រឡប់ពីប្រទេសថៃ ចូលមកកាន់ប្រទេសខ្លួនវិញ ចាប់តែងពីថ្ងៃទី២៧ តុលា បើគិតត្រឹមថ្ងៃទី២៩ តុលា នេះ អាចមានចំនួនរាប់ពាន់នាក់ហើយ ។ អ្នកសារព័ត៌មានមួយចំនួនកំពុងរង់ចាំតាមដាន និងផ្តិតយករូបភាពអំពីទិដ្ឋភាព នៃពលករទាំងហ្វូងនោះ នៅខាងមុខច្រកទ្វារអន្តរជាតិដូង។ ប៉ុន្តែមិនត្រូវបានមន្ត្រី និងកម្លាំងប្រដាប់អាវុធដែលដាក់ពង្រាយការពារនៅទីនោះអនុញ្ញាតឱ្យនៅក្បែរឬថតរូបឡើយ។

បើតាមអ្នករត់ម៉ូតូឌុបនៅមាត់ច្រកទ្វារអន្តរជាតិដូងនេះម្នាក់ ក៏បានផ្តល់ព័ត៌មានមកដែរថា ចាប់តាំងពីព្រឹកព្រលឹម នាថ្ងៃទី២៩ តុលា នេះ គេឃើញពលកររាប់រយនាក់បាននាំគ្នាមកដល់ខាងមុខច្រកទ្វារព្រំដែន ខាងទឹកថៃយ៉ាងត្រៀបត្រាណែនតាន់តាប់ទៅហើយ ។ ពួកគេបានឈរកកកុញនៅលើស្ពានតម្រង់ដួរចូលទឹកដីខ្មែរ តែត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីការពារព្រំដែនខ្មែរ។

លោកផាត សុផាន់ណា ប្រធានអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិ«ដូង» មិនអាចទំនាក់ទំនងសុំការបំភ្លឺបានទេ នៅព្រឹកថ្ងៃទី២៩ តុលា ពាក់ព័ន្ធនឹងចំនួនពលករខ្មែរវិលត្រឡប់ចូលប្រទេសកំណើត ដោយខុសប្រក្រតីនេះ ដោយទូរស័ព្ទរបស់លោកគ្មានអ្នកទទួល ។ ប៉ុន្តែបើតាមមន្ត្រីព្រំដែនម្នាក់ដែលសុំមិនប្រាប់ឈ្មោះ បានប្រាប់កោះសន្តិភាពតាមទូរស័ព្ទដែរថា គ្រប់មន្ត្រីការពារដែន ជាពិសេសមន្ត្រីដែលកំពុងគ្រប់គ្រងច្រកទ្វារព្រំដែននានា មិនត្រូវបានគេអនុញ្ញាតឱ្យផ្តល់ព័ត៌មាន អំពីក្រុមពលករវិលចូលស្រុកនាពេលនេះឡើយ ។ មន្ត្រីរូបនេះបានបង្ហើបឲ្យដឹងដូច្នេះថា «ខ្ញុំមិនអាចវាយតំលៃអំពីចំនួនពលករខ្មែរដែលកំពុងសម្រុកចូលស្រុកខ្មែរនាប៉ុន្មានថ្ងៃនេះយ៉ាងភ្លូកទឹកភ្លូកដី តាមច្រកទ្វារអន្តរជាតិដូង ខាងលើនេះបានទេ។ ប៉ុន្តែបើតាមការពិនិត្យជាក់ស្តែង ខ្ញុំអាចកត់សម្គាល់បានថា គិតត្រឹមថ្ងៃទី២៩ តុលានេះប្រហែលអាចមានចំនួនខ្ទង់ពាន់នាក់ហើយ» ។

ជុំវិញការវិលត្រឡប់ចូលស្រុកដ៏ចម្លែករបស់ពលករខ្មែរនៅប្រទេសថៃខាងលើនេះ ពួកគេត្រូវបានចោទសួរនាំយ៉ាងជាក់លាក់ពីមន្ត្រីអន្តោប្រវេសន៍អំពីមូលហេតុនៃការវិលត្រឡប់ចូលស្រុកនេះ ។ ប៉ុន្តែរាល់ចម្លើយរបស់ក្រុមពលករហាក់ដូចៗគ្នាដោយខ្លះថា «មកលេងផ្ទះ ឬមកលេងបុណ្យអុំទូក»។ ប៉ុន្តែយ៉ាងណា ពលករទាំងនោះ បានឆ្លងចូលមកកាន់ទឹកដីកំណើតជាបន្តបន្ទាប់ ក្រោយពីមន្ត្រីបញ្ចប់ការសាកសួរ និងវាយប៉ាស្ព័ររួចរាល់ ។

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI ថ្ងៃទី២៨-១០-២០១៩

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក អូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្ត ឧត្តរមានជ័យ ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 29-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៤នាក់ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤ នាក់នេះ មានស្រុកកណើតនៅខេត្តបាត់ដំបង ០២នាក់ ស្រី ០១នាក់ និងខេត្តព្រៃវែង ០២នាក់៕

## ក្រុមក្មេងស្ទាវថៃ និងបក្ខពួកជាង ១០ម៉ូតូ ចូលប្លន់ទ្រព្យសម្បត្តិ ពលករខ្មែរ នៅក្នុងខេត្តរ៉ាក់យ៉ង

http://nokorwatnews.com/ 29-10-2019

ខេត្តបន្ទាយមានជ័យ: យោងតាមរបាយការណ៍ពី កម្លាំងសមត្ថកិច្ចតម្រួត ស្រុកក្លែង ខេត្តរ៉ាក់យ៉ង ប្រទេសថៃ បានអោយដឹងថា កាលពីវេលាម៉ោង០៣និង៣០នាទីទៀបភ្លឺ ថ្ងៃច័ន្ទ ទី២៨ ខែតុលា ឆ្នាំ២០១៩ មានករណី ប្លន់មួយបានកើតឡើង នៅម្តុំមាត់ផ្លូវក្រាក់សែរប៊ុន-ខៅលុម ស្ថិតនៅក្នុងភូមិ៦ ឃុំក្រាក់សែប៊ុន ស្រុកក្លែង ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ។ តាមបតាមប្រភពព័ត៌មានបានអោយដឹងថា ជនរងគ្រោះដែលត្រូវក្រុមក្មេងស្ទាវថៃប្លន់នោះ មានឈ្មោះ ឆាត អាយុ ជាង ៣០ឆ្នាំ ជាពលករខ្មែរ ស្នាក់នៅក្នុងផ្ទះកើតហេតុ។

តាមការរៀបរាប់របស់ជនរងគ្រោះឈ្មោះ ឆាត ប្រាប់សមត្ថកិច្ចថា មុនពេលកើតហេតុខ្លួននិងក្រុមគ្រួសារ មានកូន,ប្រពន្ធ,ម្តាយក្មេកព្រមទាំងក្មួយ ចំនួន ០៥នាក់ កំពុងដេកលង់លក់ ក្នុងផ្ទះកើតហេតុស្រាប់តែភ្ញាក់ព្រើត បន្ទាប់ពីមានក្មេងស្ទាវមួយក្រុមជិះម៉ូតូចូលមក ៥-១០គ្រឿង រួចបាននាំគ្នាយកដុំថ្ម គប់ទ្វាផ្ទះគាត់ធ្វើអោយសំឡេងលឺលាន់រំពង ព្រមទាំងមានសំឡេងដូចផ្ទុះអាវុធ ជាច្រើនគ្រាប់ទៀត ដោយសារភាពភ័យខ្លាចជនរងគ្រោះបានដើរទៅទ្វាក្រោយ

រួចបើកភ្លើង ក្រុមក្មេងស្ទាវអ្នកទាំងនោះបាននាំគ្នាសម្រុកចូលមកគាត់នឹងក្រុមគ្រួសារបាននាំគ្នារត់គេចចេញតាមទ្វារក្រោយទៅពួននៅក្នុងចំការដូងព្រៃង ក្រោយផ្ទះកើតហេតុ ។ បន្ទាប់មកក្រុមក្មេងស្ទាវទាំងអស់នោះបាននាំគ្នារើរុសទ្រព្យសម្បត្តិក្នុងផ្ទះគាត់ក្នុងនោះមាន ប្រាក់ ចំនួន ៧០០បាត និងទូរស័ព្ទមួយគ្រឿង បន្ទាប់ពីនោះក្រុមក្មេងស្ទាវបាននាំគ្នាលើកម៉ូតូរបស់ជនរងគ្រោះអោយក្រឡាប់ជើង និងវាយបំផ្លាញរួចនាំគ្នារត់គេចខ្លួនបាត់។

ក្រោយហេតុការណ៍នេះស្ងប់ជនរងគ្រោះបានរត់ទៅសុំជំនួយពី ពលរដ្ឋថៃដែលផ្ទះជិតខាងអោយបណ្ដឹងសមត្ថកិច្ចតម្រួតចុះជួយអន្តរាគមន៍ ក្រោយពេលកើតហេតុ កម្លាំងសមត្ថកិច្ចតម្រួត បានចុះអន្តរាគមន៍ កន្លែងកើតហេតុ ព្រមទាំងសាកសួរភិនភាគជនបង្ក។ ជនរងគ្រោះបានបញ្ជាក់បន្ថែមផងដែរថា រូបគាត់ មិនធ្លាប់មានរឿងទំនាស់ជាមួយបុគ្គលណាមួយឡើយ ក្នុងហេតុការណ៍នេះ កម្លាំងសមត្ថកិច្ចតម្រួត ស្រុកក្លែង បានដាក់បញ្ជាឲ្យកម្លាំងជំនាញរួមទាំងកម្លាំងអាជ្ញាធរមូលដ្ឋាន ធ្វើការចុះស្រាវជ្រាវកាំមេរ៉ាសុវត្ថិភាព តាមដងផ្លូវ ក្នុងយប់កើតហេតុ ដើម្បីកំណត់មុខសញ្ញាតាមចាប់ខ្លួនក្រុមក្មេងស្ទាវដែលបង្ករឿងអស់ទាំងនោះយកមកផ្ដន្ទាទោសតាមផ្លូវច្បាប់។ បន្ទាប់ពីធ្វើការស្រាវជ្រាវកម្លាំងសមត្ថកិច្ចតម្រួត ស្រុកក្លែង ខេត្តរ៉ាក់យ៉ង បានឃាត់ខ្លួនក្រុមក្មេងស្ទាវ និងបក្សពួក ចំនួន ០៦នាក់ ដែលប្រព្រឹត្តបទល្មើសចូលប្លន់ផ្ទះពលករខ្មែរ កាលពីវេលាម៉ោង០៣ទៀបភ្លឺ នៅក្នុងស្រុកក្លែង ខេត្តរ៉ាក់យ៉ង ការឃាត់ជនសង្ស័យខាងលើបានធ្វើឡើងនៅរសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ នេះបច្ចុប្បន្នកម្លាំងសមត្ថកិច្ចថៃ កំពុងនាំជនសង្ស័យទាំង ០៦នាក់យកទៅធ្វើការសាកសួរបន្ថែមនៅអធិការដ្ឋាននគរបាលតម្រួតប៉ុស្តិ៍ ក្លែង ខេត្តរ៉ាក់យ៉ង៕ នីម វណ្ណា

## បុរសម្នាក់ជាពលករខ្មែរ ចងកសម្លាប់ខ្លួនសង្ស័យមានជំងឺសរសៃប្រសាទ

http://nokorwatnews.com/ 29-10-2019

ខេត្តបន្ទាយមានជ័យ: បុរសពលករខ្មែរ មានជំងឺខួរក្បាលចងកសម្លាប់ខ្លួនឯងកាលពីវេលាម៉ោងព្រឹកថ្ងៃអង្គារទី២៩ ខែតុលា ឆ្នាំ២០១៩ មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ ជា ចាន់ ភេទប្រុស អាយុ ៤៤ឆ្នាំ បានចងកសម្លាប់និងដើមឈើមួយកន្លែងនៅក្នុងតំបន់បានបឹងស្រុកសើរ៉ាឆា ខេត្តឈុនបុរី ប្រទេសថៃ។

យោងតាមប្រភពពីកូនប្រុសអ្នកស្លាប់ បានអោយដឹងថា ឪពុកគាត់ជាកម្មករសំណង់ធ្វើការនៅក្បែរកន្លែងកើតហេតុ ដោយមានជំងឺប្រចាំកាយគឺជំងឺផ្នែកខួក្បាល មុនពេលកើតហេតុ ឪពុកគាត់បាន រអ៊ូចង់វិលត្រឡប់ទៅព្យាបាលជំងឺនៅប្រទេសកម្ពុជាវិញ ប៉ុន្តែព្រឹកឡើងស្រាប់តែប្រទះឃើញឪពុកមកចងកនិងដើមឈើ ក្បែរកន្លែងធ្វើការទៅវិញ ។ ក្រោយពេលកើតហេតុកម្លាំងសមត្ថកិច្ចតម្រួតតំបន់បានបឹង បានចុះធ្វើការត្រួតពិនិត្យកន្លែងកើតហេតុ និងបញ្ជូនសាកសពយកទៅមន្ទីរពេទ្យដើម្បីកោសល្យវិច័យ រួចប្រគល់ជូនសាច់ញាតិយកទៅធ្វើបុណ្យតាមប្រពៃណី៕ នីមវណ្ណា

## ពលករខ្មែររងគ្រោះថ្នាក់ធ្លាក់ពីលើស្ពាននៅប្រទេសថៃ

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា-Prak Pheaktra 29-10-2019

29/10/19 ដំណឹងប្រកាសរកសាច់ញាតិពលករខ្មែរ០១នាក់ ឈ្មោះ ហួរ សុផន (Hou Sorphorn) ភេទប្រុស អាយុ៣៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ N01350606 ស្រុកកំណើតរស់នៅខេត្តបាត់ដំបង បន្ទាប់ពីពលកររូបនោះរងគ្រោះថ្នាក់ធ្លាក់ពីលើស្ពាន បច្ចុប្បន្នជនរងគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យភូនិភុនអាដុលយ៉ាដេត នៃទីក្រុងបាងកក ប្រទេស ថៃ។

## នារីខ្មែរជិត១ម៉ឺននាក់ បានរៀបការជាមួយបុរសកូរ៉េ

https://dap-news.com/national/ Posted on October 28, 2019

ទីក្រុងសេអ៊ូលៈ រហូតមកដល់ពេលនេះមាននារីខ្មែរជាង៨ពាន់នាក់ហើយបានរៀបការជាមួយបុរសកូរ៉េខាងត្បូង តែជិតពាក់កណ្តាលនៃចំនួននោះ ក៏បានលែងលះគ្នាទៅវិញ។ នេះបើយោងតាមតួលេខដែលលោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតខ្មែរប្រចាំនៅកូរ៉េខាងត្បូងទទួលបានត្រួសៗ។ ការលែងលះគ្នាមានចំនួនច្រើនបែបនេះមិនមែនកើតឡើងចំពោះតែនារីខ្មែរទេ វាជាចរន្តទូទៅក្នុងសង្គមបុរសកូរ៉េដែលយកប្រពន្ធបរទេស។

មន្ត្រីការទូតនិងអ្នកសាព័ត៌មានកូរ៉េបាននិយាយថា ការលែងលះគ្នាភាគច្រើនកើតឡើងដោយកត្តាវប្បធមកូរ៉េ ដែលតម្រូវឱ្យប្រពន្ធត្រូវតែចេះនិយាយភាសាកូរ៉េ ត្រូវតែរៀបចំម្ហូបអាហារឱ្យប្តីទាំងពេល (ព្រឹក ថ្ងៃនិងល្ងាច) និងត្រូវជួយមើលថែទាំឪពុកម្តាយក្មេក ។ល។ ទាំងនេះ ជាការដើរបញ្ច្រាស់ទៅនឹងទម្លាប់រស់នៅបែបថ្មីរបស់នារីអាស៊ីមួយចំនួននាពេលបច្ចុប្បន្នដែលគេចូលចិត្តទៅញ៉ាំអាហារនៅខាងក្រៅឬចង់មានសេរីភាពគ្រួសារជាងមុន។

ជុំវិញការរកប្រពន្ធបរទេសនេះ រដ្ឋាភិបាលកូរ៉េបានបង្ហើបឱ្យដឹងថា ប៉ុន្មានឆ្នាំចុងក្រោយនេះ នារីវៀតណាមកំពុងពេញនិយម ដែលក្នុងមួយៗឆ្នាំមាននារីវៀតណាមប្រហែល៦ពាន់នាក់បានរៀបការជាមួយបុរសកូរ៉េ។ បើយើងមើលមួយភ្លែតហាក់ដូចជាសំណាងរបស់នារីបរទេសទាំងនោះ រួមទាំងនារីខ្មែរផង តែការពិតមិនមែនសុទ្ធតែសំណាងនោះទេ វាជារឿងអភ័ព្វទៅវិញក៏ថាបាន។

តាមការស្ទង់មតិទៅលើនារីជាប្រពន្ធចំនួន៩២០នាក់ នៅឆ្នាំ២០១៨ កន្លងមកនេះ បានបង្ហាញថា ៤២% សុទ្ធតែឆ្លងកាត់អំពើហឹង្សាក្នុងគ្រួសារដែលបង្កដោយប្តី។ ហើយថ្មីៗនេះ អំពើហឹង្សាលើប្រពន្ធជាស្ត្រីវៀតណាមអាយុ៣៦ឆ្នាំនៅចំពោះមុខកូនបានធ្វើឱ្យរដ្ឋាភិបាលកូរ៉េ ត្រូវបង្ខំចិត្តចេញបញ្ញតិថ្មីមួយហាមមិនឱ្យបុរសកូរ៉េដែលមានប្រវត្តិប្រើអំពើហឹង្សាលើប្រពន្ធអាចរៀបការជាមួយនារីបរទេសថ្មីទៀតឡើយ។ ទន្ទឹមនឹងបំរាមខាងលើ រដ្ឋាភិបាលកូរ៉េក៏បានបិទភ្នែកម្ខាងឱ្យប្រុសៗរបស់ខ្លួនមានឱកាសយកប្រពន្ធបរទេស ដើម្បីបង្កើតកូនឱ្យបានច្រើនក្នុងបំណងរក្សាតុល្យភាពកំណើនមនុស្សថ្មីជំនួសមនុស្សចាស់ ។

បច្ចុប្បន្នប្រទេសកូរ៉េខាងត្បូងកំពុងជួបបញ្ហាសង្គមពីរៈ ទីមួយចំនួននារីច្រើនជាងបុរស ពួកគេមិនចង់រៀបការហើយក៏មិនចង់មានកូនដែរ។ ទីពីរ បុរសកូរ៉េនៅតាមជនបទពិបាកសុំស្នេហ៍ពីនារីសាសន៍ដូចគ្នាដោយសារគម្លាតចំណេះដឹង ការងារ និងប្រាក់ចំណូល។ កត្តានេះហើយដែលធ្វើឱ្យបុរសកូរ៉េភាគច្រើននៅជនបទត្រូវអែ (កម្លោះព្រៅ) ដូច្នេះហើយទើបពួកគេបែរទិសដៅរកនារីបរទេសរហូតឆ្លាយដល់អឺរ៉ុបខាងកើតឲ្យតែយកបាន។

ក្រៅពីកត្តាខាងលើ បុរសកូរ៉េក៏តែងសម្លឹងរកនារីបរទេសដោយសារចំណាយតិច អស់ជាងមួយម៉ឺនដុល្លារបានប្រពន្ធមួយ បើប្រៀបធៀបការរៀបអាពាហ៍ពិពាហ៍ជាមួយនារីកូរ៉េគ្នាឯងត្រូវចំណាយជាមធ្យមជិត១០ម៉ឺនដុល្លារឯណោះ។ ដោយឡែកចំពោះនារីកូរ៉េរកប្តីបរទេសវិញ បើយោងតាមតួរលេខឆ្នាំ២០១៧ បុរសចិនមានសំណាងបាននារីកូរ៉េច្រើនជាងគេ បន្ទាប់មកមាន អាមេរិក កាណាដា ជប៉ុន និងអូស្ត្រាលី ។ បុរសខ្មែរមានចំនួនតិចតួចណាស់ ប្រហែលជាមិនទាន់ជាប់ក្រសែភ្នែកនារីកូរ៉េនៅឡើយក៏ថាបាន ឬមួយក៏នារីកូរ៉េមិនមែនជាជម្រើសរបស់បុរសខ្មែរក៏មិនដឹង។ អត្ថបទក្រោយខ្ញុំអាចនឹងឈ្លេចសួរនារីកូរ៉េនិងបុរសខ្មែរអំពីស្នេហាឆ្លងសាសន៍៕

## ត្រាំ នឹងផ្អាកអនុគ្រោះពន្ធដល់ឧស្សាហកម្មគ្រឿងសមុទ្រថៃ

https://www.postkhmer.com/ AFP | Publication date 28 October 2019 | 10:50 ICT

**ក្រុងវ៉ាស៊ីនតោនៈ** លោក ដូណាល់ ត្រាំ នឹងផ្អាកការអនុគ្រោះពន្ធពាណិជ្ជកម្មសម្រាប់ឧស្សាហកម្មអាហារសមុទ្ររបស់ប្រទេសថៃ បន្ទាប់ពីប្រទេសនេះបានបរាជ័យក្នុងការចាត់វិធានការកែលម្អសិទ្ធិកម្មករ ដែលធ្វើឲ្យប៉ះពាល់ដល់វិស័យច្រើនពាន់លានដុល្លារមួយនេះ។ ថៃគឺជាប្រទេសនាំចេញអាហារសមុទ្រឈានមុខគេទី៣ របស់ពិភពលោក

ប៉ុន្តែឋានៈជាប្រទេសផ្គត់ផ្គង់របស់ខ្លួនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយការរាយការណ៍ពីពលកម្មទាសករ និងការជួញដូរក្នុងចំណោមកម្លាំងពលកម្មចំណាកស្រុក។

ទីភ្នាក់ងារព័ត៌មាន Bloomberg News បានរាយការណ៍កាលពីថ្ងៃសៅរ៍ដោយដកស្រង់សម្តីការិយាល័យតំណាងពាណិជ្ជកម្មអាមេរិកថា ផលិតផលអាហារសមុទ្រទាំងអស់របស់ប្រទេសថៃនឹងបាត់បង់សិទ្ធិស្របច្បាប់របស់ខ្លួនសម្រាប់ការទទួលបានការអនុគ្រោះពន្ធពាណិជ្ជកម្មដោយសារតែ «បញ្ហាសិទ្ធិកម្មករដែលអូសបន្លាយរយៈពេលយូរនៅក្នុងឧស្សាហកម្មអាហារសមុទ្រ និងឧស្សាហកម្មដឹកជញ្ជូន»។ ការផ្អាកការអនុគ្រោះពន្ធពាណិជ្ជកម្មដែលទីភ្នាក់ងារព័ត៌មាន Bloomberg បានឲ្យដឹងថាមានតម្លៃ ១,៣ ពាន់លានដុល្លារនេះនឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២០។ នេះបើយោងតាមលិខិតមួយដែលបានផ្ញើកាលពីថ្ងៃសុក្រទៅកាន់លោកស្រី Nancy Pelosi អ្នកនាំពាក្យសភាជាន់ទាបអាមេរិក។

លោក ត្រាំ បានឲ្យដឹងនៅក្នុងលិខិតនេះថា៖ «ខ្ញុំបានកំណត់ហើយថា ប្រទេសថៃមិនកំពុងចាត់វិធានការដើម្បីឲ្យកម្មករនៅក្នុងប្រទេសថៃត្រូវបានទទួលស្គាល់សិទ្ធិកម្មជាអន្តរជាតិនោះទេ។ វាជាការសមស្របក្នុងការផ្អាកសិទ្ធិទទួលបានការរួចពន្ធនេះ»។ ស្ថិតក្រោមកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធ (GSP) របស់អាមេរិក បណ្តាប្រទេសដែលមានសិទ្ធិទទួលប្រព័ន្ធនេះអាចនាំចូលទំនិញមួយចំនួនទៅកាន់អាមេរិកដោយរួចពន្ធ។ ទំនិញផ្សេងទៀតដែលបាត់បង់ការទទួលបានការអនុគ្រោះពន្ធនេះ រួមមានផលិតផលផ្លែឈើ បន្លែ សម្លៀកបំពាក់ និងឧបករណ៍អគ្គិសនី។

យោងតាមការិយាល័យអ្នកតំណាងពាណិជ្ជកម្មអាមេរិកការនាំចេញពីថៃទៅអាមេរិកមានចំនួនសរុប ៣១,៩ ពាន់លានដុល្លារនៅឆ្នាំ ២០១៨ ដោយគ្រឿងម៉ាស៊ីនអគ្គិសនីគឺជាទំនិញដែលមានបរិមាណច្រើនជាងគេ។ ការផ្អាករបស់អាមេរិកនេះធ្វើឡើង ទោះបីជាសហភាពអឺរ៉ុបនៅពេលថ្មីៗនេះបានដកប្រទេសថៃ ចេញពីការព្រមានរបស់ខ្លួនកាលពីខែមករាដោយមើលឃើញកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដោយរដ្ឋាភិបាលថៃ ដើម្បីដោះស្រាយការនេសាទខុសច្បាប់។ ប្រទេសថៃ បានស្ថិតក្នុងបញ្ជីនេះចាប់តាំងពីឆ្នាំ ២០១៥ មកបន្ទាប់ពីមានការចោទប្រកាន់ពីបទរំលោភសិទ្ធិកម្មករ ដែលមិនអាចគ្រប់គ្រងបានក្នុងក្រុមនាវានេសាទរបស់ខ្លួន។

លោក Phil Robertson អនុប្រធានទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅតំបន់អាស៊ីរបស់អង្គការ Human Rights Watch កាលពីថ្ងៃសៅរ៍បានអបអរសាទរវិធានការនេះដោយហៅការអនុវត្តច្បាប់ការពារកម្មកររបស់ប្រទេស ថៃ ថា « គួរឲ្យអាណិត»។ លោក Robertson ថ្លែងថា៖ «អស់រយៈពេលជាច្រើនឆ្នាំហើយ ប្រទេសថៃ បានបរាជ័យក្នុងការការពារទាំងកម្មករថៃ និងកម្មករចំណាកស្រុកមកពីបណ្តាប្រទេសជិតខាងជាច្រើនពីនិយោជិតដែលមិនស្មោះត្រង់ដែលបណ្តេញនរណាម្នាក់ដែលក្រោកឈរទាមទារសិទ្ធិរបស់ពួកគេចេញពីការងារ»។ លោកបន្តថា៖ «ការកែទម្រង់គឺហួសពេលកំណត់យូរហើយ»។

លោកស្រី Narumon Pinyosinwat អ្នកនាំពាក្យរបស់រដ្ឋាភិបាលថៃកាលពីថ្ងៃសៅរ៍ចុងសប្តាហ៍មុនបានបដិសេធការអត្ថាធិប្បាយស្តីពីការផ្អាកនេះ៕ LA

# ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៩

## សម្តេច ស ខេង ជំរុញឱ្យវិនិយោគការងារក្នុងស្រុកកាន់តែច្រើន ទប់ស្កាត់ពលរដ្ឋចំណាកស្រុក

https://thmeythmey.com/ 30, Oct 2019 , 7:39 pm

សៀមរាបៈ កម្ពុជាកំពុងធ្វើម្ចាស់ផ្ទះកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេសនៃប្រទេសបញ្ជូនទាំង៣ កម្ពុជា ឡាវ មីយ៉ាន់ម៉ា (CLM) ស្តីពីតួនាទីប្រទេសបញ្ជូនដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍។ ក្នុងកិច្ចប្រជុំនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្តេច ស ខេង បានជំរុញឱ្យមានការវិនិយោគឱកាសការងារកាន់តែច្រើនបន្ថែមទៀត ដើម្បីទប់ស្កាត់ការចំណាកស្រុករបស់ប្រជាពលរដ្ឋ។ នេះជាលើកទី២ហើយ ដែលគណៈប្រតិភូនៃប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ជួបពិភាក្សាលើកិច្ចការពារពលករទេសន្តរប្រវេសន៍ ដើម្បីពិភាក្សារកដំណោះស្រាយបញ្ហាប្រឈមនានា ដែលកំពុងកើតឡើង លើពលករទាំងស្របច្បាប់ និងមិនស្របច្បាប់ទៅក្រៅប្រទេស ពិសេសប្រទេសថៃ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងថា គោលបំណងសំខាន់នៃកិច្ចប្រជុំលើកទី២នេះ ធ្វើឡើងដើម្បីស្វែងយល់ពីស្ថានភាព និងទំនោរនៃទេសន្តរប្រវេសន៍បច្ចុប្បន្នដើម្បីរិះរកវិធានការលុបបំបាត់ការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី ការជួញដូរមនុស្ស និងរាល់ទម្រង់នៃអំពើកេងប្រវ័ញ្ច និងការលើកកម្ពស់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងស្របច្បាប់។ ក្នុងកិច្ចប្រជុំនេះដែរ ក៏នឹងកំណត់រកបញ្ហារួមនិងផ្លាស់ប្តូរបទពិសោធន៍ល្អៗក្នុងការដោះស្រាយបញ្ហានានា តាមរយៈការពង្រឹងកិច្ចសហការក្នុងការឆ្លើយតបការបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារជនរងគ្រោះនៅក្នុងប្រទេសរៀងៗខ្លួន ក៏ដូចជាប្រទេសគោលដៅ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ សម្តេច ស ខេង មានប្រសាសន៍ថា កិច្ចប្រជុំនេះគឺដៅខ្ពស់លើការការពារទេសន្តរប្រវេសន៍ ហើយបញ្ហានេះមានភាពស្មុគស្មាញបើគេស្វែងរកមូលហេតុដែលធ្វើឱ្យកើតមានទេសន្តរប្រវេសន៍ឬការចំណាកស្រុកទៅធ្វើការនៅប្រទេសក្រៅ។ បញ្ហាដែលរដ្ឋមន្ត្រីមហាផ្ទៃលើកមកនិយាយនោះមានដូចជាការអភិវឌ្ឍមុខរបរមិនទាន់រីកចម្រើន បញ្ហាការរស់នៅ។ល។ ក្នុងពិធីបើកកិច្ចប្រជុំនៅថ្ងៃទី៣០ តុលា សម្តេច ស ខេង ជំរុញឱ្យប្រទេសទាំង៣ដែលកំពុងជួបប្រជុំគ្នា ត្រូវជំរុញការវិនិយោគឱកាសការងារឱ្យបានកាន់តែច្រើន ដើម្បីជាជម្រើសល្អសម្រាប់ប្រជាពលរដ្ឋធ្វើការ និងអាចទាញចំណូលសម្រាប់ដោះស្រាយជីវភាពរស់នៅ ជៀសវាងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ យ៉ាងណាក៏ដោយ សម្តេច ស ខេង ពន្យល់ថា ការចំណាកស្រុកគឺមានស្ទើរគ្រប់ប្រទេសលើកលែងតែប្រទេសដែលមានការអភិវឌ្ឍខ្ពស់តែប៉ុណ្ណោះ ក្នុងនោះប្រជាជនថៃផ្ទាល់ក៏មានប្រជាពលរដ្ឋចេញទៅធ្វើការនៅបរទេសដែរ។

បន្ថែមពីនេះ ប្រធាន គ.ជ.ប.ជ ក៏មិនចង់ឱ្យប្រទេសទាំងបី មានកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា យកលទ្ធផលនៃកិច្ចប្រជុំលើកនេះទៅសង្កត់កថៃរឿងពលកររបស់ខ្លួននោះដែរ។ តាមយោបល់សម្តេច ស ខេង ប្រទេសទាំងបីគួរយល់ពីស្ថានភាពរបស់ថៃ ដ្បិតថាប្រទេសនេះក៏រងសម្ពាធខ្លាំងពីអន្តរជាតិច្រើនដែរទាក់ទងនឹងរឿងនេះ ពិសេសពលករធ្វើការលើទូកនេសាទតែម្តង។ សម្តេចបញ្ជាក់ថា គួរមានកិច្ចប្រជុំបួនភាគីម្តងដើម្បីជជែកដោយផ្ទាល់ជាមួយថៃ ហើយការរិះរកដំណោះស្រាយផ្សេងៗសម្រាប់ជួយទេសន្តរប្រវេសន៍នេះ ក៏ជាចំណែកជួយប្រមូលនូវធាតុចូលល្អៗ ថ្មីៗដើម្បីជាជំនួយស្មារតីដល់ភាគីថៃក្នុងការដោះស្រាយបញ្ហាប្រឈមនានាផងដែរ។

គួរបញ្ជាក់ថា បន្ទាប់ពីកិច្ចប្រជុំនេះ ប្រទេសទាំងបីនឹងធ្វើកំណត់ហេតុរួមមួយដែលបានចុះហត្ថលេខារួមដោយដាក់ចេញនូវអនុសាសន៍ជាសំណើរសំខាន់ៗ ចំពោះរដ្ឋាភិបាលនៃប្រទេសទាំងបី ក្នុងការផ្តួចផ្តើមជាដំណោះស្រាយរួមគ្នា និងសម្រាប់ការពិភាក្សាជាមួយប្រទេសថៃ ដែលជាប្រទេសគោលដៅ ដើម្បីលើកកម្ពស់ កិច្ចការពារពល

ករទេសន្តរប្រវេសន៍ឲ្យមានសុវត្ថិភាព និងទទួលបានផលប្រយោជន៍ដោយស្របច្បាប់ ព្រមទាំងការចែករំលែកប្រកបដោយសមធម៌ នូវការទទួលខុសត្រូវ លើការដោះស្រាយភាពប្រឈម និងផលប្រយោជន៍ រវាង និយោជក និងនិយោជិក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល៕

## កម្ពុជា ឡាវ មីយ៉ាន់ ស្វះស្វែងរកវិធីសាស្ត្រការពារពលករទេសន្តរប្រវេសន៍

http://bayontv.com.kh/ 30/10/2019

ភ្នំពេញ៖ ប្រទេសកម្ពុជា ឡាវ មីយ៉ាន់មា (CLM) បានបើកប្រជុំកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ ដឹកនាំបច្ចេកទេស ស្តីពីតួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍ ដែលកិច្ច ប្រជុំនេះសំដៅឆ្ពោះទៅរកវិធីសាស្ត្រការពារពលករទេសន្តរប្រវេសន្តន៍ ដែលទៅធ្វើការនៅប្រទេសថៃ។

ក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូន ទាំងបី កម្ពុជា ឡាវ មីយ៉ាន់មា ស្តីពីតួនាទី នៃប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរ ប្រវេសន៍ នៅថ្ងៃទី៣០ ខែតុលា នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហា ផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងថា កិច្ចប្រជុំនេះ មានសារសំ ខាន់ ហើយក៏ជាការបំពេញករណីយកិច្ចជាប្រទេសសមាជិកក្នុងតំបន់ និងក្នុងពិភពលោក ក្នុងការពង្រឹង កិច្ចសហការស្វែងរកគន្លឹះ ដោះស្រាយរួមគ្នា រវាងប្រទេស ដែលមានស្ថានភាពប្រហាក់ប្រហែលគ្នា បង្ហាញអំពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្ត ក្នុងកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ពលករ ពីភាពរងគ្រោះ និង ជនរងគ្រោះ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ជាពិសេស ពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូប ភាព ដែលនឹងផ្តល់ផលប្រយោជន៍ប្រកបដោយសមធម៌ សម្រាប់ភាគីទាំងសងខាង គឺនិយោជក និងនិយោ ជិត និងរវាងប្រទេសបញ្ជូន និងប្រទេសគោលដៅនៃការទទួល។

សម្រេចក្រឡាហោម បានបញ្ជាក់ថា ប្រទេសកម្ពុជា ឡាវ មីយ៉ាន់មា ជាប្រទេសជិតខាងគ្នា មានព្រំ ដែនជាប់ជាមួយប្រទេសថៃដូចគ្នា មានប្រជាពលរដ្ឋ កំពុងធ្វើការនៅក្នុងប្រទេសថៃដូចគ្នា ទាំងស្របច្បាប់ និងមិនស្របច្បាប់ ក្នុងចំនួនយ៉ាងច្រើន។ មួយចំនួន បាននឹងកំពុងប្រឈមនឹងបញ្ហាជាច្រើន ក្នុងដំណើរ ការទេសន្តរប្រវេសន៍ តាំងពីការចាកចេញ ទាំងនៅកន្លែងធ្វើការ និងរហូតដល់ពេលត្រឡប់មកវិញ។ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ទៀតថា គោលដៅ នៃកិច្ចប្រជុំពិគ្រោះយោបល់នេះ គឺសំ ដៅឆ្ពោះទៅរកវិធីសាស្ត្រកិច្ចការពារពលករទេសន្តរប្រវេសន្តន៍តែប៉ុណ្ណោះ មិនបាននិយាយទៅដល់ការរក មូលហេតុ ដែលនាំឲ្យមានទេសន្តរប្រវេសន៍នោះទេ។ ការរិះរកវិធីសាស្ត្រការពារពលករទេសន្តរប្រវេសន៍ របស់ប្រទេសទាំងបី ជាការរួមចំណែកមួយ ប្រមូលជាគុចូលល្អៗថ្មីៗ ដើម្បីប្រឹក្សាជាមួយភាគីថៃ ដែលអាច និយាយបានថា ជាជំនួយស្មារតី ដើម្បីដោះស្រាយបញ្ហាដែលកំពុងមានចំណោទ។

កិច្ចប្រជុំនេះ ពុំមែនជា ការចាប់ដៃគ្នារវាងប្រទេសទាំងបី ដើម្បីដាក់សម្ពាធទៅលើភាគីថៃនោះទេ ប៉ុន្តែគឺជាការរួមគ្នា ដើម្បីបង្ហាញ ទស្សនទានថ្មីៗ ក្នុងន័យការពារពលករ ដែលចាកចេញពីប្រទេសរបស់ខ្លួន ហើយក៏ជួយការពារចំពោះភាគី ថៃ ដែលជាប្រទេសអ្នកទទួលពលករផងដែរ ដើម្បីធ្វើឱ្យពលករ ដែលកំពុងធ្វើការនៅប្រទេសថៃ ក៏ទទួលបានផលប្រយោជន៍ ហើយភាគីថៃ ដែលជាប្រទេសគោលដៅទទួលពលករពហុទិស ក៏ទទួលបានផល ប្រយោជន៍ ដូចនេះ អ្វីៗទាំងអស់ គឺដើម្បីយល់ទាំងអស់គ្នា ថានេះគឺជាការរួមចំណែកពីគ្នាទៅវិញទៅមក៕

## គ្មានទេ! ពលករខ្មែររាប់ពាន់នាក់ វិលត្រឡប់ចូលស្រុកតាមច្រក«ដូង

https://kbn.news/archives/ October 30, 2019

ខេត្តបាត់ដំបង ៖ មេប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង លោកវរសេនីយ៍ឯក ផាត សុផាន់ណា បានចេញមកបំភ្លឺ និងធ្វើការបដិសេធ ទាត់ចោលទាំងស្រុងចំពោះព័ត៌មានក្នុងស្រុកមួយ ដែលផ្សាយនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩ថា ពលករខ្មែររាប់ពាន់នាក់ នៅតែបន្តវិលត្រឡប់ចូលស្រុកតាមច្រក«ដូង» ដែលនាំឲ្យមហាជនមានការភាន់ច្រឡំ ។ តាមរយៈសេចក្តីបំភ្លឺថា សារព័ត៌មាននោះ បានយករូបភាពចាស់កាលពីឆ្នាំ២០១៨ ដែលប្រជាពលរដ្ឋខ្មែរធ្វើដំណើរចូលមកប្រទេសកម្ពុជាវិញតាមច្រកទ្វារព្រំដែនអន្តរជាតិដូងដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ។ លោកវរសេនីយ៍ឯក ផាត សុផាន់ណា នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង ក៏បានអំពាវនាវដល់គ្រប់បណ្តាញសារព័ត៌មាន និងអ្នកប្រើប្រាស់បណ្តាញសង្គមទាំងអស់ មេត្តាកុំចុះផ្សាយនូវព័ត៌មានដែលមិនពិត និងមានប្រភពព័ត៌មានមិនច្បាស់លាស់ ដែលនាំឲ្យមានការយល់ច្រឡំ និងប៉ះពាល់ដល់កិត្តិយសស្ថាប័នមានសមត្ថកិច្ច ដែលកំពុងបំពេញភារកិច្ចជូនប្រជាពលរដ្ឋ និងប្រទេសជាតិ ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៧នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI ថ្ងៃទី៣១-១០-២០១៩

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៧នាក់ នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៧នាក់នេះ មានស្រុកកំណើតនៅខេត្តសៀមរាប ០៧នាក់ ស្រី ០៥នាក់ ៕

## ស្ថានទូតខ្មែរនៅថៃ ចេញសេចក្តីប្រកាសព័ត៌មានថា ពលករខ្មែរកំពុងបម្រើការងារតាមធម្មតានៅប្រទេសថៃ មិនមានការវិលត្រឡប់មកកម្ពុជាជាគំហុកនោះឡើយ

http://www.freshnewsasia.com/ 2019-10-31

**(ភ្នំពេញ)៖** ស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ បានចេញមកប្រកាសថា បច្ចុប្បន្នពលករខ្មែរនៅក្នុងប្រទេសថៃ កំពុងបម្រើការងារតាមធម្មតា ពុំមានការធ្វើដំណើរវិលត្រឡប់ទៅប្រទេសកម្ពុជា ជាគំហុក ដូចដែលសារព័ត៌មានមួយចំនួនបានធ្វើការចុះផ្សាយនោះទេ។ នេះបើតាមសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩នេះ។ ស្ថានទូតកម្ពុជា បានអះអាងទៀតថា ភាគីថៃ ក៏កំពុងតែដំណើរការបន្តទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារជូនដល់បងប្អូនពលករអាចស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃបន្តទៀតបាន រហូតដល់ឆ្នាំ២០២២។ ដូចនេះសូមពលករទាំងអស់ រក្សាភាពស្ងៀមស្ងាត់ និងបន្តអនុវត្តការងារជាធម្មតា កុំជឿតាមការផ្សព្វផ្សាយ និងការញុះញង់ របស់សារព័ត៌មានមួយចំនួន ដែលជាហេតុបង្កឲ្យបងប្អូនខាតបង់ថវិកា ពេលវេលា និងអាចត្រូវនិយោជក បញ្ឈប់ពីការងារទៀតផង។

គួរជម្រាបថា ការចេញមកអះអាងរបស់ស្ថានទូតកម្ពុជា នៅប្រទេសថៃបែបនេះ បានធ្វើឡើងបន្ទាប់ពីថ្មីៗនេះមានការចុះផ្សាយដោយយករូបភាព និងឃ្លីបវីដេអូចាស់ៗ អំពីការចុះត្រួតពិនិត្យពលករបរទេសរបស់អាជ្ញាធរថៃ និងការធ្វើដំណើរឆ្លងកាត់ព្រំដែនវិលត្រឡប់ ទៅចូលរួមបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ របស់បងប្អូនពលករនាពេលកន្លងមក មកធ្វើការផ្សព្វផ្សាយឡើងវិញ ក្នុងគោលបំណងបង្កការភ្ញាក់ផ្អើល និងអូសទាញឲ្យពលករត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីកេងចំណេញផ្នែកនយោបាយ៕